ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 10-Apr-2017, 11:30
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី២៦៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ម៉ាដាលេណា ហ្គេហ្ស៊ី
*(Ms. Maddalena Ghezzi)*
លោកស្រី សែ កុលវុឌ្ឍី
លោក រ៉ូជឺ ហ្វីលីព *(Mr.Roger Phillips)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង
កញ្ញា សុង ឆវ័ន្ត
លោក ឌេល លីសាក់ *(Mr.DALE LYSAK)*
លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ស្វួន វិសាល

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ

*(Mrs. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក គីម ម៉េងឃី

លោក ឡោ ជុនធី

លោក ហុង គីមសួន

លោកស្រី ស៊ីន សុវ៉ន

លោកស្រី ម៉ុច សុវណ្ណារី

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី ស្វួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោកស្រី ម៉ុច សុវណ្ណារី | ខ្មែរ |
| លោក សូត្រ សាំង (2-TCCP-304) | ខ្មែរ |
| លោក សយ សែន (2-TCCP-271) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សុត្រ សាំង** (2-TCCP-304)

សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ....................ទំព័រ ៣
សួរដោយលោក គង់ សំអុន ផ្ដើមពី ....................ទំព័រ ២៨
សួរដោយលោកស្រី អង់តា ហ្គីសសេ ផ្ដើមពី ....................ទំព័រ ៣៥
សួរដោយចៅក្រម ហ្សង់ ម៉ាកឡាវ៉ែន ផ្ដើមពី ....................ទំព័រ ៤៦
សួរបន្តដោយលោកស្រី អង់តា ហ្គីសសេ ផ្ដើមពី ....................ទំព័រ ៤៨

**ការសួរសំណួរទៅសាក្សី៖ លោក សយ សែន** (2-TCCP-271)

សួរដោយលោកស្រី ម៉ុច សុវណ្ណារី ផ្ដើមពី ....................ទំព័រ ៥២
សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្ទាឯល ផ្ដើមពី ....................ទំព័រ ៥៥
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី....................ទំព័រ ៧១
សួរដោយលោកស្រី អង់តា ហ្គីសសេ ផ្ដើមពី ....................ទំព័រ ៨០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅព្រឹកនេះ អង្គជំនុំជម្រះធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង បន្តបញ្ចប់ ហើយនិងនៅរសៀលនេះអង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី សយ សែន។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះគឺលោក សូត្រ សាំង លោកមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ ហើយនៅថ្ងៃនេះដែរមានដើមបណ្តឹងរដ្ឋប្បវេណីបម្រុងមួយរូបដែលមានរហស្សនាម 2-TCCP-271។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ជាដំបូងនេះ អង្គជំនុំជម្រះសូមសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយមានបញ្ហាសុខភាពមិនអំណោយផលឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥។ មេធាវីការពារក្តីរបស់ខ្លួន បានប្រាប់អំពីផល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ បានកត់សម្គាល់ស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា ថាលោក នួន ជា មានអាការៈឈឺចង្កេះជាប្រចាំ គឺនិងកាន់តែឈឺខ្លាំងឡើងនៅពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថាសូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៥:៤៦]

ដោយផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះ យល់ព្រមនិងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា នៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយអង្គជំនុំជម្រះក៏សូមជម្រាបជូនដល់ភាគីដែលពាក់ព័ន្ធនៅក្នុងរឿងក្តីនេះថា កិច្ចដំណើរការនីតិវិធីស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 ដែលនៅចំពោះមុខអង្គជំនុំជម្រះត្រូវបានធ្វើឡើងជាអសាធារណៈមួយផ្នែក បន្ទាប់មកសវនាការត្រូវបានផ្អាក ដោយសារមានសំណើសុំវិធានការការពារពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណី ហើយដែលរួមមានការធ្វើសវនាការស្តាប់សក្ខីកម្មដែលនៅសេសសល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះជាអសាធារណៈ និងការរៀបចំធ្វើរបាយការណ៍វាយតម្លៃដោយអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ។

របាយការវាយតម្លៃរបស់អង្គភាពគាំពារសាក្សីនិងអ្នកជំនាញឯកសារ E--

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:០៧:៤២]

បាទ ឥឡូវនេះ បញ្ហានេះដោយសារបញ្ហាទំនងជាមានការភ័ន្តច្រឡំលើការរៀបចំសេចក្ដីសម្រេចនេះ ដែលធ្វើឲ្យមានការ -- មានភាពខុសគ្នារវាងភាសាខ្មែរ និងភាសាអង់គ្លេស។ ដូច្នេះ អង្គជំនុំជម្រះផ្អាកការជម្រាបជូនភាគីពាក់ព័ន្ធនឹងបញ្ហានេះមួយអន្លើសិន ហើយរង់ចាំរហូតដល់ពេលអង្គជំនុំជម្រះត្រឡប់មកពីសម្រាកនៅម៉ោងទីមួយនេះ អង្គជំនុំជម្រះនឹងជម្រាបជូនដល់ភាគី និងសាធារណជនជ្រាបលើបញ្ហានេះសាជាថ្មីម្ដងទៀតរួមទាំងសម្រេចលើសំណើសុំរបស់មេធាវីការពារក្ដីរបស់លោក ខៀវ សំផន ផងដែរ។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាទៅដល់ក្រុមមេធាវីការពារក្ដី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

បាទ មេធាវីការពារក្ដីលោក នួន ជា អស់? សូមអញ្ជើញបាទ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរសហការី។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជម្រាបសួរលោកដើមបណ្ដឹងរដ្ឋប្បវេណី។ កាលពីម្សិលមិញមុនពេលឈប់សម្រាក ខ្ញុំបានសួរសំណួរមួយចំនួនអំពីសក្ខីកម្មរបស់ សយ សែន ខ្ញុំនឹងលើកឡើងអំពីប្រធានបទនេះឡើងវិញក្នុងរយៈពេលខ្លីទេ។ តែដំបូងខ្ញុំសូមចាប់ផ្ដើមសួរសំណួរដូចតទៅនេះ គឺទាក់ទងទៅនឹងឈ្មោះរបស់អ្នកទោស និងអ្នកយាមគុក។ អ្នកយាមគុកពីរនាក់គឺ<>ឈ្មោះ អ៊ួក និង ទូច។ ក្នុងចំណោមទាំងពីរនាក់នេះ អ្នកយាមម្នាក់បានផ្ដល់ចម្លើយជូនសហចៅក្រមស៊ើបអង្កេតថា ទូច គឺរស់នៅ<ខាងកើត>វត្តខ្នារ នៅខាងត្បូងលាយបូរ។ តើលោកអាចបញ្ជាក់បានទេ វាត្រឹមត្រូវដែរឬអត់ទេ?

[០៩:១០:០៦]

**លោក ស្យូត្រ សាំង៖**

**ឆ៖** បាទ ទូច រស់នៅទីណា ខ្ញុំមិនដឹងកំណើតកើតជាគាត់ទេ ប៉ុន្តែថាគាត់រស់នៅឃុំលាយបូរ តែឃុំ ស្រុក ខ្ញុំអត់ដឹងទេ គាត់រស់នៅក្នុងឃុំលាយបូរ ប៉ុន្តែភូមិគាត់ខ្ញុំអត់បានដឹងទេបាទ។

**ស៖** ហើយតើលោកអាចជម្រាបជូនតុលាការបានទេ គាត់សព្វថ្ងៃនៅរស់រានមានជីវិតឬក៏អត់

ទេ?

**ឆ៖** បាទ តាំងពី៧៩ មកសព្វថ្ងៃនេះ ខ្ញុំមិនបានដឹងទេ ថាគាត់នៅរស់ ឬមួយគាត់ស្លាប់។

**ស៖** ហើយ <>អ៊្លូក គឺឯកសារ <D40/20>, ERN 00433571 ជាភាសាអង់គ្លេស, ខ្មែរ 00165332, ហើយនិងបារាំង <00524320>, គឺអ្នកឃាមម្នាក់នេះបានផ្ដល់សក្ខីកម្ម និយាយអំពីឈ្មោះ អ៊្លូក ថា "អ៊្លូក ឥឡូវនេះគឺរស់នៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ"។ តើលោកអាចបញ្ជាក់បានទេគាត់ពិតជារស់នៅទីហ្នឹងមែន ឬក៏អត់ទេ?

**ឆ៖** បាទ ពីព្រោះតា អ៊្លូក ហ្នឹង ឈ្មោះតាអ៊្លូកៗហ្នឹងគាត់មិនដឹងនៅកំពង់ស្ពឺ ឬមួយនៅខេត្តណាកាលធ្វើហ្នឹង ខ្ញុំអត់បានដឹងគាត់នៅដែរ មិនដឹងគាត់នៅភូមិណា ឃុំណា មិនដឹងគាត់នៅទីណា។ ខ្ញុំអត់ដឹងទេបាទ។

**ស៖** លោកដឹងថាគាត់សព្វថ្ងៃនៅរស់រានមានជីវិតទេ ឬក៏អត់ទេ?

**ឆ៖** បាទ ចាប់ពី ៧៩ មកបច្ចុប្បន្ន ខ្ញុំអត់ដឹង បានដឹងថា គាត់រស់ ឬមួយស្លាប់បាទ។

**ស៖** សូមអរគុណ។ លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសុំសួរឈ្មោះមនុស្សម្នាក់គឺអ្នកទោសស្រីដែលលោកបានឆ្លើយនៅក្នុងចម្លើយ<ឌី.ស៊ី.ខេម>របស់លោកឆ្លើយ -- គឺឯកសារ D22/88, ERN គឺ 00379422, ខ្ញុំអត់មាន ERN ជាភាសាខ្មែរទេ<។> នេះវាគ្រាន់តែឈ្មោះរបស់បុគ្គលម្នាក់។ លោកដើមបណ្ដឹងរដ្ឋប្បវេណីលោកនិយាយពីអ្នកទោសម្នាក់ឈ្មោះក្អួយបេ។ លោកជម្រាបជូនតុលាការបានទេតើក្អួយបេនេះជាអ្នកណា?

[០៩:១៣:១០]

**ឆ៖** បាទ ក្អួយបេ នេះកាលនៅពេលវ័យកុមារនៅតូចណាស់ គឺ កូនយាយវ៉ាត់។

**ស៖** បាទ ខ្ញុំយល់ហើយ។ សំណួរចុងក្រោយអំពីអ្នកទោសស្រីម្នាក់នៅពេលដែលលោកធ្វើការនៅទីនោះ។ អ្នកទោសស្រីម្នាក់ឈ្មោះ <រុន>។ តើបើខ្ញុំនិយាយអ៊ីចឹង តើលោកអាចនឹកឃើញទេ?

**ឆ៖** ឈ្មោះសូមអញ្ជើញប្រាប់ម្ដងទៀត ខ្ញុំចាំ អត់បានៗស្គាល់ឈ្មោះហ្នឹងបាទ។

**ស៖** ឈ្មោះ រុន។

**ឆ៖** បាទ ឈ្មោះ រុន នេះ ខ្ញុំស្គាល់បាទ។

**ស៖** តើ រុន នេះជាអ្នកទោសស្រី ដែលមានជាប់ពាក់ព័ន្ធនឹងសេចក្ដីស្នេហាជាមួយនឹង តាអាន់មេគុកហ្នឹងដែរហ្នឹង ឬមែនទេ?

**ឆ៖** បាទ ខ្ញុំរឿងស្នេហា រឿងអ្វីទាំងនេះ ខ្ញុំមិនបានដឹងទេ បាទ មិនដឹងគាត់ស្នេហាយ៉ាងម៉េច ឬមួយស្នេហាគាត់ខូចកាយគ្នាត្រង់ណា ខ្ញុំមិនបានដឹងទេបាទ។

**ស៖** លោកចាំអ្វីដែរអំពីឈ្មោះ រុន ហ្នឹងអ្នកទោសស្រី លោកចាំរឿងរ៉ាវរបស់គាត់ខ្លះដែរទេ?

**ឆ៖** អ៊ីរុន នេះគឺចាំបាននៅដើមក្នុងកន្លែងដែលខ្ញុំរែកដីដំបូក រែកបាតត្រពាំងនេះ បាទខ្ញុំចាំបាទ។

**ស៖** លោកដឹងទេថា មូលហេតុអីបានជាគេចាប់ខ្លួនគាត់យកមកឃុំឃាំងនៅគុកក្រាំងតាចាន់?

**ឆ៖** ក្នុងរឿង យាយរុន នេះ ខ្ញុំអត់បានដឹងទេ ពីព្រោះខ្ញុំអត់បានមានអ្នកស៊ើបសួរចម្លើយរបស់គាត់ទេបាទ។

**ស៖** តើ រុន នេះជាមិត្តភក្តិ ឬសហការីរបស់ពេទ្យស្រីម្នាក់ គឺអ្នកទោសស្រីដែលលោកនិយាយពីម្សិលមិញឈ្មោះ ហាន? តើជាមិត្តភក្តិនឹងគ្នា ឬជាសហការីនឹងគ្នា?

**ឆ៖** បាទខ្ញុំអត់ដឹងគាត់មិត្តភក្តិ ឬមួយសហការីយ៉ាងម៉េចទេ ឃើញតែគាត់មកនៅក្នុងហ្នឹងទាំងពីរនាក់បាទ។

**ស៖** តើលោកឃើញពួកគេនៅជាមួយគ្នាក្នុងលក្ខណៈជាមិត្តភក្តិ ឬក៏យ៉ាងម៉េច? សូមលោកជួយរៀបរាប់ឲ្យបានលម្អិតបន្តិច។

**ឆ៖** ក្នុងរស់នៅក្នុងៗគុកនោះ គឺជាការធម្មតាជាមួយខ្ញុំ ក៏ឃើញតែគាត់រស់នៅជាមួយគ្នា ពេលចេញធ្វើការម្តងម្កាលហ្នឹង ក៏ឃើញរស់នៅជាការធម្មតា មិនដែលមានឈ្លោះទាស់ទែងគ្នាទេបាទ។

[០៩:១៧:២០]

**ស៖** សូមអរគុណ។ សំណួរចុងក្រោយទាក់ទងទៅនឹងប្រធានបទពីម្សិលមិញដែលយើងនិយាយគ្នា អំពីអ្នកទោសស្រីម្នាក់ឈ្មោះ រ៉ាត់ ហើយខ្ញុំសួរថា តើលោកធ្លាប់បានឃើញគាត់ ឬក៏ជួបគាត់ទៀតទេ ក្រោយឆ្នាំ១៩៧៩។ <ខ្ញុំគិតថា >លោក<បាន>ឆ្លើយថា លោកមិនដែលបានជួបទៀតទេ។

ហើយនៅក្នុងចម្លើយមួយដែលលោកបានឆ្លើយ លោកបានឃើញគាត់ម្តងនៅក្នុងឆ្នាំ២០០០។ តើនេះត្រឹមត្រូវដែរទេ?

**ឆ៖** ក្នុង យាយរ៉ាត់ ខ្ញុំអត់បានឃើញទេ។ ខ្ញុំជួបប្អូនគាត់ឈ្មោះ ខា នុំងបានទៅលេងដល់ផ្ទះខ្ញុំបាទ។

**ស៖** ដូច្នេះ គឺលោកជួបជាមួយនឹងកូនស្រីរបស់ រ៉ាត់ ទៅវិញទេ មិនមែនជួប រ៉ាត់ ទេ។ អ៊ីចឹងមែនទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទខ្ញុំជួបប្អូនរបស់គាត់ មិនមែនកូនទេ ពីព្រោះ សុខា ហ្នឹងជាប្អូនរបស់គាត់ ជាកូនរបស់យាយញ៉ បាទ។

**ស៖** សូមអរគុណ។ <លោកដើមបណ្ដឹងរដ្ឋប្បវេណី> ខ្ញុំបានលើកឡើងពីមុនបន្តិចមកហើយថាខ្ញុំនឹងរំឭកឡើងវិញអំពីសក្ខីកម្ម <> សយ សែន បានឆ្លើយជូនអ្នកអ្នកស៊ើបអង្កេតរបស់<>តុលាការនេះ និងជម្រាបជូនអង្គជំនុំជម្រះ។ កាលពីម្សិលមិញ លោកបានឆ្លើយទាក់ទងទៅនឹងការចោទប្រកាន់អំពីការប្រព្រឹត្តអំពើរំលោភផ្លូវភេទនៅ<ក្នុងបរិវេណ>ក្រាំងតាចាន់។ ខ្ញុំសូមដកស្រង់សក្ខីកម្មនេះយកមកបង្ហាញជូនលោក ហើយខ្ញុំនឹង<សុំឲ្យ>លោក<ឆ្លើយតប>ប្រតិកម្មយ៉ាង<ម៉េចចំពោះ>ចម្លើយនេះ<។>

[០៩:១៩:៥៨]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន នេះគឺជាឯកសារ គឺសក្ខីកម្មរបស់ សយ សែន E1/257<*(ស៊ីក)*> នៅវេលាម៉ោង ១០:៤០ និងម៉ោង ១០:៤២, ERN 005-- ខ្មែរគឺ 00--

**អ្នកបកប្រែ៖**

លោកប្រធានសូមអនុញ្ញាត លឿនពេក អ្នកបកប្រែតាមអត់ទាន់ ERN។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី វ៉ិចទ័រ កូប៉េ អានលេខ ERN សាជាថ្មីម្ដងទៀត អ្នកបកប្រែ បកប្រែមិនទាន់ទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ គឺ 01064674។ លោកដើមបណ្ដឹងរដ្ឋប្បវេណី គឺ សយ សែន និយាយអំពីលោកនិងនិយាយអំពី ឌុច និងនិយាយអំពីអ្នកយាមដទៃទៀត។ សំណួរគឺដូចតទៅនេះ "មានមនុស្សពីរនាក់មាន ឌុច គឺ ឌុចធំ និង ឌុចតូច។ សូមទោស នេះគឺជាចម្លើយទៅវិញទេ គឺចម្លើយរបស់ សយ សែន មានមនុស្សពីរនាក់ហៅថា ឌុច – ឌុចតូច និង ឌុចធំ។ ឌុចធំ ជាអនុប្រធាន, ឌុចតូច គឺជាកូនចៅទេ។ ក្រៅពីការងាររបស់គាត់សម្លាប់អ្នកទោស ឌុចតូច នេះមានការងារបន្ថែមទៀតគឺ វាយអង្គុលីលេខ ដើម្បីផ្ញើជូនទៅថ្នាក់លើ។ ឌុចតូច គឺជាឈ្មោះមួយផ្សេងទៀត សាំង <ដែល>ជាមនុស្សកាចសាហាវណាស់ <ក្នុងចំណោមកងទ័ពទាំង១២នាក់នេះ>។ <យោងតាមចម្លើយនេះ គេសួរ៖ "តើហេតុអីបានជា> លោក សយ សែន ថា ឌុចតូច និងឈ្មោះមួយទៀតឈ្មោះ សាំង គឺជាមនុស្សដែលកាចជាងគេបំផុតនៅក្នុង

ចំណោមកងទ័ពទាំង១២<?" សយ សែន បានឆ្លើយវិញថា> "ការដែលខ្ញុំនិយាយដូច្នេះ តែពេលណាបើគាត់បានឃើញ ឬអ្នកទោសប្រព្រឹត្តកំហុសអ្វីតូចតាចហ្នឹង គឺថាគាត់នឹងវាយដំអ្នកទោស វាយនឹងដៃទាត់ធាក់នឹងជើង។ គាត់គឺថាប្រើដៃប្រើជើងគាត់ គឺវៃទាត់យ៉ាងខ្លាំង"។ លោកដើមបណ្តឹងរដ្ឋប្បវេណី គឺ សយ សែន បានឆ្លើយថាលោកនេះ និង ឌុច គឺជាមនុស្សដែលកាចសាហាវជាងគេ<ប្រចាំនៅក្នុង> បរិវេណក្រាំងតាចាន់។ តើលោកមានប្រតិកម្មយ៉ាងម៉េចចំពោះចម្លើយនេះ?

[០៩:២២:៥៧]

**លោក ស្វត្រ សាំង៖**

**ឆ៖** បាទ ចំពោះចម្លើយនេះ ខ្ញុំធ្វើចំពោះអ្នកទោស ឬបងប្អូនអ្នកនៅក្នុងក្រាំងតាចាន់ទាំងមូល ខ្ញុំក៏មិនដែលបានមានវាយដំច្រំធាក់ មានការកាប់សម្លាប់គាត់ដោយអំពើហិង្សាមួយ គឺគ្មានទេលោក។ បើលោកពាក្យដើមបណ្តឹងពីក្រៅថា ខ្ញុំនេះអ្នកកាចសាហាវឃោរឃៅ ម្ល៉េះជីវិតខ្ញុំអត់បានរស់នៅក្នុងបច្ចុប្បន្ននេះទេ។ បើខ្ញុំកាចសាហាវដូចពាក្យបណ្តឹងនោះមែនបាទ។

**ស៖** ចុះ ឌុច វិញ? តើ ឌុច គឺជាអ្នកយាមកាចសាហាវដែលប្រព្រឹត្តិអំពើឃោរឃៅមកលើអ្នកទោសដែរទេ?

**ឆ៖** ចំពោះរូប ឌុច ក៏ខ្ញុំមិនដែលបានឃើញទៅវៃទៅដំច្រំធាក់ទេ ពីព្រោះ ឌុច ហើយនិងខ្ញុំដេករស់នៅជាមួយគ្នា។ វេនយាមៗជាមួយគ្នាបាទ។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី គឺថាចម្លើយរបស់លោកហាក់បីដូចជាមានភាពផ្ទុយគ្នាទៅនឹងចម្លើយរបស់ សយ សែន។ គឺថាហាក់បីដូចជាលោកចង់និយាយមានន័យថា សយ សែន នេះគឺនិយាយកុហកតុលាការ។ អ៊ីចឹងលោកយល់ថាម៉េច លោកមានប្រតិកម្មយ៉ាងម៉េចចំពោះសក្ខីកម្មរបស់ សយ សែន នេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកសហមេធាវីរងអន្តរជាតិ -- ព្រះរាជអាជ្ញារងអន្តរជាតិ!

[០៩:២៤:៥៦]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ការជំទាស់របស់ខ្ញុំនេះ គឺថាលោក កូប៉េ កំពុងតែព្យាយាម<នាំមុខ

សាក្សី>ឲ្យគាត់ផ្តល់<មតិយោបល់ ឬកំណត់>ចរិតលក្ខណៈ<សក្ខីកម្ម>មួយផ្សេង<ទៀត>។ <នេះជារឿងដដែលៗ ដែលលោកមេធាវីបានធ្វើជាមួយនឹងសាក្សីម្នាក់ទៀត ដោយលោកមេធាវីបានប្រាប់សាក្សីរូបនោះឲ្យប្រើពាក្យ “ព័ត៌មានប្រឌិត”។ សាក្សីរូបនេះបានផ្តល់ចម្លើយរួចហើយ ដូច្នេះ វាមិនចាំបាច់ណាឲ្យលោកសាក្សីផ្តល់យោបល់ផ្ទាល់ខ្លួនចំពោះសុក្រឹតភាពនៃចម្លើយសាក្សីម្នាក់ទៀតនោះទេ។>

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំមានសិទ្ធិសួរដូច្នេះបាន។ ខ្ញុំបានតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណីមើលទៅគាត់កំពុងតែមានភាព<>ផ្ទុយគ្នាយ៉ាងខ្លាំង។<ដោយសាក្សីរូបនេះជាដើមបណ្តឹងរដ្ឋប្បវេណីជាភាគីម្នាក់ដែរ អ៊ីចឹង គាត់ក៏មានសិទ្ធនិយាយខ្លះដែរអំពីសក្ខីកម្មរបស់> សយ សែន។ ដូច្នេះ ខ្ញុំយល់ឃើញថាការតាំងសំណួរបែបនេះ ជាការសមស្របពាក់ព័ន្ធនឹងបញ្ហានេះ។

[០៩:២៦:១៣]

**ប្រធានអង្គជំនុំ៖**

លោកអាចតាំងសំណួរបាន ប៉ុន្តែលោកមេធាវីមិនគប្បីប្រើពាក្យពេចន៍ឯណាធ្វើឲ្យគោលដៅនៃការឆ្លើយតបនឹងសំណួររបស់លោកបាត់ទំនុកចិត្តនោះទេ។ ពាក្យពេចន៍របស់ខ្លួន ដែលលោកបានធ្វើចុងក្រោយអម្បាញ់មិញនេះ ក្នុងន័យសំដៅធ្វើឲ្យគោលដៅ គឺដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បាត់ទំនុកចិត្តក្នុងការឆ្លើយតបទៅនឹងសំណួររបស់លោកសួរ។ លោកអាចតាំងសំណួរបាន បើសំណួរណាមិនត្រូវសួរ អង្គជំនុំជម្រះប្រើឆន្ទានុសិទ្ធិឬក៏ភាគីជំទាស់ អង្គជំនុំជម្រះនឹងពិចារណាសម្រេចលើសេចក្តីជំទាស់ថា ឲ្យត្រូវការស្តាប់ ឬក៏មិនស្តាប់សក្ខីកម្មតបទៅនឹងសំណួរនោះ។ យើងបានអនុវត្តដូចជាច្រើនខែមកហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំនឹងព្យាយាមរៀបសំណួរឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី នៅពេល សយ សែន បានឆ្លើយថាលោកនេះគឺជាអ្នកយាមដែលកាចសាវហាវនៅក្រាំងតាចាន់ តើចម្លើយរបស់គាត់នេះកុហក ឬក៏អត់ទេ?

[០៩:២៧:២៦]

**លោក ស្វូត្រ សាំង៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ក្នុងចម្លើយនេះ ខ្ញុំបើសិនជាជម្រាបលោក អស់លោកឲ្យដឹង ឲ្យយល់ត្រង់ថា បើសិនជាកាចសាហាវ ខ្ញុំកំណើតកើតជានៅឃុំលាយបូរ។ បើខ្ញុំកាចសាហាវក្នុងបច្ចុប្បន្នសព្វថ្ងៃ ខ្ញុំមិនអាចយកជីវិតទៅផ្ញើនៅជិតក្រាំងតាចាន់បានទេណ៎ា។ វាមានសាច់ញាតិបងប្អូនភូមិផងរបងមើលឃើញក្នុងហ្នឹង រហូតតាំងពីនោះ៧៩ មកដល់បច្ចុប្បន្នខ្ញុំមិនអាចទៅរស់នៅបានទេ បាទ។

**ស៖** បាទ ជាថ្មីម្តងទៀត ដើម្បីកុំឲ្យដដែលៗលោកដើមបណ្តឹងរដ្ឋប្បវេណី តើ សយ សែន កុហកតុលាការ ឬក៏អត់នៅពេលដែលគាត់ឆ្លើយថា លោក គឺជាអ្នកយាមដែលកាចសាហាវនោះ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីមិនបាច់ឆ្លើយតបនឹងសំណួរបែបនេះទេ! ការវាយតម្លៃភស្តុតាង និងទម្ងន់ភស្តុតាង ជាបន្ទុករបស់អង្គជំនុំជម្រះ។ យើងសូមប្រាប់លោកមេធាវីសាជាថ្មីម្តងទៀត ម្សិលមិញយើងបានប្រាប់លោកម្តងហើយ។ ថ្ងៃនេះ យើងប្រាប់សាជាថ្មីម្តងទៀត យើងសង្ឃឹមជឿជាក់ថាលោកមិនតាំងសំណួរបែប -- ប្រភេទបែបនេះទៀតទេទៅថ្ងៃមុខ។

[០៩:២៨:៥០]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ លោកប្រធាន សយ សែន <មិនត្រឹម>និយាយថា លោកគឺជាអ្នកដែលកាចសាហាវ<នោះទេ> គាត់<ក៏>និយាយរឿងរ៉ាវផ្សេងៗទៀតអំពីសកម្មភាពរបស់លោកនៅគុកក្រាំងតាចាន់។ ខ្ញុំនឹងអានសម្រង់មួយ<ទៀត>ចេញពីសក្ខីកម្មរបស់គាត់ គឺឯកសារ E1/257.1 ដែលបានឆ្លើយក្នុងរង្វង់ម៉ោងដប់<មួយ ដប់>ប្រាំបួន<នាទី>នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥។ <គេសួរ សយ សែន ថា៖>

"លោកដើមបណ្តឹងរដ្ឋប្បវេណី សំណួរដូចតទៅ៖ ឥឡូវនេះ យើងនឹងនិយាយអំពី សាំង ដែលលោកនិយាយថានៅរស់រានមានជីវិតនៅឡើយ។ គឺថាលោកបាននិយាយសំដៅទៅឈ្មោះ សាំង នេះជាច្រើនលើក ហើយបើខ្ញុំយល់មិនច្រឡំទេលោកបាននិយាយថា <នៅជាមួយនឹង>ឌុចតូច គឺថា<គាត់គឺ>ជាមនុស្សដ៏ព្រៃផ្សៃបំផុត តើបុគ្គលម្នាក់នេះ<គឺជាអ្នកដែល>លោក<កំពុង>និយាយ<មែនទេ>? សយ សែន ឆ្លើយថា៖ បាទ សាំង ហើយនិង ឌុច នេះ គឺជាមនុស្សកាចសាហាវព្រៃផ្សៃណាស់ ប៉ុន្តែ<ឈ្មោះស៊ីន>មិនកាចដូច ឌុចតូច ហើយនិង សាំង នេះទេ សម្រាប់អ្នកយាមដទៃទៀត។ កាលពីម្សិលមិញក៏ដូចជាព្រឹកនេះ សំណួរបានសួរទៅលោកទាក់ទងទៅនឹងការសម្លាប់កុមារីតូចៗពីរនាក់ ដែលលោកឆ្លើយថា ឌុចតូច គឺជាមនុស្សដែលបោកក្បាលកូនក្មេងទាំងពីរនាក់នេះទៅនឹងគល់ឈើ ហើយ<ស៊ីន>ជាអ្នក

សម្លាប់កុមារមួយទៀត, <តើអ៊ីចឹង ត្រឹមត្រូវដែរទេ?>។ ខ្ញុំចាំ មិនមែន សាំង ទេដែលបោកកូនក្មេងនុំង គឺ <ឈ្មោះ ស៊ីន>។ ក្រុមទាំងមូលគឺ ទៅសម្លាប់កូនក្មេងនេះ<រួមមាន>ឌុចតូច, <សាំង, ស៊ីន នេះឯង ជាអ្នកបោកសម្លាប់ក្មេងនេះ។ អ៊ីចឹង ក្រុមអ្នកសម្លាប់កុមារីពីរនាក់នោះមាន ឌុចតូច សាំង និង ស៊ីន។> សំណួរ៖ គឺអ្នកដែលសម្លាប់ក្បាលកូនក្មេងតូចទាំងពីរនាក់ហ្នឹងគឺ សាំង និង ស៊ីន អ៊ីចឹងមែនទេ? ឆ្លើយ៖ ក្មេងដែលមានអាយុបងហ្នឹងគឺ សាំង ជាអ្នកសម្លាប់ ហើយឯក្មេងតូចអាយុតិចជាងនោះគឺ ស៊ីន អ្នកសម្លាប់"។

លោកដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន នេះបានផ្ដល់នូវសក្ខីកម្មអំពីភាពកាចសាហាវទាក់ទងទៅនឹងអំពើរបស់លោកនៅឯគុកក្រាំងតាចាន់។ សូមលោកឆ្លើយ<តប>មើល៍ ឬក៏មានប្រតិកម្មយ៉ាងម៉េច? ខ្ញុំគ្រាន់តែសួរថា តើវាពិត ឬក៏មិនពិតទេ ដែលថាលោកបានចូលរួមពាក់ព័ន្ធក្នុងការសម្លាប់កុមារតូចៗពីរនាក់ហ្នឹង?

[០៩:៣១:៤១]

**លោក សូត្រ សាំង៖**

**ឆ៖** បាទ ក្នុងចម្លើយនេះខ្ញុំសូមបដិសេធ។ ខ្ញុំអត់បានសម្លាប់កូនក្មេងតូចៗ ក៏ខ្ញុំមិនបានធ្វើឃោរឃៅ សាហាវនៅក្នុងគុកហ្នឹងទេបាទ។

**ស៖** ចុះ ស៊ីន <និង>ឌុចតូច ហ្នឹង តើអ្នកទាំងពីរហ្នឹងពាក់ព័ន្ធនៅក្នុងការសម្លាប់កុមារីតូចៗទាំងពីរនាក់នេះដែរឬក៏អត់ទេ?

**ឆ៖** បាទ ក្នុង ឌុចតូច និង ស៊ីន ហ្នឹង ខ្ញុំអត់បានដឹងគោលការណ៍របស់គេទេ មិនដឹងគេសម្លាប់ម៉ោងណា ថ្ងៃណា ឆ្នាំណា ខ្ញុំអត់បានដឹងទេបាទ។

**ស៖** បាទ ប៉ុន្តែលោកឆ្លើយថា លោកខ្លួនឯងផ្ទាល់នៅពេលដែលលោកធ្វើការនៅក្រាំងតាចាន់ មិនដែលចូលពាក់ព័ន្ធក្នុងការសម្លាប់កុមារទាំងពីរនាក់នេះទេ។ តើលោកគឺជាត្រឹមត្រូវទេ?

**ឆ៖** បាទ ជាការពិតណាស់។

[០៩:៣៣:០៥]

**ស៖** បាទ ជាថ្មីម្ដងទៀត ខ្ញុំព្យាយាមសួរម្ដងទៀតលោកប្រធាន<។> ខ្ញុំរៀបចំសំណួរឲ្យបានត្រឹមត្រូវ។ លោកដើមបណ្ដឹងរដ្ឋប្បវេណីចម្លើយរបស់លោក<ពិតជា>ផ្ទុយគ្នាទៅនឹងចម្លើយរបស់ សយ សែន។ តើលោកកំពុងតែនិយាយការពិត ឬក៏អត់ដែលថា សយ សែន មិនបាននិយាយការពិតនោះទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លើសាក់៖**

នេះគឺជារបៀប<ដដែល>នៃការសួរសំណួរ <ដូចគាត់បានសួរពីមុនហ្នឹង គឺ>គាត់ព្យាយាមបញ្ចុះបញ្ចូលសាក្សីឲ្យនិយាយថា សាក្សីដទៃទៀតនិយាយកុហកតុលាការ គឺមិនប្រាប់ការពិតនោះទេ។ <សាក្សីបានឆ្លើយនឹងសំណួររួចទៅហើយ> មិន<ត្រូវណាសាក្សីរូបនេះមកកំណត់>លក្ខណៈសម្បត្តិ <ឬផ្ដល់មតិយោបល់>របស់<គាត់មកលើសក្ខីកម្មសាក្សីរបស់សាក្សី>ផ្សេងទៀត<បានឡើយ>។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំថានេះគឺការសួរបែបនេះគឺមានលក្ខណៈសមស្របហើយ។ ហើយដើមបណ្ដឹងរដ្ឋប្បវេណីក៏មានសិទ្ធិក្នុងការឆ្លើយតបទៅនឹងការឆ្លើយដាក់បន្ទុក <ឬសក្ខីកម្មបង្កព្យសនកម្ម>ណាមួយ <ដែរ>មកលើគាត់។ <ហើយសំណួរបន្តគឺ បើសិនណាគាត់ថា> សយ សែន <និយាយ>កុហក <ខ្ញុំនឹងសួរគាត់ថា ចុះហេតុអីបានជា> សយ សែន <មក>និយាយកុហក នៅចំពោះមុខតុលាការ<នេះ? អ៊ីចឹងទេ> សំណួរបែបនេះគឺសមស្របដែលអនុញ្ញាតឲ្យសួរបានហើយ។

**ប្រធានអង្គជំនុំ៖**

បាទ សំណួរបែបនេះសមស្របមិនចាំបាច់ឆ្លើយតបទេ។ ប្រភេទសំណួរដែលឲ្យសាក្សីវាយតម្លៃទៅលើភស្តុតាងដែលដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះបែបនេះ ដើមបណ្ដឹងរដ្ឋប្បវេណីមិនបាច់ឆ្លើយតបសំណួរនេះទេ។

អញ្ជើញចូលទៀតចុះ!

[០៩:៣៥:០៣]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងបន្តទៅមុខទៀតលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងពេលថ្មីៗនេះ លោកមានធ្លាប់ទៅជួប សយ សែន ហើយនិយាយជាមួយគាត់ពីបញ្ហាបន្តិចបន្តួចអីដែរឬទេ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក សូត្រ សាំង៖**

**ឆ៖** បាទ ក្នុងអំឡុង សយ សែន ខ្ញុំអត់បានជួបមុខនិយាយលេងសើចពីនេះពីនោះ ការងារអ្វីៗពីមុនដោយចាស់ដោយថ្មីក៏ដោយ។ ខ្ញុំសូមជម្រាបជូនលោកតុលាការ កាលពីថ្ងៃមួយ អំឡុងការកូនរបស់ សយ សែន ប៉ុន្តែ សយ សែន អត់បានមកជម្រាបប្រាប់ខ្ញុំទៅហែជំនូនកូនរបស់គាត់ទេ មានប្រពន្ធគាត់ ពីព្រោះ សយ សែន កាលពីមុនរស់នៅជិតផ្ទះខ្ញុំទេ ក្រោយមកគាត់បានទៅរស់នៅជាមួយប្រពន្ធក្រោយនៅបៀតអង្គតាសោមនោះ បើអ៊ីចឹងខ្ញុំអត់បានដែលបានទៅនិយាយជាមួយ សយ សែន យ៉ាងម៉េចមួយៗទេបាទ។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំនឹងអាននូវសម្រង់មួយ គឺឯកសារ E29/466, អង់គ្លេស មានលេខ <01066609>, ខ្មែរ 01072056, គឺខ្ញុំសូមដកស្រង់ដូចតទៅនេះ៖ "គឺថានៅក្នុងសក្ខីកម្មរបស់គាត់កាលពីខែកុម្ភៈ ឆ្នាំ២០១៥ លោក សយ សែន "បានជួបជាមួយនឹងលោក ហើយនិងលោកស្រី <> និងសាច់ញាតិរបស់លោក <ស្រី> ក្នុងពេលដែលផ្ដល់សក្ខីកម្មធម្មតា"។ លោក<សយបាន> និយាយថា "<លោកសូត្រ>មានការភ័យខ្លាច ហើយស្នើឲ្យលោក <សយ ប្រាប់>ថា<លោក>គឺជាជនរងគ្រោះ<ម្នាក់>។ <លោក សយ> និយាយថា គាត់<មិនមានអារម្មណ៍រងការគំរាមកំហែងពី> លោក <សាំង>នោះឡើយ ហើយ<លោក សយ បាននិយាយថា លោកស្រីក៏ទទួលរាក់ទាក់គាត់ ហើយ >សាច់ញាតិរបស់គាត់បានជួបស្វាគមន៍<គាត់ដែរ តែគ្រាន់តែមិនសូវជាស្និទ្ធស្នាលដូចពីមុនឡើយ>"។

លោកដើមបណ្ដឹងរដ្ឋប្បវេណី នេះគឺជារបាយការណ៍ដែលរៀបរាប់អំពីអ្វីដែលលោក សយ សែន បាន<ប្រាប់ទៅមន្ត្រីតុលាការនេះ> ដែលបញ្ជាក់ថាគាត់ក្នុងពេលថ្មីៗនេះ<ក្រោយពីសក្ខីកម្មរបស់គាត់> គឺ<គាត់>បានជួបជាមួយលោក <នឹងខុចតូច>។ តើវាជាការត្រឹមត្រូវដែរឬទេ ដែលលោកសយ សែន ទើបតែជួបលោកក្នុងពេលថ្មីៗនេះ?

[០៩:៣៨:១៨]

**ឆ៖** បាទ ដូចខ្ញុំជម្រាបជូនខាងដើមអ៊ីចឹង ខ្ញុំជាមួយ សយ សែន ខ្ញុំអត់បានដែលទំនាក់ទំនងតាំងពីមិនត្រឹមតែសព្វថ្ងៃនេះទេ តាំងពី៧៩ ខ្ញុំក៏មិនដែលទៅនិយាយលេងសើចជាមួយគាត់យ៉ាងម៉េចមួយៗ បើអ៊ីចឹង សយ សែន ចម្លើយ សយ សែន ទាំងអម្បាលម៉ាននេះ គឺខ្ញុំអត់ទទួលយកបានទេបាទ។

**ស៖** ដូច្នេះ បានន័យថា លោកក៏មិនដែលសុំគាត់ជាពិសេស ដែលសុំឲ្យគាត់រៀបរាប់ថាលោកជាជនរងគ្រោះ មិនមែនជាចារី។ តើអ៊ីចឹងមែនទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ក្នុងចំណុចនេះ សយ សែន ក៏ខ្ញុំអត់បានសុំ។ សយ សែន ក៏ខ្ញុំមិនដែលបាននិយាយទៅរកលេងសើចចង្វាក់អ្វីមួយ។ ដូចខ្ញុំជម្រាបថា ខ្ញុំអត់ដែលបានជួបនិយាយលេងសើចជាមួយ សយ សែន ទេ ដ្បិតតែផ្ទះខ្ញុំនៅជិតបាទ។

**ស៖** ដើម្បីឱ្យច្បាស់១០០ភាគរយ អ៊ីចឹងមានន័យថាលោកមិនដែលជួបជាមួយគាត់នៅក្នុងពេល ១ខែ ឬក៏១ខែកន្លះកន្លងមកហ្នឹង មិនដែលជួបនិយាយអំពីតួនាទីរបស់លោកថាជាជនរងគ្រោះ ឬក៏ <សាក្សី>អីនោះទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពីព្រោះខ្ញុំអត់ដែលបាននិយាយជាមួយ សយ សែន ហ្នឹងខ្ញុំម៉េចទទួលបានបាទ។

**ស៖** សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ ឥឡូវនេះ ខ្ញុំៗសូមនិយាយអំពីការចោទប្រកាន់ពីការធ្វើទារុណកម្ម<ក្នុង>ពេលសួរចម្លើយនៅក្រាំងតាចាន់។ ខ្ញុំចាំថា កាលពីម្សិលមិញលោកបាននិយាយអំពីហេតុការណ៍មួយ ដែលជាហេតុការណ៍បង្ហាញពីអ្នកសួរចម្លើយបានប្រើថង់ផ្លាស្ទិក ហើយយកថង់ផ្លាស្ទិកហ្នឹងទៅច្រកលើក្បាលអ្នកដែលត្រូវគេសួរចម្លើយនោះ។ ដូច្នេះ ខ្ញុំចង់សួរថាតើលោកឃើញហេតុការណ៍ហ្នឹងនៅពេលណាដែរ?

[០៩:៤១:០២]

**ឆ៖** បាទ ក្នុងច្រកចម្លើយថង់ផ្លាស្ទិក នៅអ្នកទោសក្នុងក្រាំងតាចាន់នេះ ពេលវៀងពេលខែឆ្នាំខ្ញុំមិនចាំទេ ប៉ុន្តែគ្រាន់ថាខ្ញុំចាំត្រង់ថាដល់ពេលខ្ញុំធ្វើបាយម្ដងម្កាល គេសួរចម្លើយ ខ្ញុំអាចឃើញក្នុងហ្នឹងបាទ។

**ស៖** ឥឡូវនេះ យើងនិយាយអំពីហេតុការណ៍មួយ ដែលលោកនិយាយថាលោកឃើញហេតុ-ការណ៍នេះកើតឡើង។ តើលោកចាំទេថាតើអ្នកទោស ឬក៏អ្នកដែលគសួរចម្លើយហ្នឹងជានរណាដែរ ជាស្ត្រី ឬក៏បុរស?

**ឆ៖** អ្នកទោសសួរចម្លើយហ្នឹង គឺជាបុរស បាទ។

**ស៖** តើអ្នកដែលសួរសម្លើយហ្នឹង ជាស្ត្រី ឬក៏បុរស?

**ឆ៖** បាទ អ្នកសួរចម្លើយ គឺប្រធានគុកគេហ្នឹងហើយបាទ។

**ស៖** ចុះអ្នកទោស អ្នកដែលគេសួរចម្លើយហ្នឹងជានរណាដែរ?

**ឆ៖** បាទ អ្នកទោសសួរចម្លើយនោះ ខ្ញុំបាទអត់ស្គាល់ឈ្មោះគាត់ទេ ហើយក៏មិនដឹងថាថ្ងៃខែឆ្នាំណា ម៉ោងណា ពេលណាបាទ ខ្ញុំអត់បានចាំទេបាទ។

**ស៖** អ៊ីចឹងលោកនិយាយថាអត់ស្គាល់ឈ្មោះគាត់ទេ។ អ៊ីចឹងបានន័យថា លោកមិនអាច<ដឹង> ថាអ្នកទោសជាស្ត្រី ឬក៏បុរសទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ស្ត្រីបុរសខ្ញុំបង្ហាញបាន ប៉ុន្តែគ្រាន់ថាឈ្មោះ និងថ្ងៃខែឆ្នាំ ដែលត្រូវសួរចម្លើយនោះ ខ្ញុំអត់ដឹងទេបាទ។

[០៩:៤៣:១៧]

**ស៖** ប្រហែលជាមានបញ្ហានៃការបកប្រែ។ លោកសាក្សីខ្ញុំចង់ដឹងថា តើអ្នកទោសដែលលោកឃើញហ្នឹង ជាស្ត្រី ឬក៏បុរស?

**ឆ៖** ចំពោះអ្នកទោសសួរចម្លើយនោះ គឺជាប្រុស មិនមែនជាបុរសទេ ថាប្រុសអ៊ីចឹងតែម្តងទៅបាទ ងាយយល់ជាង។

**ស៖** តើលោកចាំអំពីលក្ខណ: រូបរាង ឬក៏លក្ខណ:សម្គាល់អ្វីរបស់អ្នកទោសនោះដែរឬទេ?

**ឆ៖** បាទ ពីព្រោះរូបរាងកាយក្នុងអ្នកទោសនោះ ខ្ញុំមិនបានឃើញគាត់ទេ ប៉ុន្តែអ្នកទោសមិនដឹងថាប៉ុន្មាន ឬធំ មាឌហ្នឹង ខ្ញុំមិនចាំទេរឿងមាឌៗគាត់មិនដឹងទោះមាឌប៉ុន្មាន ប៉ុន្តែគ្រាន់តែសួរចម្លើយនៅក្នុងនោះមែន។

**ស៖** តើលោកអាចស្តាប់ឮសំណួរដែលគេសួរចម្លើយ តើលោកបានស្តាប់ឮថាតើអ្នកសួរចម្លើយហ្នឹងគេសួរអំពីអ្វីទៅអ្នកទោសនោះដែរឬទេ?

**ឆ៖** បាទ ក្នុងអ្នកសួរ និងអ្នកឆ្លើយក្នុងទីនោះខ្ញុំអត់បានឮទេ បាទ។

**ស៖** តើលោកដឹងថា ការសួរចម្លើយហ្នឹង ចំណាយពេលអស់ប្រហែលប៉ុន្មានម៉ោងដែរ នៅពេលដែលលោកឃើញហេតុការណ៍នោះ?

**ឆ៖** សួរក្នុងចម្លើយអ្នកទោសនោះ ខ្ញុំបើសិនជាគិតជាម៉ោង មិនដឹងជាម៉ោងប៉ុន្មានទៅម៉ោងប៉ុន្មានទេ ប៉ុន្តែគ្រាន់តែចាប់ពេលសួរប៉ុណ្ណឹង បើសិនជាខ្ញុំស្មាន ខ្ញុំមិនភ្លេចពេលធ្វើបាយទេ ប្រហែលជាម៉ោងដប់ ឬប្រហែលជាប៉ុណ្ណឹង។

[០៩:៤៥:៤៦]

**ស៖** លោកនិយាយថាការសួរចម្លើយហ្នឹងប្រហែលជាចាប់ផ្តើមនៅពេលព្រឹក។ តើអ៊ីចឹងមានន័យថា លោកស្មាន ឬមួយក៏លោកដឹងថា ពេលវេលាវាចាប់ផ្តើមនៅ<ម៉ោង១០:០០>?

**ឆ៖** អានេះខ្ញុំស្មានតែម៉ោងទេ ក៏ប៉ុន្តែអ្នកសួរចម្លើយគាត់នៅតែសួរដដែលក្នុងថ្ងៃពេលព្រឹកហ្នឹង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បាទ ប្រហែលជាម៉ោងដប់ទេ។

**ស៖** តើលោកចាំដែរឬទេថា តើអ្នកសួរចម្លើយហ្នឹងគេធ្វើអ្វី? តើគេធ្វើយ៉ាងម៉េចជាមួយថង់ផ្លាស្ទិកហ្នឹង? តើគេប្រើថង់ផ្លាស្ទិកហ្នឹងដើម្បីធ្វើអីដែរ? លោកចាំទេ?

**ឆ៖** បាទ ថង់ផ្លាស្ទិកហ្នឹង ខ្ញុំស្មានទេ ខ្ញុំមិនឃើញផ្ទាល់ទេ ពីព្រោះថង់ផ្លាស្ទិក អាន ប្រាប់ថាកំណាត់កន្ទ្រែងភ្លៀងទទូរយើងហ្នឹង គេយកទៅរុំក្បាលគាត់ឲ្យថប់ដង្ហើម ដើម្បីឲ្យអ្នកទោសឆ្លើយបាទ។

**ស៖** នៅពេលដែលលោកនិយាយថា "ខ្ញុំស្មាន" អ៊ីចឹង តើលោកចង់មានន័យយ៉ាងម៉េចដែរ? តើលោកបានឃើញផ្ទាល់ ឬក៏លោកមិនបានឃើញផ្ទាល់ទេ ទើបលោកនិយាយថា "តាមខ្ញុំស្មាន" នោះ?

**ឆ៖** អានេះបើតាមឃើញ វាគ្រាន់តែឃើញពីចម្ងាយ មិនមែនយើងទៅចូលផ្ទាល់នឹងភ្នែកទេ។ អានេះជាការស្មានរបស់ខ្ញុំបាទ។

**ស៖** អ៊ីចឹង លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកចង់ផ្ដល់សក្ខីកម្មថាលោកមិនប្រាកដថាតើអ្នកសួរចម្លើយហ្នឹងប្រើប្រាស់ថង់ផ្លាស្ទិកដាក់អ្នកដែលត្រូវគេសួរចម្លើយហ្នឹង។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំទទួលស្គាល់ ពីព្រោះឃើញគេរុំកំណាត់ផ្លាស្ទិកហ្នឹង រុំមែន។ ក៏ប៉ុន្តែត្រង់ថារុំយ៉ាងម៉េច មួលយ៉ាងម៉េចនោះ ខ្ញុំមិនបានទៅដល់ទេបាទ។

[០៩:៤៨:៣០]

**ស៖** តើលោកឃើញហេតុការណ៍ហ្នឹងតែម្ដង ឬក៏លោកឃើញហេតុការណ៍ហ្នឹងច្រើនដង?

**ឆ៖** ពីព្រោះហេតុការណ៍នេះ ខ្ញុំឃើញតែម្ដងទេ។ ពេលអំឡុងតែខ្ញុំធ្វើបាយតែប៉ុណ្ណឹងទេ បាទ។

**ស៖** ដើម្បីឲ្យប្រាកដ អ៊ីចឹងលោកឃើញតែម្ដងទេ មិនមែនឃើញច្រើនដងទេ។ ប៉ុន្តែ ក្នុងពេលកន្លងមកហ្នឹង ខ្ញុំឮពាក្យថាលោកឃើញច្រើនដង។ តើលោកប្រាកដទេថាលោកឃើញតែម្ដងហ្នឹង?

**ឆ៖** ខ្ញុំបាទឃើញម្ដងទេ វាច្រើនដងទៅមុខយ៉ាងម៉េចទៀតខ្ញុំអត់ដឹងទេ ប៉ុន្តែអំឡុងដែលខ្ញុំធ្វើបាយ ដែលខ្ញុំឃើញហ្នឹង ពេលអំឡុងខ្ញុំដែលធ្វើបាយនៅមន្ទីរនោះតែម្ដងហ្នឹងបាទ តែទៅមុខទៀតយ៉ាងម៉េច ប្រើរបៀបរបបហ្នឹងទៀត ខ្ញុំអត់ដឹងទេបាទ។

**ស៖** តើលោកចាំទេថាលោកធ្លាប់និយាយជាមួយអ្នកឆ្មាំគុកដទៃទៀតអំពីហេតុការណ៍ដែលលោកឃើញហ្នឹងទេ? តើលោកមានធ្លាប់និយាយគ្នាដែរទេ?

**ឆ៖** ក្នុងនោះ ខ្ញុំអត់បាននិយាយជាមួយអ្នកឆ្មាំគុកដទៃទៀតទេ ត្រង់ការងារហ្នឹងរបស់ការងារឃើញយ៉ាងម៉េចជារឿងរបស់បុគ្គលឃើញ វាអត់មានយកទៅផ្សព្វផ្សាយប្រាប់ពីមួយទៅមួយថា អ្នកនេះ

អ៊ីចេះ អ្នកនោះអ៊ីចុះ គឺគ្មានទេបាទ។

[០៩:៤៩:៥១]

**ស៖** តើលោកចាំទេថា ធ្លាប់មានអ្នកយាមផ្សេងទៀតប្រាប់លោកថា គេបានឃើញហេតុការណ៍ ឬក៏អាចថាហេតុការណ៍ធ្វើទារុណកម្ម។ តើអ្នកយាមផ្សេងទៀត ធ្លាប់ប្រាប់លោកដែរទេ?

**ឆ៖** បាទក្នុងទីនោះ គឺគ្មានអ្នកណាប្រាប់អ្នកណាទេ ពីព្រោះដឹងថាម្នាក់ៗវា ដឹងថាគេផ្លូវហ្នឹងទៅហើយ យើងអត់មានទៅសួរសាកគ្នាថា ហេ! អែ្នងឃើញគេធ្វើអ៊ីចេះ អែ្នងធ្វើអ៊ីចុះ។ អាហ្នឹងបើឃើញក៏ឃើញ បើមិនឃើញ អត់ ជារឿងបុគ្គលផ្សេងគ្នាបាទ។

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវនេះ ខ្ញុំចង់សួរសំណួរផ្សេងមិនពាក់ព័ន្ធទៅនឹងការសួរចម្លើយទេ ប៉ុន្តែខ្ញុំចង់សួរលោកអំពីការ<ចោទប្រកាន់>សម្លាប់មនុស្ស នៅក្នុងបរិវេណក្រាំងតាចាន់។ លោកបានផ្តល់សក្ខីកម្មច្បាស់<ហើយ>ថា លោកមិនដែលចូលរួមនៅក្នុងការសម្លាប់មនុស្សទេ គឺមិនដែលចូលរួមក្នុងការសម្លាប់អ្នកទោស។ ប៉ុន្តែកាលពីម្សិលមិញ លោកបានផ្តល់សក្ខីកម្មថា ហើយលោកបានប្រើពាក្យមួយ <ខ្ញុំសូមប្រើពាក្យស្រួលនិយាយ គឺឃើញមួយប៉ប្រិចភ្នែកនៃការសម្លាប់។ សូមលោកនិយាយឲ្យច្បាស់ជាងនេះបន្តិចមើល៍? តើលោកបានឃើញការសម្លាប់មួយប៉ប្រិចភ្នែកនេះនៅពេលណា?>

[០៩:៥២:០៦]

**ឆ៖** បាទ ក្នុងការណ៍ ខ្ញុំឃើញសម្លាប់មនុស្សក្នុងក្រាំងតាចាន់នេះ មិនមែនឃើញថា អូ៎! ឃើញតែមួយភ្លែត ពីព្រោះរាប់ឆ្នាំ បានៗន័យថារាប់ឆ្នាំហ្នឹងវាមិនមែនថា អង្គុយចាំនៅតែកន្លែងហ្នឹងមួយកន្លែងទេបាទ ពីព្រោះខ្ញុំមានគេប្រើទៅរកម្ហូប ទៅធ្វើបាយ ទៅស្ទូង ទៅដក ធ្វើជីតាមវេនរបស់ខ្លួនបាទ។

**ស៖** តើលោកអាចបញ្ជាក់ឲ្យច្បាស់បានទេថា នៅពេលដែលលោកឃើញមួយភ្លែត ថាតើលោកឃើញត្រឹមតែមួយវិនាទី<>ឬក៏ឃើញមួយនាទី? តើលោកមានន័យម៉េចដែរ ដែលលោកនិយាយថាឃើញមួយប៉ប្រិចភ្នែក ឃើញមួយភ្លែតនោះ?

**ឆ៖** ក្នុងអ្នកសម្លាប់ មិនមែនមួយភ្លែតសម្លាប់ហើយទេ។ សូមជម្រាប ថាអ្នកសម្លាប់នេះ មិនមែនយើងទៅអង្គុយមើល ឬមួយទៅអង្គុយចោងហោងអង្គុយតែមើលគេ គឺមិនមែនទេ បាទ។ ឃើញ រយៈពេល -- ក្នុងរយៈពេលមួយខ្ញុំ ដូចឧទាហរណ៍ថាខ្ញុំធ្វើបាយ ខ្ញុំសូមជម្រាបថា ខ្ញុំពេលខ្ញុំធ្វើបាយអ៊ីចឹងគេសម្លាប់។ ពេលដែលថ្ងៃគេសម្លាប់ ជារឿងរបស់គេសម្លាប់។ ខ្ញុំធ្វើបាយដឹងតែពីធ្វើបាយទេបាទ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:៥៣:៣៨]

**ស៖** តាមការបកប្រែជាភាសាអង់គ្លេសឲ្យខ្ញុំស្តាប់ លោកនិយាយថា ខ្ញុំ -- លោកជឿថាលោក <បាន>ឃើញមានការសម្លាប់។ តើលោកនិយាយថាលោកជឿជាក់ថាលោកឃើញមានការសម្លាប់ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ជាការពិត ឃើញសម្លាប់មែន។

**ស៖** តើលោកអាចបញ្ជាក់ឲ្យបានលម្អិតបានទេលោកដើមបណ្តឹងរដ្ឋប្បវេណី? ថាតើគេសម្លាប់អ្នកណាដែរ? គេសម្លាប់អ្នកទោស ឬក៏គេសម្លាប់អ្នកទោសច្រើននាក់? តើអ្នកទោសដែលគេសម្លាប់នុ៎ងស្រី ឬក៏ប្រុស? តើលោកអាចបញ្ជាក់ឲ្យបានលម្អិតបន្តិចបានទេទៅលើចំណុចនេះ?

**ឆ៖** បាទ ក្នុងអ្នកទោសស្រីប្រុសដែលយកទៅសម្លាប់គឺមានពិតមែន។ ក្នុងទីនោះ មានស្រីមានប្រុស បាទ។

**ស៖** ខ្ញុំមិនចង់ឲ្យលោកនិយាយជាទូទៅទេ ខ្ញុំចង់សួរលោកអំពីព័ត៌មានលម្អិតដែលលោកនិយាយថាឃើញមួយភ្លែត ឃើញមួយប៉ប្រិចភ្នែកនៃការសម្លាប់មនុស្សហ្នឹង។ តើលោកឃើញមួយភ្លែតនុ៎ងលោកឃើញគេសម្លាប់អ្នកទោសម្នាក់ ពីរនាក់ បីនាក់? ហើយថាតើលោកឃើញមួយប៉ប្រិចភ្នែកហ្នឹងតើអ្នកដែលឃើញ លោកឃើញគេសម្លាប់ហ្នឹង ស្រី ឬក៏ប្រុស? <សូមនិយាយឲ្យបានលម្អិតបន្តិចមើល៍?>

[០៩:៥៥:១៤]

**ឆ៖** បាទ កាលនោះ ខ្ញុំឃើញសម្លាប់នោះគឺប្រុសទេបាទ។

**ស៖** អ៊ីចឹងមានន័យថាលោកឃើញមនុស្សប្រុសម្នាក់ត្រូវគេសម្លាប់។ តើលោកចង់និយាយអ៊ីចឹងមែនទេ?

**ឆ៖** បាទៗ។

**ស៖** តើលោកអាចរៀបរាប់ពីលក្ខណៈរបស់បុរសម្នាក់នុ៎ងបានទេ តើបុរសនុ៎ងជាមនុស្សប្រុសក្មេង ឬក៏ចាស់ មាឌតូច ឬក៏មានធំ? លោកស្គាល់ឈ្មោះមនុស្សប្រុសម្នាក់នោះទេ?

**ឆ៖** បាទ ក្នុងការសម្លាប់នោះ កាលពីមុនឡើយយុទ្ធជនគាត់មកពី -- នៅកងទ័ពទេ ប៉ុន្តែគាត់រត់ចោលជួរ គាត់ខុសអ្វីៗ ខ្ញុំអត់ដឹងទេ។ ប៉ុន្តែយុទ្ធជន កាលហ្នឹងនៅកងជាមួយខ្ញុំ នៅកងស្រុកត្រាំកក់ តែគាត់រត់ចោលជួរយ៉ាងម៉េច ស្លាប់ យកលួចអ្វីក្នុងរឿងរបស់គាត់ ខ្ញុំអត់ដឹងទេបាទ។

**ស៖** អ៊ីចឹងតើលោកអាចប្រាប់ឈ្មោះគាត់បានដែរឬទេ? ឬលោកស្គាល់ឈ្មោះគាត់ទេ?

**ឆ៖** បាទ ឈ្មោះគាត់ហ្នឹងកាលពីក្នុងសម័យធ្វើសង្គ្រាមជាមួយ លន់ នល់ កាលនោះគាត់ឈ្មោះ បង – បងជោ ត្រូវជាកូន យាយណាំ នេះ។

[០៩:៥៦:២៩]

**ស៖** តើលោកអាចប្រាប់បានទេថា ហេតុការណ៍ហ្នឹងកើតឡើងនៅប្រហែលជាពេលណាដែរ?

**ឆ៖** បាទ ហេតុការណ៍កើតឡើងនៅក្នុងប្រហែលជាម៉ោង ខ្ញុំមិនចាំច្បាស់ទេ ក្នុងប្រហែលជាថ្ងៃរសៀល មិនដឹងម៉ោងបី ឬម៉ោងពីរទេបាទ ក្រៅពីហ្នឹងខ្ញុំមិនបានចាំច្បាស់អស់ទេ។ ប៉ុនព្រោះកាលហ្នឹង ខ្ញុំគេឲ្យមកយាមនៅខាងកើតនេះ ប៉ុន្តែដល់ខ្ញុំចូលវិញហ្នឹង វាបាត់ តាជោហ្នឹង។ បាត់ តាជោ គឺបាត់ទៅ គ្រាន់តែថាវាយកទៅសម្លាប់ត្រង់ណា នៅត្រង់ណា ខ្ញុំអត់ដឹងទេបាទ។

**ស៖** ឥឡូវខ្ញុំវង្វេងហើយលោកដើមបណ្ដឹងរដ្ឋប្បវេណី។ តើលោកចង់និយាយថាមនុស្សម្នាក់នេះដែលលោកនិយាយថាលោកឃើញគេសម្លាប់នោះ? ការពិតទៅ<>ប៉ុន្តែឥឡូវលោកថា លោកឃើញគេយកទៅបាត់ ហើយលោកអត់<ឃើញការ>សម្លាប់<ផង>។ តើលោកចង់និយាយមានន័យម៉េចដែរ?

**ឆ៖** ខ្ញុំក្នុងការស្មានក្នុងចិត្តរបស់ខ្ញុំគឺ បងជោ ហ្នឹងគាត់មុននឹងសម្លាប់ គេឲ្យខ្ញុំទៅយាមខាងក្រៅ តែដល់ពេលបាត់ តាជោ ហ្នឹង ដល់ខ្ញុំចូលមកវិញបាត់ តាជោ ហ្នឹងខ្ញុំស្មានក្នុងចិត្តខ្លួនខ្ញុំថា ពិតគេសម្លាប់ហើយ តែមិនដឹងថាគេសម្លាប់នៅជង្ហុកណា ឬមួយត្រង់ណាទេបាទ។

[០៩:៥៩:០២]

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងពេលមុននេះ យើងនិយាយអំពីកាលដែលលោកឃើញមួយភ្លែត លោកឃើញមួយប៉ប្រិចភ្នែកនេះ។ ដូច្នេះខ្ញុំចង់ដឹងថា លោកពិតជាបានឃើញផ្ទាល់ភ្នែកអំពីការសម្លាប់មនុស្ស<ប្រុសនោះទេ?> គឺថាលោកបានឃើញថាមនុស្សម្នាក់ហ្នឹងត្រូវគេវ៉ៃ ឬក៏គេសម្លាប់ហើយ តើលោកបានឃើញគាត់ដួលដេកទៅលើដី ឬមួយក៏លោកមិនបានឃើញហេតុការណ៍ទាំងអស់នេះទេ?

**ឆ៖** បាទ ហេតុការណ៍ឃើញទាំងអស់នេះ ខ្ញុំអត់បានឃើញទេ ពីព្រោះមិនដឹងគេវ៉ៃដំបងគល់ឫស្សី ឬមួយត្បូងចងទេ គឺអត់បានឃើញត្រង់ថាវ៉ៃទេ ប៉ុន្តែគ្រាន់ថា ខ្ញុំដឹងថាបាត់ឈ្មោះ បងជោ នេះ។

**ស៖** អ៊ីចឹងខ្ញុំអាចសង្ខេបបន្តិចសិនថានៅពេលដែលលោកនិយាយថា ឃើញការសម្លាប់មួយប៉ប្រិចភ្នែក គឺតាមពិតទៅ គឺលោកបានឃើញ តើលោកអាច -- តើអាចនិយាយបានទេថាការដែល

លោកបានឃើញមួយប៉ប្រិចភ្នែកពីការសម្លាប់នោះ គឺលោក<មិន>បានឃើញ<សកម្មភាព>សម្លាប់ដោយផ្ទាល់ភ្នែក។ តើអ៊ីចឹងមែនទេ?

**ឆ៖** ក្នុងវ៉ៃនិងសម្លាប់ផ្ទាល់ភ្នែកតែម្តងនេះ ខ្ញុំអត់បានឃើញទេ ប៉ុន្តែថា គ្រាន់តែខ្ញុំដឹងថាអង្កាល់ពីមុនខ្ញុំចេញទៅយាមខាងក្រៅ ឈ្មោះ បងជោ គាត់នៅ តែដល់ពេលក្រោយហើយ ដល់ល្ងាច ដល់ពេលរៀបរាប់អ្នកទោសចប់សព្វគ្រប់ ឲ្យប្រធានគេ វាបាត់ឈ្មោះ តាជោ ហ្នឹង។ ខ្ញុំដឹងស្មានក្នុងចិត្តរបស់ខ្លួនខ្ញុំទេ ខ្ញុំថា តាជោ កូនឃាយណាំ នេះពិតជាគេសម្លាប់ចោលហើយ។

[១០:០១:២៣]

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី អ្វីដែលលោកបាននិយាយថាឃើញមួយភ្លែត ឬក៏ស្អីហ្នឹងកន្លងមកហ្នឹង តើលោកអាចនិយាយបានទេថា <វាជាពេលតែម្តងគត់ ដែល>លោក<>បានឃើញការសម្លាប់មនុស្សនោះ?

**ឆ៖** ក្នុងការបានឃើញមួយប៉ប្រិចភ្នែក ខ្ញុំបាទអត់បានឃើញទេ មួយប៉ប្រិចភ្នែកនោះ ប៉ុន្តែគ្រាន់តែខ្ញុំដឹងថា តាជោ ហ្នឹងគេសម្លាប់។ ខ្ញុំដឹងថា តាជោ ហ្នឹងគេសម្លាប់ហើយ ថ្ងៃហ្នឹង តែមិនដឹងគេសម្លាប់ដោយវិធីសាស្ត្រអ្វី វ៉ៃអ្វីមួយ ឬមួយវ៉ៃដំបង ឬមួយគល់ឫស្សី ខ្ញុំអត់បានទៅឃើញទេបាទ។

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវនេះ ខ្ញុំចង់សួរលោកពីសំណួរទាក់ទងទៅនឹងអំពើដទៃទៀត គឺអំពើនៃការសម្លាប់។ <ខ្ញុំ>ចង់ដឹងថា<តើ>លោកមានពាក់ព័ន្ធ ឬក៏អត់នោះ។ លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកធ្លាប់និយាយ ឬក៏ធ្លាប់ជជែកជាមួយអ្នកទោសមុនពេល<គេយកគាត់ទៅ>សម្លាប់ ឬក៏មុនពេល<ពួកគាត់>បាត់ខ្លួនដែរឬទេ ឬមួយក៏ថាលោកមិនដែលនិយាយ ឬក៏ជជែកជាមួយអ្នកទោសមុនពេលដែលគេយកទៅសម្លាប់ ឬក៏មុនពេលដែលពួកគាត់បាត់ខ្លួននោះទេ?

**ឆ៖** បាទ ក្នុងនោះ គឺជជែកជាមួយអ្នកទោសថា មុននឹងគាត់បាត់ខ្លួននោះឲ្យខ្ញុំទៅជជែកអ្វីមួយក្នុងនោះ គឺអត់មានបានទៅជជែកជាមួយអ្នកទោសទេបាទ។

**ស៖** តើលោកដែលធ្លាប់ដោះខ្នោះជើងអ្នកទោសមុនពេលដែលគេបញ្ជូនអ្នកទោសទៅក្រៅ ឬក៏មុនពេល ប្រហែលជាគេសម្លាប់<ពួក>គាត់<?>

[១០:០៣:៣៧]

**ឆ៖** បាទ ពីព្រោះក្នុងគុកនីមួយៗ គឺមានម៉ោងរបស់គេ។ បាទ មានម៉ោងដូចថា អារឿងចូលមកប៉ុន្មាន ចេញទៅប៉ុន្មាន យើងរាយការណ៍ឲ្យមន្ទីរគេបាទ។ បើអ៊ីចឹងយើងត្រូវដឹងថាអ្នកទោសក្នុង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហ្នឹង ក្នុងយប់ហ្នឹងនៅប៉ុន្មាន ក្នុងថ្ងៃហ្នឹងមានប៉ុន្មាន អាហ្នឹងយើងរាយការណ៍ជូនមន្ទីរគេ ព្រោះតួនាទីគេត្រួតពិនិត្យនៅលើ តាមឿន គេជាអ្នកចុះត្រួតពិនិត្យផ្ទាល់។

**ស៖** អ៊ីចឹងខ្ញុំ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ដែលថាលោក ហើយនិងអ្នកយាមដទៃទៀតជាទូទៅគឺទទួលខុសត្រូវលើការ<ដាក់>ខ្នោះ និងដោះខ្នោះអ្នកទោស។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ មិនមែនដាក់ខ្នោះអ្នកទោស គឺមិនមែនតែខ្ញុំម្នាក់ទេ។ វាទូទៅក្នុងកន្លែងនោះ គឺពេលវេលាដែលត្រូវគេយកចូលមក យើងត្រូវតែដាក់ខ្នោះ។ បញ្ហាដាច់ខាតត្រូវតែដាក់ខ្នោះ ពីព្រោះបើមិនដាក់ខ្នោះក្រែងលោអ្នកទោសរត់រួចទៅ ជិវិតរបស់ខ្ញុំបាទហ្នឹងគឺត្រូវតែស្លាប់តែម្តង។

[១០:០៥:០២]

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកធ្លាប់បានឃើញ សយ សែន ដាក់ខ្នោះ ឬក៏ដោះខ្នោះជើងអ្នកទោសទេ?

**ឆ៖** បាទ ពីព្រោះចំពោះ សយ សែន នេះខ្ញុំមិនបានពិនិត្យទេ ពីព្រោះ សយ សែន គាត់ការងារខាងក្នុងហ្នឹង គឺគាត់រ៉ាប់រងទាំងអស់ក្នុងនោះបាទ។

**ស៖** ប៉ុន្តែគាត់មិនបានដាក់ ឬក៏ដោះខ្នោះជើងអ្នកទោសទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ចំពោះក្នុងនោះត្រង់ដាក់ក៏ខ្ញុំអត់បានទៅដឹងដែរ រឿងដោះក៏ខ្ញុំអត់បានដឹងដែរបាទ។

**ស៖** សំណួររបស់ខ្ញុំថា តើលោកធ្លាប់ដែលបានឃើញ សយ សែន ដោះខ្នោះជើង ឬក៏ដាក់ខ្នោះជើងអ្នកទោសទេ?

**ឆ៖** ក្នុងនោះ ខ្ញុំជម្រាបជូនថា ខ្ញុំអត់បានដឹងថា ដឹង ឃើញដោះ ខ្ញុំអត់បានឃើញទេ។ ហើយដោះក៏ខ្ញុំអត់ដឹងថា សយ សែន ហ្នឹងគាត់ដោះអ្នកទោសដែរបាទ។

**ស៖** តើលោកធ្លាប់រាប់ចំនួនអ្នកទោសទេ មុននឹងគេយកអ្នកទោសទៅសម្លាប់ ឬក៏លោកធ្លាប់រាប់ចំនួនសាកសពអ្នកទោសដែរទេ ក្រោយពីគេសម្លាប់ហើយ?

**ឆ៖** បាទ ក្នុងចំនួនអ្នកទោស ខ្ញុំបាទមិនបានដឹងចំនួនប៉ុន្មាន សម្លាប់ប៉ុន្មាន ថ្ងៃណា ខែណា ឆ្នាំណា សម្លាប់ប៉ុន្មានៗ ខ្ញុំអត់បានដឹងទេបាទ ប៉ុន្តែដឹងថាកន្លែងហ្នឹង គេសម្លាប់។

**ស៖** សូមរៀបសំណួរ<>ខ្ញុំឡើងវិញ។ <លោកដើមបណ្តឹងរដ្ឋប្បវេណី> តើលោកធ្លាប់រាប់ចំនួនសពអ្នកទោសដែលគេសម្លាប់នៅក្នុងបរិវេណ<>ក្រាំងតាចាន់ដែរទេ? ឧទាហរណ៍ រាប់ថា មួយ ពីរ បី បួន អ៊ីចឹងទៅ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ នេះក្នុងរាប់ចំនួន មួយ ពីរ បី បួន នេះរាប់តែពេលប្ដូរយាមទេបាទ។ ប្ដូរយាមយប់គឺត្រួតពិនិត្យជាអចិន្ត្រៃយ៍ ក្នុងវេននីមួយៗបាទ។

[១០:០៧:៥៣]

**សៈ** លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកធ្លាប់ដែលឃើញ សយ សែន រាប់ចំនួនសាកសពអ្នកទោសនៅក្នុងបរិវេណគុកក្រាំងតាចាន់ហ្នឹងដែរទេ?

**ឆ៖** បាទ ក្នុងនោះ ខ្ញុំអត់បានឃើញ សយ សែន គាត់ចូលទៅរាប់អ្នកទោសទេ ឃើញតែពួកមន្ទីរ និងពួកទ័ពយាមហ្នឹងទេបាទ។

**សៈ** បាទ ខ្ញុំយល់ សំណួររបស់ខ្ញុំសួរអ៊ីចេះទេ តើលោកធ្លាប់ដែលបានឃើញ សយ សែន នេះរាប់សាកសព រាប់ខ្មោចអ្នកទោស ដែលគេបានទើបតែបានសម្លាប់ហើយដែរទេ?

**ឆ៖** បាទ ក្នុងនោះខ្ញុំអត់បានឃើញគាត់រាប់ទេបាទ។

**សៈ** លោក ឬក៏អ្នកយាមជាមួយលោកធ្លាប់ដែលបានជីករណ្ដៅ ដែលត្រូវប្រើប្រាស់ដើម្បីកប់សាកសពអ្នកទោស<ដែរទេ>?

**ឆ៖** បាទ ពីព្រោះអ្នកយាមជាមួយខ្ញុំតែដល់ពេលគេ វគ្គមួយៗគេមិនប្រាប់ពួកទ័ពទេ ប្រាប់គ្រាន់តែថា ឥឡូវពួកកងទ័ព យុទ្ធជនទាំងអម្បាលម៉ាន គឺមានខ្លួនត្រៀមតាមមុខសញ្ញារៀងខ្លួន កុំឲ្យពេលវេលាហួសពេលហួសម៉ោង ដល់ម៉ោងចូលមកវិញ។ បាទមានតែប៉ុណ្ណឹងទេ ត្រង់ថាជីកជង្ហុក កាប់រណ្ដៅ ឬមួយសាកសពទៅវ៉ៃទៅសំពង អាហ្នឹងជារឿងរបស់គេទេបាទ។

**សៈ** តើលោក ឬក៏អ្នកយាមជាមួយលោកនេះធ្លាប់បានដោះយកខោអាវចេញពីសាកសពអ្នកទោសនៅបរិវេណក្រាំងតាចាន់ដែរទេ?

[១០:១០:០៦]

**ឆ៖** បាទ ចំពោះខោអាវខ្ញុំអត់បានទៅដោះ ទៅទាញយកពីអ្នកទោសទេបាទ។

**សៈ** ចុះអ្នកយាមជាមួយលោកហ្នឹង គេធ្លាប់បានដោះខោអាវចេញពីសាកសពអ្នកទោសទេ?

**ឆ៖** ក្នុងនោះ ខ្ញុំជារឿងអ្នកយាម អាហ្នឹងជារឿងរបស់គេផ្សេងខ្ញុំអត់បានឃើញទេបាទ។

**សៈ** តើលោកធ្លាប់ដែលបានឃើញ សយ សែន ដោះខោអាវចេញពីខ្លួនសាកសពអ្នកទោសក្រោយពីគេសម្លាប់<ភ្លាមៗទេ>?

**ឆ៖** បាទ ចំពោះ សយ សែន ក៏ដូច្នេះដែរ ខ្ញុំអត់បានឃើញគាត់ទៅសម្រាតសម្លៀកបំពាក់ ខោ

អាវសាកសពទេ បាទ។

**ស៖** តើ<>លោកហើយនិងអ្នកយាមជាមួយលោក<>ធ្លាប់ៗអូសសាកសពអ្នកទោសដែលគេសម្លាប់ហើយទេ?

**ឆ៖** បាទ ពីព្រោះខ្ញុំអត់បានដែល អ្នកយាមជាមួយខ្ញុំ មិនដឹងខ្ញុំក៏អត់ដែលបានទៅអូសសាកសពជាមួយគាត់ដែរបាទ។

**ស៖** តើលោកធ្លាប់ដែលបានឃើញ សយ សែន អូសឬក៏សែងសាកសពអ្នកទោសដែលគេបានសម្លាប់ហើយនោះទេ?

**ឆ៖** បាទ រឿងសយ សែន ខ្ញុំអត់បានដឹង មិនបានដឹងគាត់អូសសាកសព ឬមួយគេប្រើនៅពេលណាម៉ោងណាដែរ ខ្ញុំអត់បានដឹងទេបាទ ជាមួយ សយ សែន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់សាមសិបនាទី ក៏សូមចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញ ដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញមកកាន់កន្លែងផ្ដល់សក្ខីកម្មរបស់សាក្សីនៅវេលាម៉ោងមួយ -- ម៉ោងដប់និងសាមសិបនាទី។ ហើយចំណែកបែបបទក្នុងការចេញចូលយើងបានប្រាប់រួចហើយ គឺរបៀបរបបនៃការរូតរាំងននដូចអនុវត្តដូចកាលម្សិលមិញ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៣ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:៣០:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាទៅក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងដល់ភាគីពាក់ព័ន្ធអំពីកិច្ចដំណើរការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 នៅចំពោះមុខអង្គជំនុំជម្រះដែលត្រូវបានធ្វើឡើងអសាធារណៈមួយផ្នែក។ បន្ទាប់មកសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះត្រូវបានផ្អាករង់ចាំសេចក្តីសម្រេចពីអង្គជំនុំជម្រះទៅលើសំណើសុំវិធានការការពារ ដែលបានស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដែលរួមមានការធ្វើសវនាការស្តាប់សក្ខីកម្មដែលនៅសេសសល់របស់គាត់ជាអសាធារណៈ និងរៀបចំធ្វើរបាយការណ៍វាយតម្លៃដោយអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ។

របាយការណ៍វាយតម្លៃរបស់អង្គភាពគាំពារសាក្សីនិងអ្នកជំនាញ ឯកសារE29/461 បានចង្អុលបង្ហាញថាដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271 បានសម្រេចដកសំណើសុំវិធានការការពាររបស់ខ្លួនវិញ បន្ទាប់ពីមានការដកសំណើសុំធ្វើសវនាការជាអសាធារណៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271។ ការធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ នឹងធ្វើជាសាធារណៈបន្ទាប់ពីបញ្ចប់ការធ្វើសក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-304 នៅចំពោះមុខអង្គជំនុំជម្រះ។ សេចក្តីសម្រេចនេះ មិនប៉ះពាល់ទៅនឹងការណែនាំពីមុនអង្គជំនុំជម្រះពាក់ព័ន្ធនឹងនីតិវិធីសវនាការលើភស្តុតាងទាក់ទងនឹងជនរងគ្រោះនៃការបៀតបៀនលើផ្លូវភេទនោះទេ។

ហើយក៏សូមជម្រាបជូនទៅខាងក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ផងដែរថា កាលពីព្រឹកមិញអង្គជំនុំជម្រះថា ពិភាក្សាលើបញ្ហាសំណើសុំរបស់ក្រុមមេធាវីការពារក្តីពាក់ព័ន្ធនឹងនីតិវិធីនៃការដាក់បង្ហាញឯកសារដែលក្រុមមេធាវីមានបំណងដាក់។ ហើយឥឡូវនេះ អង្គជំនុំជម្រះសម្រេចដូច្នេះហើយ ហើយបើសិនបើមានសំណើសុំយ៉ាងណាពាក់ព័ន្ធនឹងបញ្ហាស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-271នៅរសៀលនេះនោះ សុំលើកឡើងជាសំណើផ្ទាល់មាត់ដើម្បីស្តាប់ភាគីពាក់ព័ន្ធមុននឹងអង្គជំនុំជម្រះសម្រេចលើបញ្ហានេះ។

បាទជាបន្តនេះ ផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

[១០:៣៤:១៥]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ខ្ញុំយល់អំពីអ្វីដែលលោកប្រធានបានលើកឡើងយោងតាម

សេចក្ដីសម្រេចអម្បាញ់មិញនេះ សំណើរបស់យើងគឺថា ផ្នែកនៃការស្ដាប់ចម្លើយសក្ខីកម្ម <2-TCCP-271> ធ្វើជាអសាធារណៈ<នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ គួរតែធ្វើ>ជាឯកសារសាធារណៈ <ដូច្នេះ យើងអាចយោងតាមឯកសារនេះ មកតាំងសំណួរសាក្សីបាន។ ធ្វើដូចគ្នាដែរចំពោះសាក្សីផ្សេងៗនាពេលខាងមុខទៀត>។ <នោះជាសំណើដែលយើងយោងតាមសេចក្ដីសម្រេច ដែលទើបតែចេញអម្បាញ់មិញនេះ>។

សហការីរបស់ខ្ញុំបានប្រាប់ថា ជាភាសាខ្មែរដូចជាមិនសូវច្បាស់ទេ។ ខ្ញុំសូមនិយាយឡើងវិញ។ សាក្សីនោះ គឺកាលពីថ្ងៃទី០៥ ខែកុម្ភៈ កន្លងទៅហ្នឹងគឺថាមានសវនាការអសាធារណៈមួយផ្នែករួចមកហើយ ដែលរង់ចាំនូវសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។ អ៊ីចឹងថ្ងៃនេះ អង្គជំនុំជម្រះ បានសម្រេចរួចទៅហើយ ដោយថាវិធានការការពារលែងចាំបាច់ទៀតហើយ។ ដូច្នេះ ខ្ញុំសូមថាផ្នែកអសាធារណៈនៃសវនាការថ្ងៃទី០៥ ខែកុម្ភៈ <ឆ្នាំ២០១៥>នុ៎ង គឺធ្វើជាសាធារណៈវិញ ដើម្បីឲ្យយើងអាចយោងទៅលើសវនាការ<នេះ> ដោយមិនឲ្យមានការលំបាកទៅថ្ងៃខាងមុខទៀត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១០:៣៥:៥៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដើម្បីឲ្យបានច្បាស់នោះ អ្វីដែលលោកៗស្រីសុំនោះ <បើសិនណាខ្ញុំស្ដាប់មិនច្រឡំទេនោះ> គឺថាប្រតិចារឹកសវនាការកាលពីថ្ងៃមុននុ៎ង គឺថាត្រូវដាក់ជាសាធារណៈវិញ គឺថាដោយសារតែមិនមានវិធានការការពារ ហើយសវនាការដើមបណ្ដឹងហ្នឹង ក៏ត្រូវធ្វើជាសាធារណៈ។ អ៊ីចឹងមែនទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

អ៊ីចឹងហើយលោកចៅក្រម គឺខ្ញុំ<គិតថា ជាភាសាបារាំង វាច្បាស់ជាង។ គឺ>ធ្វើអ៊ីចឹងហើយ។

**ប្រធានអង្គជំនុំ៖**

មានភាគីណាពាក់ព័ន្ធមានមតិយោបល់ ពាក់ព័ន្ធនឹងបញ្ហានេះទេ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន ខ្ញុំទើបតែពិភាក្សាជាមួយមេធាវីរបស់ សយ សែន។ ហើយគាត់ប្រាប់ថាមិនមានបញ្ហាអ្វីទេ ពាក់ព័ន្ធទៅនឹងសំណើរបស់មេធាវីការពារក្ដី ខៀវ សំផន នោះ។ សូមឲ្យអង្គ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជំនុំជម្រះទទួលយកតាមសំណើនោះទៅចុះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៣៧:២២]

**ប្រធានអង្គជំនុំ៖**

ដោយសារមិនមានមតិជំទាស់លើបញ្ហានេះ ហើយជាការលើកឡើងសមស្រប អង្គជំនុំជម្រះយល់ព្រមនិងអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តី ខៀវ សំផន អនុវត្តដូច្នេះ ចំពោះក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី សយ សែន នាពេលរសៀលនេះ។

បាទ ប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរតិចតួចទេ សួរលោកបន្ថែម។ ទាក់ទងទៅនឹងការចោទប្រកាន់ទៅលើសកម្មភាពដែលធ្វើឡើងនៅបរិវេណគុកក្រាំងតាចាន់។ សំណួររបស់ខ្ញុំសួរថាតើលោកធ្លាប់ដែលបានឃើញអ្នកយាម ឬក៏កម្មាភិបាលដទៃទៀត ធ្លាប់ខ្វេះយកប្រមាត់ ឬក៏ថ្លើម ចេញពីសាកសពអ្នកទោសដែលបានគេបានសម្លាប់នៅក្រាំងតាចាន់ <ហើយយកមកស៊ី>ដែរទេ?

[១០:៣៨:៥៣]

**លោក ស៊្លុត សាំង៖**

**ឆ៖** បាទ គឺអត់ទេ។

**ស៖** បាទ សូមអរគុណ។ ឥឡូវ ខ្ញុំសូមអានសម្រង់ខ្លីមួយជូនលោកស្តាប់ ចេញពីឯកសារ ចេញពីចម្លើយជូនទៅសហចៅក្រមស៊ើបអង្កេត គឺចម្លើយរបស់អ្នកយាម<ដូចលោក>។ លោកប្រធាន គឺឯកសារ D40/20 ជាចម្លើយរបស់ ស៊ឹម។ ហើយខ្ញុំសូមការអនុញ្ញាតអានសម្រង់ស្តី អំពីការចោទប្រកាន់ថា មានការសម្លាប់នៅក្រាំងតាចាន់។ ប៉ុន្តែ<មុន>នឹងសួរ ខ្ញុំ<ចង់ដឹង>តើ ស៊ឹម នេះដែលជាអ្នកយាមជាមួយលោកនេះ នៅរស់រានមានជីវិតទេសព្វថ្ងៃនេះ? ហើយបើសិនណាជានៅរស់មានជីវិត តើសព្វថ្ងៃ គាត់រស់នៅឯណាដែរ?

[១០:៤០:០៤]

**លោក ស្មូត្រ សាំង៖**

**ឆ៖** បាទ ស៊ីម នេះរស់រានមានជីវិតបាទ ប៉ុនគាត់នៅឆ្ងាយពីខ្ញុំ មិនដឹងនៅៗខាងម្តុំត្រពាំងធំនេះបាទ។

**ស៖** តើគាត់រស់នៅឃុំសំរោង ស្រុកត្រាំកក់ហ្នឹងមែនទេ?

**ឆ៖** បាទ ឃុំសំរោង ស្រុកត្រាំកក់ហ្នឹងហើយបាទ។

**ស៖** តើថ្មីៗនេះ លោកធ្លាប់បានឃើញ បានជួបគាត់ដោយហេតុផលណាមួយ ឬក៏ដោយថៃដន្យណាមួយដែរទេ?

**ឆ៖** បាទ អត់បានដែលបានជួបគាត់ទេបាទ។

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី អ្នកយាមម្នាក់<នោះ>គឺក្នុងឯកសារ D40/20 គឺ ERN ភាសាអង់គ្លេស 00433573, បារាំង 00524323, និងខ្មែរ 00165334។ គាត់បានឆ្លើយដូចតទៅនេះ ហើយខ្ញុំនឹងសួរលោក ឱ្យលោកផ្តល់យោបល់ទៅលើបញ្ហានេះ។ សំណួរពាក់ព័ន្ធទៅនឹងការចោទប្រកាន់អំពីការសម្លាប់នៅគុកក្រាំងតាចាន់។ ហើយគាត់បានឆ្លើយដូចតទៅ៖

[១០:៤២:០៥]

សំណួរគឺសួរថាអ៊ីចេះ "តើលោកឮសំឡេងអ្វីដែរនៅពេលដែលគេសម្លាប់អ្នកទោស? ខ្ញុំឮគេចាក់មីក្រូ។ គេតែងតែប្រើអ្នកទោសឈ្មោះ សែន ឱ្យចាក់មីក្រូហ្នឹង ពេលគេសម្លាប់ហ្នឹង ហើយនិងនៅពេលដែលគេកាយកប់សាកសពអ្នកទោស"។ ពីមុននោះក៏មានការសួរទៅលោកអំពីមីក្រូនេះផងដែរ ហើយលោកថាលោកមិនដែលឃើញ<មានមីក្រូអីទេ ឬក៏មិនដែលឃើញ> សយ សែន ជីករណ្តៅអីកប់អ្នកសពអ្នកទោសនោះទេ។ តើលោកមានប្រតិកម្មយ៉ាងម៉េចដែរចំពោះចម្លើយអ្នកយាមជាមួយលោក ស៊ីម ដែលបានឆ្លើយថាដូច្នេះនេះ?

**ឆ៖** បាទ ចំពោះអ្នកទោសដែលទៅសម្លាប់នៅក្រាំងតាចាន់ ដែល សយ សែន គាត់បានជីករណ្តៅបាននេះ ខ្ញុំអត់ដឹងទេ។ ដូចមានមីក្រូចាក់ ពេលសម្លាប់បងប្អូនអ្នកទោសក៏អត់ដឹងដែរបាទ អត់មានមីក្រូក្នុងនោះ ពីព្រោះខ្ញុំអត់មានឃើញ។

**ស៖** ដូចយោងតាមការចងចាំរបស់លោក គឺមិនមានសំឡេងអ្វីឮ<ខ្លាំង>ៗ ដែលគេចាក់នៅពេលដែលមានការចោទប្រកាន់ថាសម្លាប់អ្នកទោសនៅក្រាំងតាចាន់។ <ត្រង់នេះ ខ្ញុំមិនយល់ទេ តើ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រហែលជាគេចាក់មិនឲ្យអ្នកទោសដទៃទៀតឮ ឬក៏លោកមិនចាំ>?

**ឆ៖** បាទ ជាការពិត។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី តាមការចងចាំរបស់លោកក្រៅពីអគារដែលគេឃុំឃាំងអ្នកទោស គឺថាវាមានរូងនៅក្រោមដីសម្រាប់ឃុំអ្នកទោស។ តើមានឬក៏អត់ទេ?

[១០:៤៤:៤២]

**ឆ៖** ក្នុងនោះដូចមិនឃើញមានទេបាទ។

**ស៖** សូមអានឲ្យលោកស្ដាប់នូវសម្រង់មួយទៀត ចេញអំពីរបាយការណ៍ក្រោយឆ្នាំ១៩៧៩ គឺឯកសារ E3/2062, ERN ជាភាសាអង់គ្លេស 00301366, និងខ្មែរ00079439។ ខ្ញុំអត់មាន ERN ជាភាសាបារាំងទេ។ ខ្ញុំសូមដកស្រង់របាយការណ៍នេះដូចតទៅដើម្បីឲ្យវាច្បាស់ចំពោះបញ្ហានេះ។ ពីចុងឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧ គេបានរៀបចំ វិធីសាស្ត្រថ្មី<សម្រាប់ធ្វើទារុណកម្ម>។ គឺមានរូងនៅក្រោមដីរាងជាការេ<ទំហំ២ម៉ែត្រ> ជម្រៅ៥ម៉ែត្រ ហើយក៏មានរបងលួសបន្លាព័ទ្ធជុំវិញ <មានគ្របបន្ទះក្ដារ>។ គេបានជីកដី<កម្ពស់មួយជំហរមនុស្ស> បន្ទាប់មកគេដាក់ក្ដារនៅក្នុងរូងនោះ ហើយបន្ទាប់មក <គេប្រើអង្កៀបសៀតផ្កា>អ្នកទោស <ហើយដំឡូងពួកគេ”>។ លោកមិនដែលឃើញថាមានរូងនៅក្រោមដីហ្នឹងទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ពីមុនមកខ្ញុំមិនដឹងទេ ប៉ុន្តែក្រោយមកខ្ញុំចូលទៅនៅក្នុងក្រាំងតាចាន់នេះ ខ្ញុំអត់បានឃើញទេបាទ។

**ស៖** សំណួរមួយទៀតក៏ទាក់ទងទៅនឹងរបាយការណ៍នេះផងដែរ។ នៅក្នុងបរិវេណនេះ ខ្ញុំ<សង្ឃឹមថា ខ្ញុំអានពាក្យនេះត្រូវចុះ តើមានដើមពិសដែរទេ?> សុំទោសលោកប្រធាន គឺឯកសារដូចគ្នាទេ គឺ ERN 00301366 ហើយខ្មែរ <00079440>។ ខ្ញុំនឹងសួរសំណួរដដែលនេះឡើងវិញ។ តើវាមាន<ដើមឈើពិស *(Strychnine Tree)*>ដែរ<>ទេ?

**ឆ៖** បាទ ដូចខ្ញុំបញ្ជាក់អ៊ីចឹង ខ្ញុំអត់បានឃើញទេបាទ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ គឺលោកបានឆ្លើយពីព្រឹកមិញ ហើយលោកបានឆ្លើយកាលពីម្សិលមិញ ហើយខ្ញុំយល់ថាសំណួររបស់ខ្ញុំគ្រាន់តែឲ្យឆ្លើយ បាទ ឬក៏ទេ។ តើលោកមានបានជម្រាបជូនតុលាការ <នូវ>អ្វី<ជាការ>ពិត <ហើយគ្មានអ្វីក្រៅពីការពិត, តើអ៊ីចឹងមែន>ទេ?

**ឆ៖** បាទ ខ្ញុំសូមស្ដាប់សំណួរអត់បានទេ បាទ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** លោកបានផ្ដល់សក្ខីកម្មព្រឹកមិញនេះនិងពីម្សិលមិញ ហើយលោកត្រូវបានសួរសំណួរជាច្រើនក្នុងការឆ្លើយទៅនឹងសំណួរទាំងអស់នេះ លោកឆ្លើយការពិតទាំងស្រុងឬក៏អត់ទេ? ឬក៏ឆ្លើយមិនពិតទាំងស្រុងទេ?

[១០:៤៨:៥០]

**ឆ៖** បាទ ក្នុងសំណួរខ្ញុំបាទឆ្លើយជូនទាំងប៉ុន្មាននេះ គឺពិតប្រាកដែលខ្ញុំធ្វើហើយបាទ។

**ស៖** សូមអរគុណលោកដើមបណ្ដឹងរដ្ឋប្បវេណី។ លោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី ដែលការពារលោក ខៀវ សំផន។

**សួរដោយលោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាតតាំងសំណួរមួយចំនួន។ ប៉ុន្តែ ខ្ញុំមានសំណួរខ្លីទេលោកដើមបណ្ដឹងរដ្ឋប្បវេណី។

**ស៖** ចំណុចមួយទាក់ទងទៅនឹងការចាប់ផ្ដើមតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក។ ខ្ញុំបានពិនិត្យទៅលើឯកសារ D40/21 ហើយនិងឯកសារ D22/88 ដែលជាសក្ខីកម្មរបស់លោក ធ្វើនៅពេលវេលាពីរផ្សេងគ្នា។ ហើយឯកសារមុននេះ គឺខាងសហព្រះរាជអាជ្ញា -- សូមទោស សហចៅក្រមស៊ើបអង្កេតសួរលោកក្នុងនាមជាសាក្សី។ ក៏ប៉ុន្តែក្រោយមកប្រហែលជាមួយឆ្នាំជាងក្រោយមក លោកបានក្លាយទៅជាដើមបណ្ដឹងរដ្ឋប្បវេណីវិញ។ ខ្ញុំចង់ដឹងថា តើមានអ្នកណា ឬក៏មូលដ្ឋានអ្វីដែលអាចឲ្យលោកផ្លាស់ប្ដូរឋានៈពីសាក្សីទៅជាដើមបណ្ដឹងរដ្ឋប្បវេណីនេះទេ?

[១០:៥០:៤៦]

**លោក សួគ្រ សាំង៖**

**ឆ៖** បាទ ខ្ញុំសូមជម្រាបអស់លោក កាលពីពាក្យដើមបណ្ដឹងរបស់ខ្ញុំហ្នឹងវាយូរឆ្នាំណាស់ តាំងពី នៅហ្លួសស្ពានជ្រោយចង្វារណោះមួយសា។ អាហ្នឹង ខ្ញុំដាក់ដើមពាក្យបណ្ដឹងយូរឆ្នាំ។ ដល់តែពេលសាក្រោយនេះក៏ខាងមេធាវីគាត់ថា អត់ទទួលដើមបណ្ដឹងខ្ញុំទេ ឲ្យខ្ញុំរកមេធាវីថ្មី។ បើអ៊ីចឹងខ្ញុំរកមេធាវីខ្ញុំមិនដឹងទៅរកឯណាបាន មានតែថាមកកន្លែងសាលាក្ដី។ សាលាក្ដីក៏គាត់ថាឥឡូវហ្នឹងគាត់ឲ្យមេ -- ដក -- មិនបាច់ដកទេនៅក្នុងសាលាក្ដី មានថាដើមបណ្ដឹងនៅដដែល ពីព្រោះខ្ញុំក៏មានវិបត្តិដោយសារឪពុកកាលពីជំនាន់លន់ នល់ នោះក៏មានវិបត្តិឪពុករហូតមកដល់៧៥ បែកហើយនេះ ក៏នៅតែក្នុង បងខ្ញុំ

ប្អូនខ្ញុំរស់នៅក្រាំងតាចាន់បានស្លាប់នៅក្នុងនោះ។ បើអ៊ីចឹង ខ្ញុំសូមដាក់ពាក្យបណ្ដឹងហ្នឹងវិញបាទ។

**ស៖** ខ្ញុំចង់បញ្ជាក់សំណួររបស់ខ្ញុំឲ្យច្បាស់ម្ដងទៀត។ ដោយសារពេលវេលា កាលបរិច្ឆេទដែលលោកមកធ្វើជាសាក្សីនេះ វាមុនពេលដែលលោកធ្វើជាដើមបណ្ដឹង។ អ៊ីចឹងបានន័យថាតុលាការនេះបាទទទួលស្គាល់លោកក្នុងនាមជាសាក្សីរួចទៅហើយ គឺនៅ -- មែនទែនទៅការសម្ភាសរបស់លោកនៅឆ្នាំ ២០០៧ ខែវិច្ឆិកា ថ្ងៃទី២៨។ បាទ ហើយក្នុងលិខិតដែលមានបញ្ជាក់ពីកាលបរិច្ឆេទដែលលោកធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹង គឺចុះថ្ងៃទី១៥ ខែ៩ ឆ្នាំ២០០៨។ អ៊ីចឹងបានន័យថាវាខុស យូរពេលជាងគ្នាជិតមួយឆ្នាំ។ សំណួររបស់ខ្ញុំ ខ្ញុំចង់ដឹងពីមូលហេតុដែលនាំឲ្យលោកធ្វើការផ្លាស់ប្ដូរឋានៈពីសាក្សីទៅជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ។ លោកអាចបញ្ជាក់ចំណុចនេះបានទេ?

**ឆ៖** បាទ ខ្ញុំបានជាខ្ញុំដាក់ពាក្យដើមបណ្ដឹងក្នុងរដ្ឋប្បវេណីនេះ ពីព្រោះខ្ញុំនឹកឃើញកាលពីឪពុកខ្ញុំ បងប្អូនខ្ញុំគ្រោះថ្នាក់នៅក្នុងរបប៣ឆ្នាំ ៨ខែ ២០ថ្ងៃ បានខ្ញុំដាក់ពាក្យបណ្ដឹងនេះឡើងវិញបាទ។

**ស៖** បាទ សូមអរគុណ។ ក្នុងឋានៈលោក ពេលដែលលោកឆ្លើយក្នុងឋានៈជាសាក្សីនៅឆ្នាំ ២០០៧ ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត មាននរណាដែលទៅទាក់ទងលោកឲ្យមកធ្វើជាសាក្សីដែរឬទេនៅពេលនុ៎ង?

[១០:៥៣:៤២]

**ឆ៖** បាទ ខែឆ្នាំអស់ទាំងនេះ ខ្ញុំអត់បានចាំទេបាទ។

**ស៖** សំណួររបស់ខ្ញុំ ខ្ញុំឲ្យលោកឆ្លើយអំពីមនុស្ស ពីបុគ្គលណាដែលជាអ្នកទៅទាក់ទងលោកឲ្យមកធ្វើជាសាក្សី មិនមែនទាក់ទងកាលបរិច្ឆេទទេបាទ។

**ឆ៖** បាទ ក្នុងឆ្នាំនោះ ខ្ញុំក៏មិនបានចាំ និងមួយណាជាមួយណាទេ ពីព្រោះកាលទៅសាកសួរហ្នឹងច្រើនណាស់។ ពីព្រោះខ្ញុំគ្មានឯកសារនៅក្នុងដៃជាកត់សម្គាល់ទេបាទ។

**ស៖** បាទ សូមអរគុណ។ លោកអាចបញ្ជាក់ថា អ្នកដែលទៅជួបលោកនុ៎ងមកពីខាងណាដែរទេ? ឧទាហរណ៍ពីក្រុមអង្គការ ឬក៏ពីខាងតុលាការ ដែលគេស្នើឲ្យលោកធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីជាជាងធ្វើជាសាក្សី?

**ឆ៖** បាទ ខ្ញុំក្នុងនោះខ្ញុំសូមជម្រាបថា ដូចមិនមែនមានតែសាលាក្ដីមួយទេ ក្នុងកន្លែងទទួលខ្ញុំនោះ តាំងពី៧៩ មករហូតមកទល់សព្វថ្ងៃនេះ ច្រើនៗសាលា ច្រើនគ្នា មិនដឹងអង្គការណា មិនដឹងពីខាងណាទៅខាងណា។ ខ្ញុំអត់ដឹងដែរបាទ។ ពីព្រោះមានច្រើន ពីព្រោះខ្ញុំអត់បានចាំឈ្មោះត្រង់ថា ហេ!

សាលាក្តី ឬមួយសាលាខាងមេធាវី ខាងណាៗ ខ្ញុំអត់ដឹងបាទ ពីព្រោះខ្ញុំអត់ចាំ។

[១០:៥៥:២៤]

**ស៖** បាទ សូមអរគុណ។ លោកមានធ្លាប់ជួបជាមួយនឹងអ្នកដែលជាអ្នកស្រាវជ្រាវសរសេរជាអត្ថបទណាមួយដែលលោកចាំៗជាលក្ខណៈបុគ្គល ដោយសារលោកបានធ្វើការសម្ភាសជាមួយគាត់ញឹកញាប់ដែរទេ?

**ឆ៖** បាទ ក្នុងការសម្ភាសខ្ញុំបាទនេះច្រើនណាស់ មិនដឹងខាងណាខ្លះទេ តាំងពីមាន តាំងពីអាស៊ីសេរីក៏មាន មានតាំងពីប្រទេសណាៗទៅ ខ្ញុំអត់ចាំទេបាទ។

**ស៖** បាទ សូមអរគុណ។ ទាក់ទងទៅនឹងការផ្លាស់ប្តូរពីតួនាទីរបស់លោក ពីឋានៈរបស់លោកជាសាក្សីមកដើមបណ្តឹងរដ្ឋប្បវេណីនេះវិញ លោកមាននៅចាំកាលៈទេសៈណាមួយដែលមានបុគ្គលណាម្នាក់ ឬច្រើននាក់ណែនាំឲ្យលោកធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីទេ?

**ឆ៖** បាទ ក្នុងនោះគឺដូចមិនមានខាងណាទេ មានតែខ្លួនខ្ញុំហ្នឹងសុំដាក់រហូតមក ប៉ុន្តែមិនដឹងដាក់ថ្ងៃណា ខែណា ឆ្នាំណាបាទ។

[១០:៥៧:០៩]

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់រួចមកហើយក្នុងសវនាការនេះ ដែលលោកបានបញ្ជាក់ថា លោកគឺជាជនរងគ្រោះម្នាក់នៅក្រាំងតាចាន់នៅក្នុងដំណាក់កាលដំបូង ហើយក្រោយមកលោកបានឆ្លើយថា លោកគឺជាយោធា ជាសន្តិសុខ ជាអ្នកយាមម្នាក់នៅក្នុងមន្ទីរក្រាំងតាចាន់។ ខ្ញុំចង់សួរលោកថា តើតួនាទីជាអ្នកយាម ជាសន្តិសុខនៅមន្ទីរក្រាំងតាចាន់នេះ គឺអាចឲ្យលោកជាអ្នកទទួលខុសត្រូវម្នាក់នៅក្នុងអំពើដែលកើតឡើងនៅក្នុងក្រាំងតាចាន់ដែរទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបក្នុង ខ្ញុំជាកងទ័ព ជាយុទ្ធជននៅក្នុងនោះ គឺនៅក្នុងក្រាំងតាចាន់នេះដែលខ្ញុំចូលរហូតដល់រត់ចេញទៅនេះ គឺខ្ញុំមិនបានទទួលបញ្ជាតាមធ្វើមេ ធ្វើកោយគេខ្ញុំ គឺខ្ញុំគ្រាន់តែតាមបទបញ្ជារបស់ពួកគេតែប៉ុណ្ណោះបាទ។

**ស៖** បាទ ខ្ញុំអត់និយាយអំពីការលោកដែលទទួលបញ្ជាពីគេ ឬក៏លោកធ្វើដោយខ្លួនឯងទេ ប៉ុន្តែសំណួររបស់ខ្ញុំចង់បញ្ជាក់ថា តើលោកមានការទទួលខុសត្រូវចំពោះអំពើដែលកើតឡើងនៅក្រាំងតាចាន់ដែលមានការចាប់ឃុំមនុស្ស មានការសម្លាប់នៅមន្ទីរក្រាំងតាចាន់ជាដើមនេះ។ តើលោកមានថាខ្លួនឯងហ្នឹងជាផ្នែកមួយនៃអំពើទាំងអស់នោះដែរទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ក្នុងនោះខ្ញុំបាទសូមជម្រាប ពីព្រោះការទទួលខុសត្រូវ ខ្ញុំបាទទទួលខុសត្រូវតែទទួលខុសត្រូវត្រង់ថា ឃើញច្បាស់ពិតភ្នែកដែលក្រុមសម្លាប់រង្គាលនៅក្នុងទីនោះ ដោយឃើញសាកសពគាស់មកទល់សព្វថ្ងៃនេះបាទ។

[១០:៥៩:៤៨]

**ស៖** បាទ លោកប្រហែលជាស្តាប់សំណួររបស់ខ្ញុំមិនច្បាស់ ខ្ញុំអត់បានសួរថា លោកបានឃើញអ្វីនៅក្រាំងតាចាន់ទេ។ ខ្ញុំសួរលោកពីការទទួលខុសត្រូវចំពោះអំពើដែលកើតមាននៅក្នុងក្រាំងតាចាន់ដែលទាក់ទងដែលខ្ញុំរៀបរាប់អំមិញនេះ មានការឃុំខ្លួនមនុស្ស មានការសម្លាប់មានការធ្វើទារុណកម្មសួរចម្លើយជាដើមហ្នឹង។ ខ្ញុំ សំណួររបស់ខ្ញុំគឺងាយយល់ទេគឺថា តើលោកជាផ្នែកមួយ ឬក៏ជាបុគ្គលម្នាក់ដែលទទួលខុសត្រូវចំពោះអំពើដែលកើតឡើងនៅក្នុងមន្ទីរក្រាំងតាចាន់ដែរឬទេ? លោកស្តាប់បានទេ?

**ឆ៖** ខ្ញុំបាទអត់ទាន់យល់ទេលោកគ្រូ។

**ស៖** បាទ ខ្ញុំអាចសួរលោកសាថ្មី។ នៅមន្ទីរក្រាំងតាចាន់នេះ គឺជាទីតាំងមួយដែលតាមការចោទប្រកាន់នៅក្នុងយុត្តាធិការនៃតុលាការនេះ ថាជាមន្ទីរសម្លាប់មនុស្ស ជាមន្ទីរសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ។ ដោយសារលោកជាយុទ្ធជន ជាអ្នកយាម ដែលលោកបានបញ្ជាក់អំមិញ ថាជាយោធាដែលការពារនៅក្នុងមន្ទីរក្រាំងតាចាន់នេះ ហើយដែលអំពើនៅក្នុងមន្ទីរក្រាំងតាចាន់នេះ វាមានការឃុំមនុស្សការធ្វើទារុណកម្ម និងការសម្លាប់បាទ។ សំណួររបស់ខ្ញុំសួរថា តើលោកជាផ្នែកមួយដែលត្រូវទទួលខុសត្រូវចំពោះអំពើទាំងនោះដែរឬទេ? លោកស្តាប់បានទេ?

**ឆ៖** បាទ ទាំងអំពើ កាលខ្ញុំធ្វើទាំងអម្បាលម៉ាននេះ គឺខ្ញុំទទួលខុសត្រូវបាទ។

**ស៖** បាទ លោកអាចបញ្ជាក់បានទេ លោកទទួលខុសត្រូវអំពើអ្វីខ្លះ?

**ឆ៖** បាទ ទទួលខុសត្រូវដូចជាគេឲ្យខ្ញុំយាម គេឲ្យខ្ញុំមើលអ្នកទោស គេឲ្យខ្ញុំយាមកាមយប់ព្រលប់ ធ្វើបាយធ្វើម្ហូបឲ្យគេហូប អាហ្នឹងខ្ញុំទទួលខុសត្រូវហើយបាទ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងសូមឲ្យលោកបញ្ជាក់ទៅចំណុចដើមវិញ ថាតើឋានៈរបស់លោកជាដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងផ្នែកនៃការទទួលខុសត្រូវរបស់លោកនៅក្រាំងតាចាន់នេះមានទំនាស់គ្នា ឬក៏មានបញ្ហាដែលមានការចម្រូងចម្រាសយ៉ាងម៉េចដែរទេ?

[១១:០៣:២១]

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់បន្តិចទាក់ទងនឹងនីតិវិធី ខ្ញុំមិន -- នេះមិនមែនជាការជំទាស់នោះទេ សហភាតារបស់ខ្ញុំគាត់មានសិទ្ធិចោទសំណួរតាមគាត់ចង់ ខ្ញុំគ្រាន់តែសូមរំឮកដល់អង្គជំនុំជម្រះផងដែរ ហើយអង្គជំនុំជម្រះក៏ដឹងខ្លួនឯងដែរ។ សូមរំឮកដល់ភាគី ហើយនិងសាធារណជនទាំងអស់ថាប្រសិនជាលោក <សូត្រ សាំង ក្លាយ>ជាដើមបណ្ដឹង<រដ្ឋប្បវេណី នេះក៏ព្រោះសហ> ចៅក្រមស៊ើបអង្កេត<បានចេញដីកា>សម្រេច<រួចមកហើយ។ ហើយយើងបាន>ទទួលយកគាត់ធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០។ អ៊ីចឹងដីកានោះ អ៊ីចឹងគ្មានភាគីណាមិនបានប្ដឹងឧទ្ធរណ៍នោះទេ ដូច្នេះឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់នៅទីនេះៗ ត្រូវបានសម្រេចដោយសហចៅក្រមស៊ើបអង្កេតកាលឆ្នាំ២០១០រួចទៅហើយ។ ហើយកាលនោះ ភាគីមានសិទ្ធិប្ដឹងឧទ្ធរណ៍ ក៏ប៉ុន្តែគ្មានភាគីបានប្ដឹងឧទ្ធរណ៍នោះទេ អ៊ីចឹងយើងទាំងអស់គ្នា<នៅក្នុងបន្ទប់សវនាការនេះ បានដឹងហើយថា បញ្ហានៃការ>ទទួលបាននូវឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ គឺ<>នៅដំណាក់កាលស៊ើបសួរ <មិនមែនសម្រេចនៅដំណាក់កាលនៃការជំនុំជម្រះនេះទេ>។ អ៊ីចឹងខ្ញុំសូមបំភ្លឺនៅទីនេះៗ ពីព្រោះថាដើមបណ្ដឹងរដ្ឋប្បវេណីគាត់មិនត្រូវនិយាយអ្វីលើឋានៈរបស់ខ្លួនទេ ព្រោះចៅក្រមស៊ើបអង្កេតបានសម្រេចហើយតាមរយៈការចេញដីកា<>មួយនៅខែសីហា ឆ្នាំ២០១០ហើយមកហើយ លោកប្រធាន។ នេះគ្រាន់ជាការកត់សម្គាល់ទេលោកប្រធាន។

[១១:០៥:១០]

**លោក គង់ សំអុន៖**

បាទ លោកប្រធានខ្ញុំសុំបន្តសំណួរទៅសំណួរផ្សេងទៀត។

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសុំសួរលោកទាក់ទងទៅនឹងឯកសារ E319.1.23 ទាក់ទងទៅនឹងសំណួរចម្លើយលេខ៨២។ ខ្ញុំសុំដកស្រង់៖ “ស៖ តាមការប៉ាន់ស្មាន តើមានចំនួនអ្នកទោស -- បានដែរឬទេ?” ខ្ញុំសុំអានសាថ្មី “តាមការប៉ាន់ស្មាន តើមានចំនួនអ្នកទោសបានដែរឬទេ? (ប្រហែលជាអាចប៉ាន់ស្មាន អាចសំណួរនេះអាចថា តើលោកអាចប៉ាន់ស្មានចំនួនអ្នកទោសបានដែរឬទេ?) លោក

ឆ្លើយថា សំណួរចម្លើយ៨២៖ ជួនកាលមានម្នាក់ បីនាក់ ប្រាំនាក់ ៣០នាក់។ នៅពេលខ្លះ នៅក្នុងបរិវេណគុកហ្នឹង មានតែអ្នកទោសម្នាក់ប៉ុណ្ណោះ។ សៈ យើងមានព័ត៌មានបញ្ជាក់ថា មានតួលេខខ្ពស់ជាងហ្នឹង។ តើលោកអាចបញ្ជាក់បានទេ? ឆ៨៣៖ ចំនួនហ្នឹងអាចនៅក្នុងសម័យ តាឆេន។ សៈ តាឆេនគាត់ចេញពីមន្ទីរក្រាំងតាចាន់នៅក្នុងឆ្នាំណា? ឆ៨៤៖ បាទ តាឆេន គាត់ចេញនៅឆ្នាំ១៩៧៤។ សៈ តើលោកមកមន្ទីរក្រាំងតាចាន់ ចុងឆ្នាំ៧៧ ដែរមែនទេ? ឆ៨៥៖ ចុងឆ្នាំ៧៧ និងដើមឆ្នាំ៧៨ ប្រហែលជាខែមករា ឬកុម្ភៈ ក្នុងខែប្រែត។ ខ្ញុំត្រូវបានបញ្ជូនទៅចូលទ័ពដើម្បីវ៉ៃជាមួយវៀតណាម"។ បាទ សុំបញ្ចប់ការដកស្រង់។

សំណួររបស់ខ្ញុំទាក់ទងទៅនឹងចំនួនអ្នកទោសនៅមន្ទីរក្រាំងតាចាន់ ដែលលោកបានបញ្ជាក់នៅក្នុងចម្លើយ៨៣ របស់លោកថានៅក្នុងសម័យ តាឆេន អាចមានចំនួនអ្នកទោសច្រើន។ ខ្ញុំចង់សួរថា តើលោកដឹងដោយរបៀបណានៅពេលដែលលោកចូលមកមន្ទីរក្រាំងតាចាន់នៅឆ្នាំ៧៧នោះ ហើយតាមចម្លើយរបស់លោកពីម្សិលមិញ លោកបានបញ្ជាក់ថាលោកចូលមកមន្ទីរក្រាំងតាចាន់ជាមួយនឹងកងទ័ពដទៃដែលអាចនៅក្នុងចន្លោះឆ្នាំ ចុងឆ្នាំ៧៥ ឬ៧៦ គឺមិនមែន ៧៧ ឬ៧៨នោះទេ។ តើលោកអាចបញ្ជាក់បានបែបណាថានៅក្នុងសម័យ តាឆេន គ្រប់គ្រងមន្ទីរក្រាំងតាចាន់នេះ មានអ្នកទោសច្រើន?

[១១:០៨:៤៨]

**លោក ស្បូត្រ សាំង៖**

**ឆ៖** បាទ នៅក្នុងសម័យ តាឆេន ខ្ញុំក្តាប់មិនជុំទេ ប៉ុន្តែគ្រាន់ថា វាមានច្រើនយូរយាណាស់មក ហើយនៅទីនោះ គេសម្លាប់រួចមុនពីជំនាន់លន់ នល់ បាទ។ គឺទាហានលន់ នល់ ឮ មិនជាឃើញទេ គ្រាន់តែឮថាបងប្អូនញាតិមិត្តជិតខាងពួកអ្នកប្រជាជនរស់នៅជិតខាងហ្នឹងគាត់ថា ជំនាន់តាឆេន គឺជំនាន់លន់ នល់ ប៉ុន្តែមន្ទីរហ្នឹងខ្ញុំអត់ដឹងកើតពីឆ្នាំណា ខែណា ឆ្នាំណាទេ បាទ។

**សៈ** លោកដឹងពីប្រជាជនជិតខាង មានន័យថាលោកទៅនិយាយជាមួយអ្នកស្រុកនៅក្បែរហ្នឹង ហើយគេនិយាយប្រាប់លោក ឬមួយយ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំនិយាយតាមរយៈខ្ញុំដឹង គឺកាលពីតាដាំគាត់នៅ ខ្ញុំ -- កាលគាត់នៅហើយ គាត់ចូលមកវិញបាទ។

[១១:០៩:៤៨]

**សៈ** សំណួរដើមរបស់ខ្ញុំ ខ្ញុំចង់ដឹងពីប្រភពដែលលោកដឹងថាសម័យ តាឆេន មានអ្នកទោស

ច្រើន។ អ៊ីចឹងខ្ញុំចង់ដឹងថាតើលោកដឹងមកពីណា? លោកដឹងពីអ្នកជិតខាង ឬដឹងពី តាដាំ ដែលលោកនិយាយចុងក្រោយអម្បាញ់មិញនេះ?

**ឆ៖** បាទ ខ្ញុំបាទដឹងពី តាដាំ បាទ ពីព្រោះ តាដាំ នេះគាត់នៅកាលជំនាន់នោះហើយ គាត់ចេញទៅវិញ គេឲ្យរួចទៅវិញ។ ដល់ក្រោយមកបានគាត់ចូលមកវិញបាទ។

**ស៖** អ៊ីចឹងអត់ លោកអត់មានព័ត៌មានអីពីអ្នកជិតខាងទេ គឺលោកបានព័ត៌មានពី តាដាំ តែម្នាក់គត់ឬយ៉ាងម៉េច?

**ឆ៖** បាទ បានព័ត៌មានពី តាដាំ បាទ។

**ស៖** លោកអាចបញ្ជាក់បានទេថា តាដាំ និយាយជាមួយលោកម៉េចខ្លះ?

**ឆ៖** បាទ តាដាំ គាត់ៗបាននិយាយជាមួយខ្ញុំ ខ្ញុំក៏បានសាកសួរលេងជាមួយគាត់ នៅក្នុងទីនោះកាលពីគាត់មើលក្របី មើលគោហ្នឹង ក៏ខ្ញុំបានសាកសួរគាត់លេងសើចជាមួយគាត់ហ្នឹង គឺថាកាលពីមុនមកមានច្រើន កាលជំនាន់លន់ នល់ មិនមែនជំនាន់ក្រោយនេះ។ ក្រោយនេះ វាជំនាន់ក្រោយដែលខ្ញុំទៅរស់នៅនេះ គឺតិចទេ។

[១១:១១:៣៥]

**ស៖** បាទ សូមអរគុណ។ តើលោកមានបានឃើញអ្វីដូចជាផ្នូរ ឬក៏កន្លែងសម្លាប់មនុស្សក្នុងសម័យពី៧៤ ហ្នឹងទេ សម័យ តាឆេន គ្រប់គ្រងនិងបន្សល់ទុក នៅពេលដែលលោកទៅនៅមន្ទីរក្រាំងតាចាន់នោះ?

**ឆ៖** បាទ ផ្នូរ សំណៅសាកសពដែលបងប្អូនស្លាប់នៅក្នុងក្រាំងតាចាន់នេះ គឺខ្ញុំបានឃើញបាទ។

**ស៖** ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ គឺខ្ញុំនិយាយអំពីផ្នូរដែលមានក្នុងសម័យ ឬក៏បន្សល់ទុកពីសម័យតាឆេន គ្រប់គ្រង់។ លោកអាចបញ្ជាក់ផង។

**ឆ៖** បាទ គឺផ្នូរសម័យតាឆេន គ្រប់គ្រងហ្នឹង គឺផ្នូរនៅៗជួរខាងត្បូងស្នួរចម្លើយហ្នឹងបាទ។

**ស៖** មានច្រើនប៉ុនណាដែរ?

**ឆ៖** បាទ ផ្នូរសម្រាប់សាកសពបងប្អូនស្លាប់នៅក្នុងក្រាំងតាចាន់នេះ គឺខ្ញុំបាទអត់បានរាប់ផ្នូរទេប៉ុនគ្រាន់តែបានឃើញផ្នូរកន្លែងសាកសពហ្នឹង គឺឃើញបាទ។ តែចំនួនថា ចំនួនប៉ុន្មានផ្នូរប៉ុន្មានផ្នូរ ខ្ញុំអត់បានទេ អាស្រែមួយនៅខាងត្បូងហ្នឹង អាហ្នឹង គឺផ្នូរសាកសពបាទ។

[១១:១៣:០៤]

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** បាទ សូមអរគុណ។

**លោក គង់ សំអុន៖**

លោកប្រធាន ខ្ញុំអស់សំណួរ សូមឲ្យសហភាតាបន្តបាទ។

**ស្នងដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោក សួត្រ សាំង ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ។ ខ្ញុំជា<>មេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ខ្ញុំចង់ចោទសំណួរបន្តមួយចំនួន ហើយនិងសូមការបំភ្លឺពីលោក។ បើដូច្នេះ ខ្ញុំសូមឲ្យលោកស្តាប់សំណួរខ្ញុំឲ្យដោយយកចិត្តទុកដាក់ ដើម្បីឆ្លើយឲ្យបានខ្លីដែលអាចធ្វើទៅបាន។

ជាបឋម ខ្ញុំសូមត្រឡប់មកនិយាយអំពីចំណុចមួយចំនួននៃ ទាក់ទងនឹងចម្លើយរបស់លោក គឺថាឯកសារ E319.1.23។ ចំណុចដែលខ្ញុំចាប់អារម្មណ៍ជាងគេនោះ គឺថ្នាក់ដឹកនាំមួយចំនួនដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺនៅចម្លើយទី<១០> ហើយនិង១៥ នៃឯកសារហ្នឹង លោកបានលើកឡើងអំពីឈ្មោះ តាជឹម។ លោកនិយាយថាគាត់ជាគណៈស្រុក ជាមេស្រុកត្រាំកក់។ ហើយបន្ទាប់មកទៀតគាត់ត្រូវបានបញ្ជូនទៅភូមិភាគបូព៌ានៅចុងឆ្នាំ១៩៧៦។ ដូច្នេះសំណួរខ្ញុំដូចតទៅនេះ តើជាបឋម -- តើលោកធ្លាប់បានជួប តាជឹម ដែរឬទេ នៅពេល<គេតែតាំងលោកនៅត្រាំកក់?> នេះជាសំណួរទី១។

**លោក សួត្រ សាំង៖**

**ឆ៖** បាទ ចំពោះខ្ញុំបាទជួប តាជឹម គឺខ្ញុំអត់ដែលបានជួប តាជឹម ទេបាទ។

**ស៖** ហេតុអីបានលោកដឹងថាគាត់ជាប្រធានស្រុក ហើយបន្ទាប់មកទៀតហ្នឹងតើគាត់ទៅធ្វើការនៅភូមិភាគបូព៌ានៅចុងឆ្នាំ១៩៧៦?

**ឆ៖** បាទ គ្រាន់តែឃើញថាឈ្មោះ ឮតែឈ្មោះ តាជឹម បាទ។ តាជឹម ហ្នឹងគ្រាន់តែឮតែឈ្មោះទេ តែត្រង់រូប បានទៅនិយាយ ទៅទាក់ទងជាមួយគាត់ គឺខ្ញុំអត់មានបានទាក់ទងទេបាទ។

**ស៖** ខ្ញុំយល់ហើយ សួត្រ សាំង។ ក៏ប៉ុន្តែសំណួរខ្ញុំអម្បាញ់មិញនោះ ខ្ញុំចង់ដឹងថា ដោយហេតុថាលោកមិនដែលបានធ្លាប់ជួបគាត់ មិនដែលបាននិយាយជាមួយគាត់។ អ៊ីចឹងថាហេតុអីបានលោកដឹងថាគាត់ជាប្រធានស្រុក? <តើលោកបានព័ត៌មាននេះមកពីណា>?

**ឆ៖** បាទ ឈ្មោះប្រធានស្រុក ពីណាក៏ឃើញដែរ គេដឹងដែរថា តែអ្នកធំនៅក្នុងស្រុក កាន់ស្រុកហ្នឹងមួយ បើថា តាជឹម ដឹងថាស្រុក គណៈស្រុក តាជឹម គេដឹងថាគាត់គណៈស្រុកហើយ។ យើងមិន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មែនបានទៅនិយាយលេងសើចជាមួយគាត់ទេ អាហ្នឹងគេអ្នកធំបាទ។

[១១:១៦:២៥]

**ស៖** ខ្ញុំគ្រាន់តែចង់ដឹងថាតើលោកដឹងតាមរយៈអ្នកណា? ថាដឹងតាមរបៀបណាតែប៉ុណ្ណឹងទេ។ ហេតុអីបានដឹងថាគាត់ធ្វើចៅហ្វាយស្រុកនោះ?

**ឆ៖** បាទ ខ្ញុំដឹងធ្វើចៅហ្វាយស្រុកហ្នឹង ដូចខ្ញុំជម្រាបអីចឹង ខ្ញុំថាឈ្មោះលោកអ្នកធំ ប្រជាជន ឬកងយុទ្ធជនទាំងឡាយណាក៏គេដឹងថាហ្នឹង តាជឹមៗ គឺថាគណៈស្រុក តាជឹមគណៈស្រុកៗ។ អាហ្នឹងវាដូចថា តាម៉ុក ភូមិភាគៗ មិនដឹង តាម៉ុក មុខម៉េច បើមិនដែលឃើញ តាម៉ុក ផងហ្នឹង។

**ស៖** តើនៅ -- តើលោកដឹងថាគាត់ហ្នឹងទៅ -- ត្រូវបានគេតែងតាំងឲ្យធ្វើការនៅភូមិភាគបូព៌ាហ្នឹងតាមរបៀបណាដែរ?

**ឆ៖** បាទ ការតែងតាំងធ្វើទៅតាមភូមិភាគបូព៌ាហ្នឹង ខ្ញុំអត់ដឹងទេបាទ។

**ស៖** អ៊ីចឹងហេតុអីបានលោកឆ្លើយនៅចៅក្រមស៊ើប -- ប្រាប់<សហ>ចៅក្រមស៊ើបអង្កេតហ្នឹង បើសិនលោកមិនដឹង ម៉េចក៏លោកឆ្លើយប្រាប់ផ្សេង?

**ឆ៖** ខ្ញុំអត់ដែលបានឆ្លើយប្រាប់គាត់ទេបាទ។

[១១:១៨:០៦]

**ស៖** នៅចម្លើយ២៨ នៅឯកសារដដែល នៅពេលដែលលោកឆ្លើយទៅនឹងសំណួរមួយទៀត លោកថា<ថ្នាក់>ស្រុកហ្នឹងគេមានសិទ្ធិចាប់មនុស្ស។ ខ្ញុំសួរដដែលទេ សួរថាតើហេតុដូចម្តេចបានលោកដឹងថាស្រុកហ្នឹងមានសិទ្ធិចាប់មនុស្ស?

**ឆ៖** បាទ ក្នុងប្រធានស្រុក គេមានសិទ្ធិចាប់មនុស្ស។ តាមចាប់រយៈណា ធ្វើយ៉ាងម៉េចៗ ខ្ញុំអត់ដឹងទេ ប៉ុន្តែគ្រាន់តែថាដូចជាមានបងប្អូនថា ឥឡូវខ្ញុំធ្វើខុសនៅទីហ្នឹង គេមានសិទ្ធិចេញគេស្រាវជ្រាវពីណា ពីតាអាន់ទៅ។ តាអាន់ គេឲ្យនីរសារទៅយកសំបុត្រហ្នឹងទៅឲ្យកន្លែងមន្ទីរស្រុក។ មន្ទីរស្រុក មិនដឹងមន្ទីរស្រុកគេនៅណាទេបាទ។

**ស៖** សូមជម្រាបជូនអង្គជំនុំជម្រះ សាក្សី TCW-809 នៅក្នុងសេចក្តីឆ្លើយ ចម្លើយរបស់គាត់ គឺឯកសារ E3/4626 គាត់និយាយថា មិនមែនស្រុកទេ គឺតំបន់ទេ ដែលមានសិទ្ធិអំណាចផ្ទាល់លើក្រាំងតាចាន់។ លោក សួត្រ សាំង តើលោកដឹងដែរឬទេថា តើស្រុក ឬក៏តំបន់ ដែលមានសិទ្ធិអំណាច ឬក៏គ្រប់គ្រងទៅលើក្រាំងតាចាន់ដោយផ្ទាល់នេះ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ អ្នកគ្រប់គ្រងនៅក្នុងក្រាំងតាចាន់នេះ មិនដឹងប៉ុន្មានទេ ខ្ញុំអត់ដឹងពិតប្រាកដទេ ប៉ុនខ្ញុំដឹងថាចាប់តាំងពីស្រុក ពីខេត្ត ពីតំបន់ទៅ អាហ្នឹងជារឿងសិទ្ធិរបស់គេ ត្រង់ថាយ៉ាងម៉េចមួយទៀត ខ្ញុំអត់ដឹងបាទ។

[១១:២០:០២]

**ស៖** នៅចម្លើយ២៧ នៃឯកសារដដែលនេះ លោកបាននិយាយអំពីឈ្មោះ តាញ៉ែវ ថាគាត់ជាលេខាតំបន់។ អ៊ីចឹងសំណួរខ្ញុំចង់ដឹងថា ជាដំបូងចង់ដឹងថាតើហេតុដូចម្តេចបានលោកដឹងថា គាត់ជាលេខាតំបន់? ហើយតើគាត់ត្រូវបានគេតែងតាំងឲ្យក្លាយជាលេខាតំបន់ហ្នឹងនៅឆ្នាំណាដែរ បើតាមការចងចាំរបស់លោក បាទ?

**ឆ៖** បាទ ក្នុងនោះ ខ្ញុំមិនដឹងតែងតាំងគាត់ តាញ៉ែវ ហ្នឹងតែងតាំងពីឆ្នាំណាទេ។ ដឹងថា តាញ៉ែវធ្លាប់កាន់កងតំបន់ដែលខ្ញុំឈរជើងរ៉ៃនៅតាកែវនេះបាទ។

**ស៖** បាទ នៅក្នុងឯកសារមួយទៀតគឺឯកសារ D22/88, ERNជាភាសាបារាំងគឺ 1055820 *(ស៊ីក)* ERN ជាភាសាអង់គ្លេសគឺ 00379421, ERNជាភាសាខ្មែរគឺ 00354364។ លោកបាននិយាយអំពីមនុស្សពីរនាក់នៅក្នុងឯកសារនេះ លោកបាននិយាយដូចតទៅនេះ៖ "ខ្ញុំសង្កេតថាឃើញមានវត្តមានរបស់ តារស់ និងតា<យ>ន នៅក្នុងមន្ទីរនោះ គាត់ហ្នឹងសុទ្ធតែមកពីមន្ទីរស្រុក។ ហើយគាត់ហ្នឹងដែលតាមដានពីការបាត់ខ្លួនមនុស្ស និងការចាប់ខ្លួនមនុស្សទាំងអស់"។ អ៊ីចឹងសំណួរសួរថាតើ តារស់ ហើយនិងតា<យន> ហ្នឹងជាអ្នកណា? ហើយពួកគាត់ហ្នឹងមានមុខងារអ្វីដែរ? <>

**ឆ៖** បាទ ខ្ញុំឃើញ តាយន, តារស់ ចូលទៅ មិនដឹងគាត់សិទ្ធិជាប៉ុន្មានទេ ពីព្រោះសិទ្ធិគេទាក់ទង តែជាមួយប្រធានៗ ដូចតាអាន់, តាពេញ, តាចេង ឯណោះបាទ។ ចំពោះខ្ញុំអត់ដែលបានទាក់ទងជាមួយទេ គ្រាន់តែបានឃើញទេបាទ។

[១១:២២:៣២]

**ស៖** លោកបានជួបគាត់ហ្នឹងច្រើនដង បើសិនជាលោកចាំនោះអាចប្រាប់បានទេ ថាបានជួបគាត់ប៉ុន្មានដងដែរ?

**ឆ៖** បាទ ក្នុងចំនួនប៉ុន្មានដងៗ ខ្ញុំអត់បានចាំទេបាទ ប៉ុន្តែឃើញគាត់មិនដឹងជាប៉ុន្មានថ្ងៃ ម្តង ឬមួយប៉ុន្មានខែបានម្តង ប៉ុន្តែឃើញគាត់ទៅមក ជួនកាលអត់បានមក ជួនកាលទៅអ៊ីចឹង ជួនកាលមកអ៊ីចឹងទៅ។ គ្រាន់តែបើរាប់ជាដងៗ ខ្ញុំបាទមិនរាប់ចំនួនទុកទេបាទ។

**ស៖** បាទ ខ្ញុំយល់ហើយ។ ក៏ប៉ុន្តែតើលោកអាចប្រាប់ ជម្រាបជូនតុលាការបានដែរឬទេថាលោកបានឃើញគាត់ញឹកញាប់ដែរឬទេ? ឬក៏<កម្របានឃើញ>?

**ឆ៖** បាទ ក្នុងនោះឃើញគាត់មក មិនចាំថ្ងៃគាត់មកទេ ដូចខ្ញុំជម្រាបថា គាត់មក ប៉ុន្តែមកតែពេលវេលាគាត់ត្រូវមក គាត់មក គាត់មិនមក គាត់ក៏មិនមកទៅ។ មិនដឹងជារឿងគេទាក់ទងជាមួយគាត់យ៉ាងម៉េច ពីព្រោះមន្ទីរ ហើយនិងគាត់ហ្នឹង ខ្ញុំអត់ដឹងដែរបាទ។

[១១:២៣:៥០]

**ស៖** មានបុគ្គល<ចុងក្រោយ>មួយទៀត ខ្ញុំចង់ចោទសំណួរសួរទាក់ទងបុគ្គលរូបនេះ ឈ្មោះហ៊ុល ហឿន។ លោកស្គាល់គាត់ទេ?

**ឆ៖** ហ៊ុល ហឿន នេះ ខ្ញុំអត់បានស្គាល់គាត់ទេ មិនបានដឹងថាគាត់នៅពីត្រឹមម៉ានមកទេបាទ។

**ស៖** កាលពីម្សិលមិញនៅពេលដែលលោកឆ្លើយទៅសំណួរចៅក្រម ឡាវ៉ែន់ លោកបានឆ្លើយថាលោកមិនដែលធ្លាប់ជាប្រធានអ្នកយាមនៅមន្ទីរក្រាំងតាចាន់ទេ ហើយលោកក៏មិនមានតំណែងអ្នកទទួលខុសត្រូវអី ឬក៏គ្រប់គ្រងអីលើអ្នកយាមនោះដែរ។ តើខ្ញុំយល់នេះត្រឹមត្រូវដែរឬទេ? លោកឆ្លើយអ៊ីចឹងកាលពីម្សិលមិញ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** លោកបាននិយាយថា -- ខ្ញុំសូមដកស្រង់ចម្លើយរបស់លោក។ ឯកសារ D22/88, ERN ដូចមុនអម្បាញ់មិញអ៊ីចឹង ជាភាសាបារាំងគឺ <0155820>*(ស៊ីក),* ជាភាសាខ្មែរ គឺ 00354364, អង់គ្លេសគឺ<00379421>។ លោកបានពិពណ៌នាអំពីការងាររបស់លោកនៅជាមួយអ្នកទោសដូចតទៅនេះ៖ "ខ្ញុំទទួលបន្ទុកក្នុងការគ្រប់គ្រងអ្នកទោសក្នុងការងារប្រចាំថ្ងៃរបស់ពួកគេ ឧទាហរណ៍ដូចជា កាប់ដី ធ្វើស្រែ ឬក៏ជីស្រះអីជាដើម។ ហើយខ្ញុំក៏រាប់អ្នកទោសផងដែរ នៅពេលដែលគេចេញទៅធ្វើការ ហើយនិងពេលត្រឡប់ចូលមកអគារឃុំឃាំងវិញ។ ខ្ញុំក៏ត្រូវធ្វើការជាមួយពួកគាត់ផងដែរ"។ ខ្ញុំបញ្ចប់ការដកស្រង់។

សំណួរខ្ញុំដូចតទៅនេះ លោកបានឆ្លើយថាមុខងាររបស់លោកហ្នឹង គឺទាក់ទងទៅនឹងការយាមនៅខាងក្រៅមន្ទីរក្រាំងតាចាន់ទេ។ អ៊ីចឹងសំណួរខ្ញុំ ខ្ញុំចង់ដឹងថា តើលោក ក្នុងព្រមជាមួយគ្នាហ្នឹង គឺថាលោកយាមនៅក្រៅមន្ទីរក្រាំងតាចាន់ផង ហើយនិងយាមអ្នកទោសនៅខាងក្រៅផង ឬក៏លោកកាន់<>មុខងារទាំងពីរនេះ គឺនៅក្នុងពេលពីរខុសគ្នា<>ឬក៏យ៉ាងណា?

[១១:២៦:៤៨]

**ឆ៖** បាទ គឺពេលយាម យាមតែពេល -- បើយើងយាមអ្នកទោសធ្វើការងារ គឺធ្វើការងារជាមួយគាត់ គឺធម្មតាៗទេ គឺអត់ឲ្យបាត់ទេ។ ដល់ពេលធ្វើការងារចប់សព្វគ្រប់ហើយ យកមកដាក់ក្នុងមន្ទីរឃុំឃាំងហ្នឹងវិញ យើងដឹងថាបើចេញ១០នាក់ បញ្ចូលមកវិញ១០នាក់ បាទ។

**ស៖** ខ្ញុំយល់ហើយ។ សំណួរសួរបន្តពីចម្លើយអម្បាញ់មិញនេះ ជាទូទៅនោះ តើចំនួនអ្នកទោសដែលចេញទៅជាមួយលោកនោះ មានចំនួនប៉ុន្មាននាក់ដែរ ដែលលោកនាំចេញទៅក្រៅនោះ រាល់ដងលោកនាំអ្នកទោសចំនួនប៉ុន្មាន ដើរចេញទៅក្រៅ?

**ឆ៖** បាទ យកទៅធ្វើការរែកដីជីកស្រះនេះ គឺជួនកាល ១០នាក់ ជួនកាលប្រាំនាក់ ជួនកាលបួនប្រាំ ប្រាំមួយ ប្រាំពីរនាក់ មិនជាៗប្រាកដទេបាទ។ ប៉ុន្តែមិនលើសពី១០នាក់ទេ។

**ស៖** ខ្ញុំសូមអរគុណ <តែលោកមិនបានឆ្លើយសំណួរអីសោះ>។ អ៊ីចឹងសំណួរដែលលោកបានឆ្លើយតបអម្បាញ់មិញនោះ គឺសំណួរខ្ញុំចង់ដឹងថាតើការងារដែលនាំអ្នកទោសទៅធ្វើការនៅខាងក្រៅហ្នឹងការងារហ្នឹងលោកបំពេញក្នុងពេលជាមួយ ពេលដែលលោកយាមនៅខាងក្រៅ<គុកក្រាំងតាចាន់ ឬក៏លោកបំពេញការងារនេះនៅពេលផ្សេងពីហ្នឹង>?<>

**ឆ៖** បាទ គឺការងារយាមកាមខាងក្រៅនេះ ការងារតែមួយទេបាទ គឺនាំអ្នកទោសទៅ គឺយើងការពារយាមកាមខាងក្រៅហ្នឹង ក្នុងបរិវេណវាមិនឆ្ងាយទេ ប៉ុន្តែទិសដៅរៀងខ្លួនបាទ។

[១១:២៨:១៨]

**ស៖** បើតាមការរៀបរាប់អំពីការងាររបស់លោកនោះ គឺថាលោកជាទូទៅលោកធ្វើការតែនៅខាងក្រៅទេ។ តើលោកធ្លាប់បំពេញការងារនៅក្នុង<>បរិវេណមន្ទីរទេ ហើយបើមាននោះ តើលោកធ្វើការអ្វីដែរ? កិច្ចការអ្វីដែរ លោកធ្វើការនៅខាងក្នុងបាទ?

**ឆ៖** បាទ ធ្វើការនៅខាងក្នុងមានតែតួនាទី មានតែដាំបាយ មានតែឲ្យជ្រូកតែប៉ុណ្ណឹងទេបាទ។

**ស៖** នៅក្នុងការបំពេញការងាររបស់លោកនោះ លោកមានសិទ្ធិ<ដើរ>ចូលទៅមន្ទីររបស់តាពេញ និង តាអាន់ ដែរឬទេ?

**ឆ៖** បាទ ការស្នាក់នៅ ដេករស់នៅហ្នឹង គឺខ្ញុំបាទបានចូលបាទ។

**ស៖** តើលោកអាចឆ្លើយនឹងសំណួរខ្ញុំឲ្យច្បាស់លាស់បានទេ ក្នុងក្របខ័ណ្ឌការងាររបស់លោកនោះ <តើ>លោក<>ធ្លាប់ចូលទៅក្នុងមន្ទីរ តាអាន់ និង តាពេញ ដែរឬទេ?

**ឆ៖** បាទ មន្ទីរក្រាំងតាចាន់នេះគឺមន្ទីររបស់ តាពេញ, របស់ តាអាន់, របស់ តាចេង ហ្នឹងហើយបាទ។ ខ្ញុំបានចូលទៅធ្វើបាយ ខ្ញុំឲ្យជ្រូក ហ្នឹងហើយដែលខ្ញុំជាអ្នកចូលបាទ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំគិតថាម៉ោងដប់មួយកន្លះហើយ ខ្ញុំចង់ចូលទៅនិយាយអំពីប្រធានបទមួយទៀត តើអ៊ីចឹងខ្ញុំចង់សួរលោកប្រធានថា ឥឡូវនេះសមគួរនឹងសម្រាកសិន ឬយ៉ាងម៉េចលោកប្រធាន?

[១១:៣១:៣៥]

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវីត្រូវការពេលវេលាប្រហែលប៉ុន្មានទៀតទៅ ព្រោះពេលវេលាដែលបែងចែកឲ្យដូចជាអស់ម៉ោងហើយ។

**កញ្ញា អង់តា ហ្គីសសេ៖**

បើតាមគណនារបស់ខ្ញុំនោះ <បើខ្ញុំគិតមិនខុសនោះទេ> យើងមិនបានចាប់ផ្តើមភ្លាមនោះទេក្រោយពីសហព្រះរាជអាជ្ញានោះ។ អ៊ីចឹងបើតាមគណនារបស់ខ្ញុំនោះ ខ្ញុំត្រូវការពេលវេលាជាង២០នាទីទៀត បើតាមកាលពេលវេលាដែលបានបែងចែកឲ្យដោយអង្គជំនុំជម្រះនោះ ខ្ញុំនៅសល់ពេលវេលាជាង២០នាទីទៀត។ អ៊ីចឹងខ្ញុំត្រូវការពេលនេះដើម្បីសួរបញ្ចប់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវ-នាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីនិង អ្នកជំនាញដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងបុគ្គលិកគាំពារសាក្សីនិងអ្នកជំនាញមកកាន់កន្លែងផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនៅក្នុង សាលសវនាការនេះនៅវេលាម៉ោងមួយនិងសាមសិបនាទី។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកនៅខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៥៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីនេះបញ្ចប់។

**កញ្ញា អង់តា ហ្គីសសេ៖**

អរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

លោក សូត្រ សាំង -- បាទ ឥឡូវខ្ញុំសុំបន្តសំណួរខ្ញុំបន្តទៀត។ ជាថ្មីម្តងទៀត ខ្ញុំសុំៗឲ្យលោកឆ្លើយនូវសំណួររបស់ខ្ញុំ<ឲ្យ>បានខ្លីៗបំផុត។ ម្សិលមិញលោកចៅក្រម ឡាវែន៍ បានចោទសំណួរលោកមួយចំនួនទាក់ទងទៅនឹងការដ្ឋានខ្ទបត្របែកដែលបាន ដែលលោកប្រាប់ថាលោកធ្លាប់ធ្វើការនៅទីនោះ។ ខ្ញុំយល់ អង្កាល់នោះ<>មុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ អ៊ីចឹង ខ្ញុំសុំសួរលោកបញ្ជាក់ថា តើមុនរដ្ឋប្រហារនៅឆ្នាំ១៩៧០ ឬក៏ក្រោយរដ្ឋប្រហារ?

**លោក សូត្រ សាំង៖**

**ឆ៖** បាទ ខ្ទបត្របែកនេះ គឺធ្វើនៅក្នុងឆ្នាំ១៩៧១ ដែលខ្ញុំបាននៅកងយុវជនបាទ។

**ស៖** បាទ សូមអរគុណដែលបានឆ្លើយបញ្ជាក់នេះ។ លោកក៏បានឆ្លើយផងដែរ នៅសវនាការថ្ងៃទី២៤ មីនា កន្លងមកនេះ គឺក្រោយម៉ោង ១០:០៩ នាទី ខ្ញុំសុំឲ្យលោកឆ្លើយបញ្ជាក់ លោកឆ្លើយថា ឪពុករបស់លោកស្លាប់នៅឆ្នាំ១៩៧៣។ តើត្រឹមត្រូវដែរឬទេ? ខ្ញុំយល់យ៉ាងដូច្នេះត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** នៅក្នុងក្របខ័ណ្ឌនៃបទពិសោធន៍របស់លោកនៅក្នុងកងកម្លាំងកងទ័ពខ្មែរក្រហម តើមេបញ្ជាររបស់លោកធ្លាប់បាននិយាយជាមួយលោកអំពីសីលធម៌ទាំង១២ប្រការនៃជនបដិវត្តដែរឬទេ?

**ឆ៖** បាទ បាននិយាយបាទ។

[១៣:៣៣:៥៥]

**សៈ** ដូច្នេះ តើជាការត្រឹមត្រូវដែរឬទេក្នុងការនិយាយថា ក្នុងចំណោមសីលធម៌ទាំង១២ប្រការនេះ គឺថាមានការហាមឃាត់មិនឱ្យប្រព្រឹត្តកំហុសសីលធម៌ ឬក៏ហាមឃាត់មិនឱ្យប្រព្រឹត្តខុសពីសីលធម៌<ជាមួយនារីភេទ>?

**ឆៈ** បាទ ត្រឹមត្រូវហើយ។

**សៈ** លោកបាន<លើកករណីមួយឈ្មោះ ដាំ> ដែលជាសមាជិកបុគ្គលិកមន្ទីរក្រាំងតាចាន់ដែលគាត់ត្រឡប់មកវិញក្លាយជាអ្នកទោស។ <ខ្ញុំជឿថា លោកលើកឡើងអំពីសកម្មភាពអសីលធម៌។ តើលោកដឹងទេ ថាដោយសារការអនុវត្តសីលធម៌ទាំង១២ប្រការ ឬបញ្ញត្តិបដិវត្តន៍ទាំង១២ប្រការនេះហើយ ទើប>គេចាប់គាត់យកមកចូលមកមន្ទីរសន្តិសុខក្រាំងតាចាន់វិញនេះ?

**ឆៈ** បាទ គាត់ខុសសីលធម៌ បានគេយកមកចូលមន្ទីរក្រាំងតាចាន់ម្តងទៀតនេះបាទ។

**សៈ** អម្បាញ់មិញនេះ <ហើយកាលពី>ម្សិលមិញ<ផង សហភាតារបស់ខ្ញុំលោកមេធាវី> កូប៉េ បានរំឭក<លោក>នូវចម្លើយរបស់ សយ សែន មួយចំនួន។ ខ្ញុំយល់ឃើញថា លោកបដិសេធចម្លើយរបស់គាត់ទាំងស្រុងតែម្តង។ ហើយឥឡូវនេះ ខ្ញុំសូមអានចម្លើយរបស់គាត់ដោយពាក្យពេចន៍ទាំងអស់តែម្តង ដែលលោក កូប៉េ គាត់មិនបានអានទាំងអស់ទេ <បន្ទាប់មក ខ្ញុំនឹងសួរលោក>។ ខ្ញុំសូមដកស្រង់សម្រង់ទី១ <ដោយ>លោក សយ សែន<> គឺថាឯកសារ E319.1.24 នៅចម្លើយ៧៨៖ សំណួរដែលចោទសួរលោក សយ សែន នៅពេលនោះ គឺថា៖ “តើ ឌុច តូច នេះបានប្រព្រឹត្តឧក្រិដ្ឋដែរឬទេ?” ចម្លើយរបស់លោក សយ សែន៖ “បាទ ឌុច ហ្នឹងក៏បានប្រព្រឹត្តឧក្រិដ្ឋហ្នឹងច្រើនជាងគេ។ គាត់បានរំលោភស្រីៗកងចល័តជាច្រើន ហើយក៏សាហាវជាងគេផងដែរ។ គាត់រំលោភពួកស្ត្រីទាំងអស់នោះហើយសម្លាប់ដោយយកគ្រាប់សេវេនធីណៃ ដាក់នៅក្នុងប្រដាក់ភេទជាដើមមុននឹងយកកប់។ <សាំង> ជាមេរបស់ ឌុច ហើយមានកូនទាហាន១២នាក់<រួមទាំងឌុចខ្លួនឯងដែរ>។” សូមបញ្ចប់ការដកស្រង់។

សំណួររបស់ខ្ញុំ -- ការអានរបស់ខ្ញុំ ប្រហែលជាមិនល្អ។ អ៊ីចឹង នៅក្នុងសម្រង់នេះ គឺជា -- ខ្ញុំសំដៅលើលោកហ្នឹងហើយ គឺឈ្មោះ សាំង។ សំណួរទី១របស់ខ្ញុំគឺដូចតទៅនេះ តើជាការត្រឹមត្រូវដែរឬទេ ដែលថាលោកជាប្រធានរបស់ ឌុចតូច ហើយដែលលោកហ្នឹងមានកូនទាហាន១២នាក់?

**ឆៈ** បាទ គឺខ្ញុំអត់មានកូនទាហានទេ ហើយក្នុងចម្លើយនេះ ក៏មិនពិតដែរបាទ។

[១៣:៣៧:៤៩]

**ស៖** ខ្ញុំសូមឲ្យលោក<>ចាំ<ប្រយោគ ដែលថា> "ឌុច បានប្រព្រឹត្តតែទៅលើស្ត្រីដែលចេញមកពីកងចល័តជាច្រើននោះ" ហើយអ៊ីចឹងខ្ញុំសូមដកស្រង់សម្រង់មួយទៀត ដែលជាចម្លើយរបស់លោក សយ សែន<។ តាមពិត នេះជាសក្ខីកម្មរបស់គាត់>ចំពោះមុខសវនាការ<> គឺថ្ងៃទី០៥ ខែ០២ ឆ្នាំ២០១៥ យើងនេះ ហើយនៅម៉ោង --សូមអភ័យទោស តាមពិតទៅគឺសវនាការថ្ងៃទី០៥ ខែ០២ គឺម៉ោងដប់សាមសិបប្រាំបី ហើយគឺឯកសារ E1/257.1 គឺប្រហែលមុនម៉ោងដប់សាមសិបប្រាំ -- សាមសិបប្រាំបីនាទីមួយភ្លែត បន្តិច ទាក់ទងទៅនឹងការរំលោភបំពាន<>ផ្លូវភេទ ដែលមានដាក់គ្រាប់<អឹម> ៧៩ ទៅក្នុងផ្លូវភេទនោះ។ សំណួរគេសួរទៅលោក សយ សែន ដូច្នេះទៅនេះ៖ "បាទ ខ្ញុំសូមការបំភ្លឺពីលោក ទៅលើអ្វីដែលលោកបាននិយាយកាលពីម្សិលមិញ។ លោកនិយាយថាមានទាហាន ឬក៏អ្នកយាមម្នាក់ បានរំលោភស្ត្រីពីរនាក់ ពីកងចល័ត ដែលបានដាក់ក្បាលគ្រាប់កាំភ្លើងសេវេនធីណៃ ចូលក្នុងប្រដាប់ភេទរបស់<សពនារីនោះ>។ តើលោកអាចជូនពីឈ្មោះទាហាន ដែលដាក់ក្បាលគ្រាប់កាំភ្លើងនោះបានឬទេ?" ចម្លើយរបស់លោក សយ សែន ឆ្លើយដូចតទៅនេះ៖ "បាទ គឺ ឌុចតូច និង សាំង ពួកគេនុំងពីរនាក់កាលនុំង"។ សូមបញ្ចប់ការដកស្រង់។

ជាថ្មីម្តងទៀត តើជាការត្រឹមត្រូវដែរឬទេក្នុងការនិយាយថា លោក ហើយនិង ឌុចតូចនេះ បានប្រព្រឹត្តការរំលោភបំពានផ្លូវភេទ ទៅលើស្ត្រីដោយញាត់គ្រាប់ ក្បាលគ្រាប់កាំភ្លើង<អឹម>សេវេនធីណៃចូលទៅក្នុងប្រដាប់ភេទរបស់គាត់?

**ឆ៖** បាទ គឺចម្លើយនេះមិនពិតទេបាទ។

[១៣:៤០:០៨]

**ស៖** បាទ សំណួរផ្សេងបន្តទៀត អម្បាញ់មិញនេះនៅពេលដែលលោកមេធាវី កូប៉េ លោកបានអាន អំពីការចោទប្រកាន់ទាំងអស់នេះទៅប្រាប់លោកៗនិយាយថាមិនត្រឹមត្រូវទេ ហើយលោកបដិសេធ ហើយលោកក៏ឆ្លើយផងដែរថា ប្រសិនជាអ៊ីចឹងមែននោះ ប្រហែលជា<ប្រជាពលរដ្ឋ>សងសឹកលោកបាត់ទៅហើយ។ បើអ៊ីចឹងសំណួរខ្ញុំដូចតទៅនេះ ក្រៅពីការចោទប្រកាន់ដែលគេ -- ដែល សយ សែន នេះចោទប្រកាន់ទៅលើលោកនោះ។ ខ្ញុំចង់សួរថាក្រៅពីការចោទប្រកាន់របស់លោក សយ សែន <ជាអ្នកនៅក្នុងសហគមន៍របស់លោក តើ>ក្នុងស្រុក <>ឃុំ <ឬតំបន់របស់លោក>រស់នៅនោះ ធ្លាប់មានអ្នកផ្សេងទៀតដែលចោទប្រកាន់មកលើលោកដែរឬទេ ក្រៅពីលោក សយ សែន នេះ?

**ឆ៖** បាទ ក្នុងសំណួរនេះ គឺគ្មានដែលបងប្អូនណាចោទប្រកាន់ខ្ញុំទេបាទ។

**ស៖** តើលោកធ្លាប់ឮការចោទប្រកាន់ដូចគ្នានេះទៅលើ ឌុចតូច ដែរឬទេ?

**ឆ៖** បាទ គឺអត់ដែលឮទេ។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយពីកំណត់ហេតុស្ដាប់ចម្លើយរបស់លោកជាដើមបណ្ដឹងរដ្ឋប្បវេណីគឺ ឯកសារ D22/88។ ខ្ញុំសូមបញ្ជាក់ថាជាបឋមខ្ញុំចាប់អារម្មណ៍ទៅផ្នែក(ខ) ដែលលេខ ERNជាភាសាបារាំងគឺ 01055815, ERN ជាភាសាខ្មែរគឺ <00354360>, ជាភាសាអង់គ្លេសគឺ 00379417។ នៅក្នុងទម្រង់បែបបទសុំព័ត៌មានលើជនរងគ្រោះនេះ គឺថាពេលគេបង្ហាញអំពីឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត លោកបញ្ជាក់ថា គឺថាមានសរសេរនៅក្នុងទម្រង់បែបបទនេះ ដែលលោកបានចុះហត្ថលេខា ថា "ការដាក់គុកខ្ញុំនៅមន្ទីរក្រាំងតាចាន់"។ បន្ទាប់មកទៀតផ្នែក(គ), ERN បន្តបន្ទាប់ៗនោះគឺថាជាភាសាបារាំងគឺ 01055816, ជាភាសាខ្មែរគឺ 00354361, ជាភាសាអង់គ្លេសគឺ 00379418។ បាទនៅក្នុងផ្នែក(គ)នេះ លោកនិយាយអំពីព្យសនកម្មដែលលោកបានទទួលរងដែលមានសរសេរដូចតទៅនេះ គឺឈឺក្បាល ឈឺដៃឆ្វេង ហើយនិងជង្គង់ឆ្វេងដោយអំបែងគ្រាប់។ ខ្ញុំសូមដកស្រង់ផ្នែកសម្រង់ទី៣ <ក្នុងចម្លើយ>គឺទំព័រចុងក្រោយនៃឯកសារដដែលហ្នឹងគឺ ERN ជាភាសាបារាំងនោះ គឺ លេខ 01055822, ជាភាសាខ្មែរគឺ00354366, ជាភាសាអង់គ្លេសគឺ 00379422។ នៅក្នុងផ្នែកនេះលោកពន្យល់អំពីមូលហេតុរបួសរបស់លោកដូចតទៅ៖ "ភ្នែកឆ្វេង ហើយនិង<ជង្គង់ខាងឆ្វេង>របស់ខ្ញុំ<>ឈឺចុកចាប់ដោយអំបែងគ្រាប់កាលពីខ្ញុំធ្វើជាកងទ័ពបម្រើបដិវត្តន៍នៅសម័យខ្មែរក្រហម"។ <បញ្ចប់ការដកស្រង់។> សំណួរជាក់លាក់របស់ខ្ញុំ សួរថាតើលោក<ត្រូវ>របួសដោ<យ>ត្រូវគ្រាប់ហ្នឹងនៅពេលណា? ហើយកាលនោះៗ គេចាត់តាំងឲ្យលោកធ្វើអ្វីដែរ?

[១៣:៤៥:០៥]

**ឆ៖** បាទ ខ្ញុំត្រូវរបួសក្នុងឆ្នាំ១៩៧៣ ដែលប្រយុទ្ធជាមួយទាហាន លន់ នល់ នៅខេត្តតាកែវនេះបាទ។

**ស៖** អ៊ីចឹងយើងច្បាស់ហើយ គឺថាព្យសនកម្មរបស់លោក គឺថានេះដែលលោកទទួលរងនេះមិនមែនទាក់ទងនឹងរយៈពេលដែលលោកធ្វើការនៅគុកក្រាំងតាចាន់ទេ។ យើងយល់ស្របនឹងគ្នាទេ?

**ឆ៖** បាទ សមស្របហើយ។

**ស៖** អម្បាញ់មិញនៅពេលដែលលោកនិយាយអំពីមូលហេតុមួយដែលលោកសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ លោកបានឆ្លើយថាដោយសារឪពុករបស់លោកស្លាប់ ហើយនិងក្រុមគ្រួសារ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

របស់លោកស្លាប់ផងដែរ។ អ៊ីចឹងសំណួរទី១របស់ខ្ញុំនោះ ខ្ញុំសូមសួរលោកថាតើលោកមានសមាជិកគ្រួសារណាមួយដែលបានឃុំខ្លួននៅមន្ទីរគុកក្រាំងតាចាន់ដែរឬទេ?

**ឆ៖** បាទ នៅក្នុងមន្ទីរក្រាំងតាចាន់មានបងប្អូនជីដូនមួយ គឺកូនលោកពូខ្ញុំតែម្តងបាទ។

[១៣:៤៦:៤៨]

**ស៖** គឺនៅក្នុងពេលដែលលោកធ្វើការនៅមន្ទីរក្រាំងតាចាន់ហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** បាទ ពិតហើយ។

**ស៖** អ៊ីចឹងហេតុអីក៏លោកមិនបានឆ្លើយនៅក្នុង<>ទម្រង់បែបបទដែលលោកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីហ្នឹងទៅ?

**ឆ៖** បាទ ក្នុងនោះ ខ្ញុំដាក់យកតែឪពុកខ្ញុំកាលជំនាន់២០៤ មកទេបាទ។

**ស៖** លោកមិនបានឆ្លើយនឹងសំណួរខ្ញុំទេ។ អ៊ីចឹងខ្ញុំសួរលោកថាហេតុអីក៏លោកមិនបាននិយាយអំពីក្រុមគ្រួសាររបស់លោកដែរ<>នៅក្នុងទម្រង់បែបបទដែលលោកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេ-ណីនេះ <ព្រោះលោកនិយាយអំពីរយៈពេលដែលលោកធ្វើការនៅក្រាំងតាចាន់>?

**ឆ៖** ខ្ញុំមូលហេតុខ្ញុំមិនដាក់ឈ្មោះបងជីដូនមួយខ្ញុំ ខ្ញុំលើកយកតែឈ្មោះឪពុកខ្ញុំយកមកដាក់ក្នុងដើមបណ្តឹងនេះទេបាទ។

**ស៖** <>ឪពុករបស់លោក លោកបានបញ្ជាក់អម្បាញ់មិញនេះ ថាគាត់ស្លាប់នៅឆ្នាំ១៩៧៣ នោះទេ។ អ៊ីចឹង<>នេះគឺលោកមិនទាន់បានធ្វើការនៅមន្ទីរក្រាំងតាចាន់ទេ។ លោកយល់ស្របទេ?

**ឆ៖** បាទ ក្នុងឆ្នាំ៧៣ ខ្ញុំបាទមិនទាន់ធ្វើនៅមន្ទីរនៅក្រាំងតាចាន់នេះទេបាទ ពិតហើយ។

[១៣:៤៨:៥០]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសួរចប់ហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកែតម្រូវតូចមួយទាក់ទងទៅនឹងអ្វីដែលទើបតែបានបកប្រែ។ ខ្ញុំឮការបកប្រែទៅជាភាសាអង់គ្លេសថា គ្រាប់៧៩ ដល់ពេល <ក្នុងភាសាអង់គ្លេស គេនិយាយថា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គ្រាប់អឹម៧៩>-- <>មិនមែនជាគ្រាប់៧៩ ទេ គឺគ្រាប់អឹម -- គ្រាប់បែក គ្រាប់សេវេនធីណៃ – ៧៩ នេះ។ <នេះគ្រាន់តែជាការកែតម្រូវសម្រាប់ប្រតិចារឹកប៉ុណ្ណោះ។>

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៣:៤៩:៥៣]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំមានសំណួរខ្លី សួរបន្តពីមេធាវី ហ្គីសសេ – អង់តា ហ្គីសសេ។ លោកដើមបណ្ដឹងរដ្ឋប្បវេណី លោកអាចជម្រាបអំពីឈ្មោះក្រុមគ្រួសាររបស់លោក ដែលត្រូវបានឃុំខ្លួននៅមន្ទីរក្រាំងតាចាន់ដែរឬទេ? តើ<លោកអាចបញ្ជាក់ឲ្យច្បាស់ថាពួកគាត់ជាប់សាច់ឈាមយ៉ាងម៉េចជាមួយលោក? តើពួក>គាត់ស្លាប់នៅពេលដែលលោកធ្វើការនៅមន្ទីរក្រាំងតាចាន់នោះ ឬក៏យ៉ាងណា?

**លោក សូត្រ សាំង៖**

**ឆ៖** បាទ ឈ្មោះ កូនពួយន់ មីងមុិច ជាឪពុកមាររបស់ខ្ញុំ។ កូនគាត់មួយឈ្មោះ បងជា១ ធ្វើទាហានលន់ នល់ គេបានចាប់សម្លាប់នៅក្នុងក្រាំងតាចាន់បាទ។

**ស៖** ខ្ញុំឮ<ថា>បងប្អូនជីដូនមួយ<>ប្រុស<ឬ>ស្រី<?> ខ្ញុំយល់មិនសូវច្បាស់ លោកជួយបញ្ជាក់ម្ដងទៀតបានទេ?

**ឆ៖** បាទ នៅក្នុងនោះ បើយកមនុស្សមានដូចកូនពូចាន់ ក៏នៅក្នុងហ្នឹងដែរ កូនមីងមុិចខ្ញុំនេះ ក៏នៅក្នុងហ្នឹងដែរ បាទ។

**ស៖** <ខ្ញុំយល់ថាកូន>មីង <យ៉េត គឺ>ពូ<យន់ ឬក៏ខ្ញុំយល់ច្រឡំទេ? ឬក៏កូនពូយន់>ហ្នឹងឈ្មោះ មីង<យ៉េត> ឬក៏យ៉ាងម៉េច ខ្ញុំអត់សូវយល់ទេ សូមលោកនិយាយម្ដងទៀតមើល?

**ឆ៖** បាទ កូនមីងមុិច ហ្នឹងគឺឈ្មោះបងជា តែពួយន់ ជាគ្រួសាររបស់មីងមុិច។

**ស៖** ហើយគាត់ឈ្មោះអី?

**ឆ៖** បាទ ដែលស្លាប់ហ្នឹងគឺឈ្មោះ បងជា។

**ស៖** អ៊ីចឹងគាត់ស្លាប់ហ្នឹង នៅពេលដែលលោកធ្វើការនៅមន្ទីរក្រាំងតាចាន់ ស្លាប់ដោយគាត់ឈឺ ឬក៏ដោយសារគេសម្លាប់? តើមានរឿងអីកើតឡើងនៅពេលនោះ?

**ឆ៖** បាទ ស្លាប់នៅពេលនោះ ស្លាប់ដោយសារគេសម្លាប់ទេបាទ។

**ស៖** តើលោកមានបានដឹងរឿងលម្អិតអំពីការសម្លាប់<>គាត់ទេ? <តើរឿងនេះកើតឡើងនៅពេលណា?> តើ<>គាត់ត្រូវបានគេសួរចម្លើយ <ឬ>ធ្វើទារុណកម្មដែរឬទេ? តើមានរឿងអីកើតឡើងទៅ សូមរៀបរាប់ជូនតុលាការបន្តិចមក។

**ឆ៖** ខ្ញុំអត់ដឹងរឿងហ្នឹងដែរ គេរឿងជាមួយគាត់។ ប៉ុនគ្រាន់តែថា កាលជំនាន់ខ្ញុំទៅនៅហ្នឹង ឮក្រោយមក ឮគេថាគាត់នេះធ្វើទាហានលន់នល់ ពាក់ព័ន្ធទាហានលន់នល់ គេយកទៅសម្លាប់ចោលនៅទីនោះបាទ។

[១៣:៥៣:៤២]

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសួរលោក ថាតើលោកមានវត្តមាននៅក្រាំងតាចាន់ដែរឬទេ នៅពេលដែលក្រុមគ្រួសាររបស់លោកត្រូវបានគេចាប់ខ្លួនឃុំខ្លួននៅទីនោះ? លោកឆ្លើយថា បាទ។ ឥឡូវនេះ ខ្ញុំត្រូវយល់ថាម៉េច? <ខ្ញុំ>ត្រូវយល់ថា កាលនោះ កាលដែលចាប់ពួកគាត់ទៅនោះ ឃុំខ្លួននោះ លោកនៅធ្វើការនៅក្រាំងតាចាន់ហ្នឹងហើយ ឬក៏លោកមិនទាន់ទៅធ្វើការនៅក្រាំងតាចាន់នោះទេ?

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា ខ្ញុំនៅធ្វើការក្រាំងតាចាន់នេះហើយ។ ក្រោយមកបានគាត់ -- គេចាប់គាត់យកមកដាក់មន្ទីរឃុំឃាំងក្រាំងតាចាន់នេះ បាទ។

**ស៖** បាទ សូមអរគុណ។ តើ តាអាន់ ដែលជាប្រធានគុកហ្នឹង ដឹងថាលោកហ្នឹងជាបងប្អូននឹងអ្នកទោសហ្នឹងទេ?

**ឆ៖** បាទ គាត់អត់ដឹងទេ ពីព្រោះអត់មានពីណាប្រាប់គាត់ទេបាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណ ខ្ញុំអស់សំណួរហើយលោកប្រធាន។

[១៣:៥៥:០៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំមានសំណួរបន្តមួយ ព្រោះថាខ្ញុំអម្បាញ់មិញយល់មិនសូវច្បាស់។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក សូត្រ សាំង លោកទើបតែឆ្លើយថា<បងប្អូន>ជីដូនមួយរបស់លោកត្រូវបានឃុំខ្លួន

ហើយ<ត្រូវ>សម្លាប់នៅមន្ទីរក្រាំងតាចាន់។ អ៊ីចឹង នៅពេលដែលលោកនិយាយថា "ក្រោយមក" ហើយនេះ។ អ៊ីចឹងលោកចង់និយាយថា ក្រោយពេលដែលលោកឈប់ធ្វើការនៅក្រាំងតាចាន់ <ហើយក្រោយមក ទើបលោកដឹងថា គាត់ត្រូវជាប់ឃុំ ហើយត្រូវបានសម្លាប់នៅទីនោះ, អ៊ីចឹងមែនទេ>?

[១៣:៥៥:៥០]

**លោក គឹម ម៉េងឃី៖**

សូមៗទោសលោកប្រធាន!

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញ!

**លោក គឹម ម៉េងឃី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមកាត់បន្តិច ដោយសារថា ស្ដាប់ជាភាសាខ្មែរ ហើយមានការបកប្រែ ក៏ប៉ុន្តែអ្វីដែលខ្ញុំស្ដាប់បាន គឺដើមបណ្ដឹងនិយាយថា គាត់ចូលធ្វើការ។ ហើយក្រោយមក គឺគាត់នៅធ្វើការហ្នឹងដដែល គឺត្រូវបងប្អូនគាត់ហ្នឹងចាប់ មិនមែនគាត់ចេញ ឈប់ពីធ្វើការកន្លែងហ្នឹងទេ។ ដូច្នេះមិនមានការបញ្ជាក់លើសហ្នឹងទេ។ សំណួររបស់គាត់ប្រហែលជាគាត់យល់ច្រឡំថា គាត់ចេញហើយបានដឹង តែការពិតគឺគាត់នៅទីនុ៎ងទេ។ អ្វីខ្ញុំបានស្ដាប់កូនក្ដីរបស់ខ្ញុំបកស្រាយជាភាសាខ្មែរមុននេះបាទ។ សូមអរគុណ។

[១៣:៥៦:៤៦]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមអរគុណលោកមេធាវី ដែលបានចង់បំភ្លឺបញ្ហានេះ ក៏ប៉ុន្តែលោក ស្វូត្រ សាំង នៅទីនេះហើយនិង ខ្ញុំគិតថាប្រហែលជាងាយស្រួលជាងដែលឲ្យគាត់បំភ្លឺចំណុចនេះតែម្ដង។ ខ្ញុំសួរសំណួរនេះម្ដងទៀត ព្រោះមានចំណុចមួយដែលមិនច្បាស់។

**សួរបន្តដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក ស្វូត្រ សាំង នៅពេលណាដែលលោកដឹងថា បងប្អូនជីដូនមួយលោកហ្នឹង ត្រូវបានឃុំខ្លួននៅ -- សម្លាប់នៅក្រាំងតាចាន់ គឺនៅពេលដែលលោកនៅធ្វើការនៅទីនោះដែរ ឬក៏ក្រោយពេលដែលលោកចាកចេញពីមន្ទីរក្រាំងតាចាន់នេះហើយបានៗដឹងថាគាត់ហ្នឹងជាប់ឃុំឃាំង ហើយត្រូវបានគេ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សម្លាប់នៅទីនោះ?

**លោក សូត្រ សាំង៖**

**ឆ៖** បាទ ខ្ញុំនៅការនៅក្នុងក្រាំងតាចាន់ហ្នឹង។ តែក្រោយមកបានខ្ញុំគេចាប់គាត់បញ្ជូនចូលទៅក្នុងក្រាំងតាចាន់ហ្នឹងបាទ។

**ស៖** រហូតដល់ពេលនេះ ខ្ញុំនៅតែតាមលោកទាន់ ក៏ប៉ុន្តែឥឡូវនេះ សំណួរអម្បាញ់មិញ ខ្ញុំសួរនោះ ខ្ញុំសួរថាតើនៅពេលណាដែលលោកបានដឹង<ថាគេសម្លាប់គាត់>?

**ឆ៖** បាទ ដឹង ក្នុងដឹង -- ខ្ញុំដឹងគាត់ស្លាប់បាត់ចេញពីមន្ទីរហ្នឹង បានថាខ្ញុំដឹងថាគាត់ស្លាប់ពីព្រោះក្នុងមន្ទីរហ្នឹងកម្រអ្នករួចណាស់បាទ។ បាទ ខ្ញុំដឹងថាបាត់ពីកន្លែងនេះហើយ ប្រហែលជាស្លាប់ហើយ ប៉ុន្តែដល់ថ្ងៃណា -- បាត់ពីថ្ងៃណា ឬខែណា ខ្ញុំអត់បានតាមដានកត់ត្រាទុកទេបាទ។

**ស៖** តើអ្នកណាអ្នករៀបរាប់ប្រាប់លោកអំពីការបាត់ខ្លួនគាត់នេះ?

**ឆ៖** បាទ អត់មានអ្នកណាប្រាប់ទេ តែពេលគេបញ្ចេញមកធ្វើការ អត់ឃើញមកធ្វើការ ហើយបាត់រហូតទល់ការដែលខ្ញុំចេញ ចាកចេញទៅទ័ពវិញតែម្តងបាទ។

[១៣:៥៩:១៥]

**ស៖** ដូច្នេះ បើខ្ញុំយល់មិនច្រឡំទេ គឺថាមិនមានអ្នកណាប្រាប់លោកថា គាត់ត្រូវបានសម្លាប់ខ្លួននោះទេ គឺថាលោកខ្លួនឯងទាញការសន្និដ្ឋានដោយសារថា លោក ពេលក្រោយមកលោកមិនបានឃើញគាត់<ទៀតទេ>។ អ៊ីចឹងត្រឹមត្រូវដែរឬទេ ការសង្ខេបរបស់ខ្ញុំនេះ?

**ឆ៖** បាទ ការសម្គាល់របស់ខ្ញុំ តែបាត់ពីភ្នែកៗយើងឃើញហើយពិតជាមិនរួចខ្លួនទេ ពិតជាស្លាប់ហើយ។

**ស៖** ខ្ញុំចោទសំណួរម្តងទៀត អ៊ីចឹងគឺថាលោកសន្មតទេ គឺ<>គ្មានអ្នកណាប្រាប់លោកថា គាត់ហ្នឹងត្រូវបានគេយកទៅសម្លាប់ទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ពិតមែន។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសួរចប់ហើយលោកប្រធាន សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោក សូត្រ សាំង ក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណី លោកអាចថ្លែងរៀបរាប់ជូនដល់

អង្គជំនុំជម្រះស្តាប់ អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ចំពោះជនជាប់ចោទពីររូបគឺ នួន ជា និង ខៀវ សំផន ដែលបានធ្វើឲ្យប៉ះពាល់ចំពោះលោកក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលនាំឲ្យលោកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណងជំងឺចិត្ត និងជាសម្ពហភាពពីជនជាប់ចោទ និងពីស្ថានភាពព្យសនកម្មដែលមានជាអាទិ៍ចំពោះការខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត និងផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋព្យសនកម្មផ្ទាល់ខ្លួនដែលបានកើតឡើងមានពិតប្រាកដរហូតដល់សព្វថ្ងៃនេះ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។

[១៤:០១:៥៥]

**លោក សូត្រ សាំង៖**

បាទ ខ្ញុំសូមជម្រាបអង្គតុលាការ សូម -- ជាដើមបណ្តឹងរបស់ខ្ញុំ ខ្ញុំសោកស្តាយឪពុកបងប្អូនជីដូនមួយ ឬមីងមា ទាំងរូបខ្ញុំខំតស៊ូដើម្បីជាតិមាតុភូមិ បង្ហូរឈាមដើម្បីមាតុភូមិរបស់ខ្លួន ធ្វើអំពើឃោរឃៅព្រៃផ្សៃ ខ្មែរសម្លាប់ខ្មែររបៀបនេះ ខ្ញុំអត់ទទួលស្គាល់យកបានទេបាទ។

ក្នុងនោះទៀត ខ្ញុំសូមអំពាវនាវគ្រប់ស្ថាប័នរបស់រដ្ឋដែលសំណាងកសាងជាតិមាតុភូមិរបស់ខ្លួន ដើម្បីឲ្យជនរងគ្រោះពលរដ្ឋដែលរងគ្រោះទាំងអម្បាលម៉ានដូចរបស់ខ្ញុំ សូមឲ្យជួយទាមទារទាល់តែបានបាទ។

ក្នុងរដ្ឋប្បវេណីនេះ ខ្ញុំស្តាយមួយជីវិត ដើម្បីជាតិមាតុភូមិរបស់ខ្ញុំ គឺខ្ញុំចាំមិនបំភ្លេចបានទេបាទ ក្នុងលក្ខណៈខ្ញុំខំតស៊ូដើម្បីកងទ័ពកាលជំនាន់នោះគឺវេទនាជាទីបំផុត គ្មានសម័យណាប្រៀបបានទេ។ វេទនាទាំងបាញ់ប្រហារ វេទនាទាំងកប៉ាល់ហោះ វេទនាទាំងស្បៀងអាហាររស់នៅ ហូបចុកបុកទំពារសព្វគ្រប់បែបយ៉ាង។ ដើម្បីថាជាតិដឹកនាំឲ្យបានល្អ។ ផ្ទុយទៅវិញ ជាតិខ្មៅកង្វក់ដូចភក់នៅក្នុងបាតត្រពាំងអ៊ីចឹង។ ក្នុងនោះហើយ ខ្ញុំសុំ ហើយទទូចសុំទៀតដើម្បីរកភស្តុតាង រកការដែលសម្លាប់ពលរដ្ឋទូទាំងប្រទេសរបស់ខ្ញុំហ្នឹងឲ្យឃើញ ឲ្យបានពិតប្រាកដ។ ហើយក្នុងសំណាងកសាងជាតិមាតុភូមិខ្ញុំបាទឲ្យបានថ្កុំថ្កើងរុងរឿងដូចខាងដើមអ៊ីចឹងបាទ។ សូមអស់។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមអរគុណចំពោះលោក សូត្រ សាំង ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរយៈពេលពីរថ្ងៃមកនេះ។ សក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ការផ្តល់សក្ខីកម្មរបស់លោកបានដល់ទី

បញ្ចប់ហើយ វត្ថុមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិល ត្រឡប់ទៅលំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ ហើយសូមលោក ធ្វើដំណើរវិលត្រឡប់ទៅវិញដោយសុវត្ថិភាព។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនលោក ស៊ូត្រ សាំង វិលត្រឡប់ទៅលំនៅដ្ឋាន ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅ បានហើយ។

ហើយអង្គជំនុំជម្រះសូមអរគុណចំពោះលោក ញ៉ែម សំណាង បុគ្គលិកគាំពារសាក្សី និងអ្នក ជំនាញដែលបានជួយសម្របសម្រួលឧបករណ៍បំលែងសំឡេង ក្នុងអំឡុងធ្វើសវនាការស្តាប់សក្ខីកម្ម ស៊ូត្រ សាំង រយៈពេលពីរថ្ងៃកន្លងមកនេះ។ ហើយការស្តាប់សក្ខីកម្ម ស៊ូត្រ សាំង បានចប់ហើយ លោក អាចសម្រាកបានហើយ។ ហើយមុនពេលលោក ស៊ូត្រ សាំង ចាកចេញបុគ្គលិករដ្ឋបាលដែលគាំទ្រកិច្ច ដំណើរការសវនាការរូតវាំងនន បាំងខណ្ឌបន្ទប់សវនាការ និងសាលសវនាការសម្រាប់សាធារណជន ហើយក្រោយពី ស៊ូត្រ សាំង ចាកចេញទៅបើវាំងននវិញ និងឲ្យយករបាំងឡប់ឡៃដាក់បាំងដើមបណ្តឹង រដ្ឋប្បវេណីចេញពីបន្ទប់សវនាការវិញចុះ។ ហើយនិងបង្គាប់ឲ្យបុគ្គលិកផ្នែកសោទស្សន៍ និងសំឡេង ភ្ជាប់សំឡេង និងរូបភាពទៅសាធារណជនធម្មតាឡើងវិញ។

[១៤:០៥:១៨]

*(សម្រាករយៈពេលខ្លី)*

[១៤:០៨:១៥]

**ប្រធានអង្គជំនុំ៖**

បាទ រូតបើកវាំងននវិញ ហើយនិងឲ្យអញ្ជើញ សយ សែន ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅ ក្នុងបន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តទៅនេះ យើង អង្គជំនុំជម្រះ ធ្វើសវនាការបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី សយ សែន។ ហើយអង្គជំនុំជម្រះ សូមជម្រាបភាគីសាធារណជនថា លោក សយ សែន ដើមបណ្តឹងរដ្ឋ ប្បវេណីរូបនេះ ត្រូវបានអង្គជំនុំជម្រះស្តាប់សក្ខីកម្មចាប់ពីវគ្គទី២ ថ្ងៃៗទី០៤ ខែកុម្ភៈ រហូតដល់ថ្ងៃទៅ

០៦ ខែកុម្ភៈ ឆ្នាំ២០១៥។ ប៉ុន្តែដោយសារមានបញ្ហាពីរ បញ្ហាទី១ គឺពាក់ព័ន្ធទៅមួយនឹងបុគ្គលដទៃផ្សេងទៀត ដែលធ្វើការនៅអតីតជាបុគ្គលិកធ្វើការនៅមន្ទីរសម្លាប់មនុស្សក្រាំងតាចាន់ ហើយនិងបញ្ហាទី២ មានការស្នើសុំវិធានការការពារ។ ហេតុដូច្នេះហើយ បានជាមានការលើកពេលធ្វើសវនាការដោយពិចារណាលើសំណើសុំ ហើយនិងមានការស្តាប់នូវអនុសាសន៍របស់ខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ប៉ុន្តែចុងក្រោយឃើញថា សយ សែន បានផ្លាស់ប្តូរជំហរវិញ គឺថាគាត់សុខចិត្តដកនូវសំណើសុំវិធានការការពារ។ អ៊ីចឹងហើយទើបថ្ងៃនេះ យើងធ្វើការសវនាការស្តាប់សក្ខីកម្ម សយ សែន ដើមបណ្តឹងរដ្ឋប្បវេណីនេះជាសាធារណៈ។

ហើយអង្គជំនុំជម្រះ ផ្តល់វេទិកាជូនទៅក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី រួមទាំងៗសហព្រះរាជអាជ្ញា មានពេលវេលាមួយម៉ោង ក្នុងការសួរចុងក្រោយ សួរសក្ខីកម្មសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ ដើមបណ្តឹងរដ្ឋប្បវេណី -- មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[១៤:១៣:១០]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ <សហភាតារបស់ខ្ញុំគឺលោកស្រី>មេធាវី ម៉ុច សុវណ្ណារី ជាអ្នកសួរលោក សយ សែន លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ ម៉ុច សុវណ្ណារី!

**លោកស្រី ម៉ុច សុវណ្ណារី៖**

ចាស សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ុច សុវណ្ណារី៖**

**ស៖** ជាដំបូង សូមគោរពដល់អង្គសវនាការទាំងមូល ហើយសូមជម្រាបសួរដល់លោកពូ សយ សែន។ នៅថ្ងៃនេះ នាងខ្ញុំមានសំណួរមួយចំនួន ដើម្បីសួរបន្ថែមទៅ នឹងអ្វីដែលលោកពូបានថ្លែងកាលពីសវនាការពីលើកមុនៗ។ ដូចដែលលោកប្រធានអង្គជំនុំជម្រះបាន ជម្រាបថា លោកពូបានសម្រេចចិត្តនៅក្នុងការដកពាក្យស្នើសុំវិធានការការពារខ្លួនរបស់លោកពូ។ អ៊ីចឹង នេះអាចធ្វើឲ្យគេអាចសន្និដ្ឋានបាន

ថា លោកពូហាក់ដូចមិនមានការភ័យខ្លាចតទៅទៀត។ អ៊ីចឹងសំណួរដំបូង ដែលនាងខ្ញុំចង់សួរទៅលោកពូ ដើម្បីជម្រាបជូនអង្គសវនាការនៅពេលនេះ គឺចង់សួរលោកពូថា តើមូលហេតុអ្វីបានជាលោកពូលែងភ័យខ្លាច ហើយអាចបន្តថ្លែងសក្ខីកម្ម ទាក់ទងជាមួយនឹងអត្តសញ្ញាណរបស់កម្មាភិបាលខ្មែរក្រហម ដែល ធ្វើការនៅគុកក្រាំងតាចាន់ ក៏ដូចជាអង្គហេតុដែលកើតមានឡើងនៅគុកក្រាំងតាចាន់ នៅក្នុងសវ-នាការសាធារណៈនេះបាន? តើមូលហេតុអ្វី?

**លោក សយ សែន៖**

**ឆ៖** បាទ បានខ្ញុំលែងភ័យ លែងខ្លាច ខ្ញុំដូចថាវាលែងខ្លាច លែងខ្វល់ លែងអីខ្វល់អីទាំងអស់ បាទ ព្រោះអានេះវារឿងវាឮសូរសុះសាយទូទាំងប្រទេសកម្ពុជាហើយ បានខ្ញុំលែងខ្វល់។

[១៥:១៥:៥៥]

**ស៖** ចាស សូមអរគុណលោកពូ។ អ៊ីចឹងសំណួរខ្ញុំជាបន្តទៅទៀតនេះ ខ្ញុំចង់សួរទាក់ទងជាមួយនឹងទំនាក់ទំនងរបស់លោកពូ ដែលលោកពូមានជាមួយនឹងអតីតកម្មាភិបាលខ្មែរក្រហម ដែលធ្វើការនៅក្នុងគុកក្រាំងតាចាន់។ អ៊ីចឹងខ្ញុំចង់សួរលោកពូថា នៅក្នុងពេលដែលលោកពូជាប់នៅក្នុងគុកក្រាំងតាចាន់នោះ គឺនៅក្នុងសម័យខ្មែរក្រហម តើលោកពូមានទំនាក់ទំនងយ៉ាងដូចម្តេចជាមួយនឹងអតីតកម្មាភិបាលខ្មែរក្រហមទាំងមូល ហើយជាពិសេសខ្ញុំសូមជម្រាបឈ្មោះទី១ ដូចជាជាមួយនឹងលោក ឌុចតូច។ ទី២ ទាក់ទងជាមួយនឹងលោក សូត្រ សាំង និងទី៣ទាក់ទងជាមួយនឹង តាឆេន ដែលលោកបានអះអាងថា គឺជាអតីតប្រធាន គឺជាប្រធានគុកមុនដំបូងគេ?

**ឆ៖** បាទ ទី១ ទាក់ទងជាមួយ តាឆេន គាត់ជាប្រធានគុកមុនដំបូងគេ គឺគាត់ស្នាដៃរបស់គាត់ដែលគាត់ធ្វើអ្វីៗមួយខ្ញុំអត់ដែលឃើញទេ បើសិនណាបើគាត់ជាអ្នកប្រធានគាត់មិនដែលធ្វើអ្វីឲ្យយើងឃើញ ប៉ុន្តែគាត់បានប្រាប់ គាត់តែងថាឲ្យ ចុងបញ្ចប់ហ្នឹងគាត់ផ្តាំផ្ញើថាទុកខ្ញុំជាសម័យសព្វថ្ងៃនេះ គាត់ទុកខ្ញុំជាកូនគាត់ កុំមកនិយាយការងារអ្វីៗមួយកុំឲ្យប៉ះពាល់ជាមួយគាត់ តែប៉ុណ្ណឹងបានហើយបាទ បានផ្តាំផ្ញើមកខ្ញុំនិយាយតែប៉ុណ្ណឹងបាទ។

**ស៖** អ៊ីចឹងទាក់ទងជាមួយនឹងបុគ្គលឈ្មោះ សូត្រ សាំង តើលោកពូមានទំនាក់ទំនងយ៉ាងដូចម្តេចដែរជាមួយនឹងគាត់នៅក្នុងសម័យនោះ ហើយសម័យបច្ចុប្បន្ននេះ តើទំនាក់ទំនងរបស់លោកពូជាមួយនឹងគាត់យ៉ាងម៉េចដែរ?

**ឆ៖** បាទចំពោះ សូត្រ សាំង គឺសម័យមុនវាសម័យឧក្រិដ្ឋកម្ម វាបើនិយាយមិនថាចំពោះ សូត្រ

សាំង ទេទោះបីអ្នកទាំងអស់គ្នាដែលប៉ុន្មាននាក់ហ្នឹងគឺទូទៅទាំងអស់បាទ គឺគាត់ប្រើដាច់អហង្ការ ចង់ប្រើអីប្រើទៅ ចង់ធ្វើអីធ្វើទៅស្រេចគាត់ ហើយមកសម័យឥឡូវវាខុសប្លែកគ្នាច្រើនតែប៉ុណ្ណឹងបាទ។

**ស៖** ចាស សូមអរគុណលោកពូ។ ខ្ញុំចង់សួរសំណួរបន្តទៀតថា ឆ្លងកាត់សម័យហ្នឹងហើយរហូត មកទល់ពេលនេះ តើលោកពូមានអារម្មណ៍យ៉ាងម៉េចដែរចំពោះពួកគេទាំងអស់គ្នាដែលជាកម្មាភិបាលខ្មែរក្រហមនៅរស់រានមានជីវិត ថាតើលោកពូខឹង លោកពូស្អប់ពួកគេ ឬក៏យ៉ាងដូចម្ដេចដែរ? ពីអារម្មណ៍ ដែលលោកពូមានចំពោះពួកគេ?

[១៤:១៧:២៨]

**ឆ៖** បាទ សព្វថ្ងៃបុគ្គលខ្ញុំ ទោះបីគាត់បានធ្វើអំពើណាមួយទៅលើខ្ញុំ ទារុណកម្មចំពោះខ្ញុំ ហើយឬបងប្អូនទាំងអស់ គ្រប់គ្នាទាំងអស់ ប៉ុន្តែខ្ញុំយល់ទៅតាមសង្គមរបស់គាត់អ្នកដឹកនាំ ហើយរបបគេរបបមិនដែលឃើញនោះ ខ្ញុំយល់ទៅតាមហ្នឹងដែរ ខ្ញុំអត់មានតាមគំនុំគុំគួនចំពោះគាត់ក៏អត់ដែរសម័យបច្ចុប្បន្ន គឺគាត់រស់នៅទៅតាមសង្គមជាអ្នកដឹកនាំបាទ។

**ស៖** ចាស សូមអរគុណលោកពូ។ អ៊ីចឹង ខ្ញុំចង់ត្រឡប់ទៅពេលវេលាមុនពេលបើកសវនាការនេះ នៅពេលដែលលោកពូសម្រេចចិត្តនៅក្នុងការឡើងមកថ្លែងសក្ខីកម្មនៅចំពោះអង្គជំនុំជម្រះសាលាដំបូងនៅពេលនេះ ខ្ញុំចង់សួរលោកពូថា នៅពេលដែលលោកពូសម្រេចចិត្តដំបូងនៅក្នុងការឡើងមកធ្វើសក្ខីកម្មនៅទីនេះ នៅពេលនេះ ថាតើលោកពូសម្រេចចិត្តដោយស្ម័គ្រចិត្ត ឬក៏មានកត្តាអ្វីដែលជំរុញឲ្យលោកពូត្រូវសម្រេចចិត្តឡើងមកធ្វើសក្ខីកម្ម?

**ឆ៖** បាទ ខ្ញុំឡើងមកសក្ខីកម្មនៅតុលាការនេះ គឺដើម្បីអត់មាននរណាមួយគឺបង្ខិតបង្ខំ ឬដើម្បីបុគ្គលខ្ញុំផ្ទាល់ក៏អត់មានដែរ ខ្ញុំមកនេះមកដើម្បីខាតការងារផ្ទាល់និងជីវភាពការគ្រួសាររបស់ខ្ញុំ។ ប៉ុន្តែ ខ្ញុំមកបំភ្លឺពីសម័យឧក្រិដ្ឋកម្ម និងក្មេងស្រករក្រោយក៏មិនដែលឃើញ បាទហើយនិងសូមអត់ទោសតុលាការខ្លះក៏មិនដែលជួបឧបសគ្គហ្នឹងដែរ អត់ទាន់ៗជួបបញ្ហាសង្គមរបស់គេទាំងអស់នេះ។ បាទ ខ្ញុំមកៗដើម្បីបំភ្លឺ និងសម្ដែងការស្វែងរកការពិត កន្លែងពិតបានខ្ញុំនិយាយ បើមិនពិតខ្ញុំអត់និយាយបានទេបាទ។

[១៤:១៩:១៥]

**ស៖** សូមអរគុណលោកពូ សំណួរចុងក្រោយរបស់ខ្ញុំៗចង់សួរលោកពូថានៅពេលដែលលោកពូឡើងមកធ្វើសក្ខីកម្មជាសាធារណៈនៅចំពោះមុខអង្គជំនុំជម្រះនៅៗក្នុងសាលាក្ដីខ្មែរក្រហមនេះ ក្រៅពី

ការដែលលោកពូបានប្រឈមមុខជាមួយនឹងការភ័យខ្លាច ដូចដែលបានឃើញនៅក្នុងសវនាការកាលពីប៉ុន្មានសប្តាហ៍មុន តើការណ៍ដែលលោកពូឡើងមកធ្វើសក្ខីកម្មនៅទីនេះ តើបានផ្តល់ផលប្រយោជន៍អ្វីខ្លះជូនទៅដល់បុគ្គលរបស់លោកពូផ្ទាល់ខ្លួន? ឬក៏ទៅដល់នរណាម្នាក់? តើមានផលប្រយោជន៍អ្វីដែលលោកពូ ឡើងមកថ្លែងសក្ខីកម្មនៅទីនេះ?

**ឆ៖** បើតាមខ្ញុំឡើងមកធ្វើសក្ខីកម្ម បើតាមខ្ញុំគិត និងពិចារណាខ្លួនឯង ថាអត់មាន។ ចំណែកបុគ្គលខ្ញុំ គឺអត់មានសោះ អត់មាន។ បានត្រឹមផលប្រយោជន៍បានទៅលើអ្នករងគ្រោះពីជំនាន់នោះ ដែលស្លាប់ឡើងរង្គាល អ្នកនៅតាមគុកនីមួយៗគ្រប់ខេត្ត គ្រប់ស្រុកទាំងអស់។ បើខ្ញុំឡើងមកដើម្បីជំនួសមុខដែលអ្នកដែលបានចែកឋានទាំងអស់ហ្នឹង។ រឿងចំណែកបុគ្គលខ្ញុំនៅរស់នៅសព្វថ្ងៃ គឺអត់ដែលមានអីផ្តល់ផលប្រយោជន៍ដើម្បីខ្ញុំ អត់មានទេ អត់មានសោះ។ ខ្ញុំមកហ្នឹងខាតនឹងការងារបច្ចុប្បន្នទៀត។

**លោកស្រី ម៉ុច សុវណ្ណារី៖**

ចាស សូមអរគុណលោកពូ។ ខ្ញុំអស់សំណួរសួរលោកពូ។ សូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ សូមពីខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គឺមិនមានសំណួរសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ឥឡូវនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវី -- សហព្រះរាជអាជ្ញាបាទ។

[១៤:២១:០២]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី សូមអរគុណដែលលោកត្រឡប់មកជាថ្មីម្តងទៀត ដើម្បីឆ្លើយសាជាថ្មីទៅនឹងសំណួររបស់យើងខ្ញុំ។ ខ្ញុំមានសំណួរមួយចំនួនតូចទេ។ ដូចលោកដឹងហើយថាបន្ទាប់ គឺថាបន្ទាប់ពីការផ្តល់សក្ខីកម្មរបស់លោក បុគ្គលិកក្រាំងតាចាន់មួយចំនួនបានមកផ្តល់សក្ខីកម្ម

ដែរក្នុងនោះរួមមាន ផាន់ ផេន, ស្រី ថន ហៅ ឌុច ឬ ឌុចតូច នៅសម័យ, វ៉ាន់ សឿន ឬ ស៊ាន់ ជានីរសារក្រាំងតាចាន់, ហើយកាលពីម្សិលមិញ និងថ្ងៃនេះ យើងបានស្តាប់ឮដើមបណ្តឹងរដ្ឋប្បវេណី ដែលមានឈ្មោះថា សូត្រ សាំង បានមកផ្តល់សក្ខីកម្ម។ ដូច្នេះ ជាដំបូង ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីបង្ហាញឯកសារមួយជូនទៅសាក្សី គឺឯកសារ D22/88a ដែលជាអត្តសញ្ញាណបណ្ណរបស់ សូត្រ សាំង។ យើងមិនបញ្ចាំងនឹងអេក្រង់កុំព្យូទ័រទេលោកប្រធាន ប៉ុន្តែសូមផ្តល់ជាឯកសារក្រដាក់ជូនទៅដើមបណ្តឹងរដ្ឋប្បវេណី។

[១៤:២២:១២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្សាងលៈ**

**ស៖** សូមលោកមើលរូបថត<ក្នុងអត្តសញ្ញាណបណ្ណ>ហ្នឹងទៅ តើអ្នកដែលនៅក្នុងរូបថតហ្នឹង គឺពិតជាអ្នកយាមនៅក្រាំងតាចាន់មែនទេ ដែលនៅពេលនោះៗគាត់ឈ្មោះថា សាំង នោះ? លោកមើលទៅមើល៍ រូបហ្នឹងមែនទេ?

**លោក សយ សែន៖**

**ឆ៖** បាទ ពិត សូត្រ សាំង។ សូត្រ សាំង ជាពិតប្រាកដ កង -- គាត់ជាកងទ័ព។

**ស៖** ខ្ញុំមានសំណួរជាច្រើនដែលត្រូវសួរលោក។ ជាដំបូង ខ្ញុំនឹងដកស្រង់នូវចម្លើយរបស់អ្នកយាម<មួយចំនួន ដូចជា> ឌុច <តូច>, សឿន ឬក៏ ស៊ាន់<ជានីរសារ>, សៀង, ស៊ីម ដែលត្រូវបានអ្នកស៊ើបអង្កេតស្តាប់ចម្លើយ។ ពួកគាត់ទាំងអស់នោះបានបញ្ជាក់ថា ក្រៅតែពីអ្នកនៅរស់រានមួយចំនួនតូចដូចជាលោក<ផ្ទាល់> ហើយនិងគ្រួសាររបស់ យាយញ៉ ហើយនិងលើកលែងតែមានអ្នកត្រូវបានបញ្ជូនចេញមួយចំនួននោះ គឺថាអ្នកទោសនៅក្រាំងតាចាន់ស្ទើរតែទាំងអស់ត្រូវបានសម្លាប់ចោល រួមទាំងបុរស ស្ត្រីនិងកុមារ។ ពួកគាត់ក៏បាននិយាយផងដែរថា អ្នកទោសមួយចំនួនត្រូវបានសួរចម្លើយ ឬធ្វើទារុណកម្មក្នុងអំឡុងពេលសួរចម្លើយ។ ឧទាហរណ៍ លោក វ៉ាន់ សឿន ដែលជានីរសារបានបញ្ជាក់នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ នៅចំពោះមុខអង្គជំនុំជម្រះ គឺឯកសារលេខ E1/271.1 ប្រហែលជានៅម៉ោង១០:៤៧នាទី ទៅដល់ម៉ោង១០:៤៩នាទី។ គាត់បញ្ជាក់អំពីចម្លើយទី២១ នៃកំណត់ហេតុរបស់គាត់ គឺឯកសារលេខ E319.1.33។

[១៤:២៤:១៥]

ក្នុងចម្លើយនោះគាត់បានបញ្ជាក់ថា "ជួនកាល <យើង>សម្លាប់ក្មេងៗ ហើយជួនកាលគេដោះលែងជាមួយនឹងម្តាយ"។ គាត់ទទួលស្គាល់ថា ចំនួនកុមារដែលត្រូវបានដោះលែងជាមួយនឹងម្តាយហ្នឹងគឺថា មានតិចជាង១០<នាក់>។ នៅពេលដែលប្រឈមមុខទៅនឹងចម្លើយរបស់ ស្រី ថន ហៅ ឌុចតូច ក៏បានឆ្លើយនៅម៉ោង ១០:៥០នាទី។ លោក វ៉ាន់ សឿន គាត់ថា គាត់យល់ស្របជាមួយនឹង ស្រី ថន ហៅ ឌុច ដែលថាអ្នកទោស៩៩ភាគរយនៅក្រាំងតាចាន់ ត្រូវបានកម្ទេចចោល។ ឧទាហរណ៍មួយទៀត លោក សូត្រ សាំង បាននិយាយកាលពីម្សិលមិញនៅម៉ោងប្រហែល ១៤:១៩នាទី។ ខ្ញុំសូមដកស្រង់៖ "ដូចដែលខ្ញុំបាននិយាយរួចមកហើយ នៅពេលដែលម្តាយ ឬឪពុកត្រូវបានសម្លាប់ចោលនោះ កូនៗក៏បាត់ខ្លួនដែរ។ ដូច្នេះ ខ្ញុំគិតថាកូនៗក៏ត្រូវគេសម្លាប់មកដែរ" សូមបញ្ចប់ការដកស្រង់។ អ្នកយាមទាំងបួនមាន ឌុចតូច, សឿន ឬក៏ ស៊ាន់, សាំង និង ស៊ីម បាននិយាយថា ការសួរចម្លើយនិងការសម្លាប់គឺធ្វើឡើងដោយសមាជិកមន្ទីរក្រាំងតាចាន់ ដែលជាសមាជិកគណៈដឹកនាំគុក ឬក៏បក្ខជន។ ឧទាហរណ៍ដូចជា តាអាន់, ពេញ, ចេង, មឿន, សៀង ឬ ឌុចធំ។ មុននឹងសួរសំណួរទៅកាន់លោក ខ្ញុំសូមអាននូវសម្រង់មួយចំនួននៃសក្ខីកម្មរបស់ពួកគាត់នៅចំពោះមុខអង្គជំនុំជម្រះនេះ។ ជាដំបូងខ្ញុំចាប់ផ្តើមពីចម្លើយរបស់ស្រី ថន ហៅ ឌុច។ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ គឺឯកសារ E1/267.1 នៅម៉ោង០៩:២៦នាទី គាត់បាន ឆ្លើយដូចតទៅ៖ "ក្រុមខ្ញុំមានប្រាំមួយនាក់ មិនមែនជាបុគ្គលិករបស់គុកទេ។ យើងយាមតែនៅខាងក្រៅតែប៉ុណ្ណោះ គឺបុគ្គលិកគុកមិនមែនពួកយើងទេ ដែលត្រូវបានគេបញ្ជាឲ្យនាំអ្នកទោសទៅរោងសួរចម្លើយ ហើយបន្ទាប់មកទៀត នាំមកកន្លែងឃុំឃាំងវិញ"។ សូមបញ្ចប់ការដកស្រង់។

[១៤:២៦:៥២]

វ៉ាន់ សឿន នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ប្រតិចារឹកលេខ E1/270.1 នៅម៉ោង១៥:២៣នាទី គាត់បានឆ្លើយដូចតទៅ៖ "សំណួរ៖ លោកបានលើកឡើងនូវឈ្មោះមនុស្សបីនាក់ អាន់, ចេង និងពេញ។ តើបក្ខជនផ្សេងទៀតមានតួនាទីអ្វីផងដែរទេ នៅក្នុងអំឡុងពេលសួរចម្លើយហ្នឹង ឬក៏មានតួនាទីអ្វីទេ? ចម្លើយ៖ តាមពិតទៅពួកគេឆ្លាស់គ្នាធ្វើការ។ សំណួរ៖ ដូច្នេះបក្ខជនទាំងប្រាំមួយនាក់ គឺឆ្លាស់វេនគ្នាដើម្បីសួរ<ចម្លើយ>អ្នកទោស តើពិតជាអ៊ីចឹងមែនទេ។ ចម្លើយ៖ បាទ ពិតជាអ៊ីចឹងមែន។ ហើយ វ៉ាន់ សឿន បានបន្តឆ្លើយទៅទៀត ដោយបដិសេធថាអ្នកយាមទាំងប្រាំមួយនាក់ហ្នឹង គឺយាមនៅកន្លែងសួរចម្លើយ ឬក៏នាំអ្នកទោសថាមិនបាននៅ -- បដិសេធថាខ្លួនមិនបានយាមនៅកន្លែងសួរចម្លើយ ឬក៏នាំអ្នក

ទោសទៅសួរចម្លើយទេ”។

<សម្រង់ពីរចុងក្រោយមានដូចតទៅ៖> វ៉ាន់ សឿន នៅថ្ងៃទី<០៤> ខែមីនា ឆ្នាំ២០១៥ នៅ<ឯកសារ E1/271.1 នៅ>ម៉ោង១១:០៧នាទី វ៉ាន់ សឿន គាត់បានឆ្លើយថា៖ “ចំពោះយើង យើងយាមតែខាងក្រៅប៉ុណ្ណោះ នេះជាភារកិច្ចរបស់យើង។ <>អ្នកធ្វើការនៅខាងក្នុង ជាអ្នកសម្លាប់អ្នកទោស។ នេះគឺជាភារកិច្ចរបស់ពួកគេ។ នៅម៉ោង១១:០៨នាទី គេសួរគាត់ថា ក្នុងពេលសម្លាប់ តើលោកដឹងថា អ្នកណាជាអ្នកទទួលបន្ទុកសម្លាប់ ឬក៏អ្នកណាជាឃាតករទេ? គាត់ឆ្លើយនៅពេលនោះថា គឺបក្ខជនទាំងប្រាំមួយនាក់”។ សូមបញ្ចប់ការដកស្រង់។ ខ្ញុំសូមបន្តទៅទៀត ប្រសិនបើមិនមានការជំទាស់ទេ។

[១៤:២៨:៥៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក រ៉ិចទ័រ កូប៉េ!

**លោក រ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនប្រាកដថាតើព្រះរាជអាជ្ញាកំពុងតែធ្វើអ្វីនោះទេ ដែលគាត់ផ្តល់នូវព័ត៌មានអំពីសក្ខីកម្មកន្លងមករបស់សាក្សីនេះ។ ខ្ញុំប្រាកដថា ខ្ញុំ<មិន>អាចតាមទាន់អ្វីដែលគាត់និយាយនៅផ្នែកដំបូង។<>ខ្ញុំមិនមានបញ្ហាអ្វីប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី<រូបនេះ>ត្រូវបានគេលើកយកនូវសក្ខីកម្មរបស់អ្នកដទៃ<មកតទល់សួរគាត់ ក៏>ប៉ុន្តែការដែលផ្តល់នូវសក្ខីកម្មអស់រយៈពេលប្រហែលជា១៥នាទី គ្រាន់តែអានឲ្យគាត់ស្តាប់នេះគឺជា<រឿងចម្លែកសម្រាប់រូបខ្ញុំ>។ ខ្ញុំគិតថាហាក់ដូចជាគេកំពុងតែធ្វើ<សេចក្តី>សន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលដូច្នេះដែរ។ <ចំពោះខ្ញុំ ខ្ញុំទំនងមានការចងចាំខុសពីហេតុការណ៍ដែលក្រុមអ្នកយាមបាន>ឃើញអ្វីផ្ទាល់ភ្នែក<>។ ខ្ញុំអាចបន្តស្តាប់អ្វីដែល<លោកព្រះរាជអាជ្ញា>អានបន្តទៅមុខទៀតបាន ប៉ុន្តែខ្ញុំគិតថាដូចជាគ្មានគោលដៅ ដូចជាមិនដឹងថាមានប្រយោជន៍អ្វីនោះទេ។ ដូច្នេះហើយទើបខ្ញុំជំទាស់ទៅលើការសួរបែបនេះ។

[១៤:៣០:០៧]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតប។ ខ្ញុំជិតចប់ទៅហើយចំពោះការអាននេះ។ ខ្ញុំអាននេះ ដើម្បីទទួលបាន<ប្រតិកម្ម>ឆ្លើយតបពីដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ពីព្រោះថាអ្នកទាំងអស់នេះ គឺបានប្រឈម

ជាមួយនឹងមេធាវីការពារក្ដី<រួចទៅហើយ តទល់គ្នានឹងចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ហើយសួរទៅវិញទៅមក> ខាងមេធាវីការពារក្ដីហ្នឹង គាត់ថាដើមបណ្ដឹងរដ្ឋប្បវេណីកុហក<ទៅវិញ។>អ៊ីចឹងហើយបានជាខ្ញុំរំឭកឡើងវិញថា តើសាក្សីមុនៗនោះគាត់បាននិយាយអ្វីខ្លះ ដើម្បីខ្ញុំសួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមលោកប្រធានមេត្តាអនុញ្ញាតឲ្យខ្ញុំសួរបន្ត។

[១៤:៣០:៤៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣២:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រី ក្លូឌា ហ្វេនស៍ ដើម្បីសម្រេចលើសេចក្ដីជំទាស់នេះ និងរបៀបសួរ តាំងសំណួររបស់សហព្រះរាជអាជ្ញារងអន្តរជាតិអម្បាញ់មិញនេះ។

សូមអញ្ជើញលោកស្រីចៅក្រម ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំគិតថានេះមិន<មែន>ជាបញ្ហាអង្គច្បាប់ទេ <ប៉ុន្តែ វាជា>បញ្ហា<វិធីសាស្ត្រក្នុងតាំងសំណួរទៅវិញទេ>។<ពិតណាស់> និយាយតាមពិតទៅ ខ្ញុំមិនអាចតាមទាន់អ្វីដែលខាងព្រះរាជអាជ្ញាដកស្រង់យ៉ាងវែង<អន្លាយ>នោះឡើយ។ ដូច្នេះ ខ្ញុំ<ឆ្ងល់ថា តើព្រះរាជអាជ្ញា>សួរ<សំណួរបែបណាទៅ ដើម្បីសរុបសម្រង់>ទាំងអស់នេះ។ ដូច្នេះខ្ញុំស្នើយោបល់ថា លោកគួរតែដកស្រង់ត្រឹមតែពីរបីចំណុច បន្ទាប់មកសួរទៅ <ហើយស្វែងរកប្រតិកម្មឆ្លើយតបវិញប្រសើរជាង>។ <ខ្ញុំគិតថា> អ្វីដែលលោកកំពុងតែធ្វើ គឺគ្រាន់តែចង់ឲ្យមានការដកស្រង់បញ្ចូលទៅក្នុងកំណត់ត្រាប្រតិចារឹកប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំចង់ឲ្យលោកជ្រើសរើសការដកស្រង់ណាដែលសំខាន់ ដែលចាំបាច់ ដែលលោកចង់ដោះស្រាយយកមកសួរតែប៉ុណ្ណោះ <ដោយសារពេលវេលាមានកំណត់>។ <>

[១៤:៣៣:៥៤]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** ឥឡូវ ខ្ញុំចូលទៅសំណួរតែម្ដងលោកដើមបណ្ដឹងរដ្ឋប្បវេណី។ តើលោកយល់ស្របជាមួយ

នឹងអ្នកយាមទាំងអស់ហ្នឹងទេ គឺ <សាំង>, ស៊ីម, ឌុចតូច, វ៉ាន់ សឿន ដែលគាត់និយាយថាគាត់មិនមានតួនាទីអ្វីទេក្នុងពេលសួរចម្លើយ ក្នុងពេលសម្លាប់មនុស្សនោះ ពីព្រោះថាពួកគាត់ទាំងអស់នុ៎ង គឺយាមតែនៅខាងក្រៅ<ប៉ុណ្ណោះ>។ តើលោកមានចម្លើយតបយ៉ាងណាទៅនឹងចម្លើយរបស់ពួកគាត់នេះ?

**លោក សយ សែន៖**

**ឆ៖** បាទមាន។ ចម្លើយនេះគឺមិនពិតប្រាកដទេ ពួកគាត់និយាយ។ គឺគាត់ហ្នឹងហើយជាអ្នកចាប់អ្នកចង អ្នកសម្លាប់។ វៀសវាង វ៉ាន់ សឿន មួយខ្ញុំអត់ស្គាល់ទេ មិនដឹងឈ្មោះអី ខ្ញុំអត់ស្គាល់ ពីមុនខ្ញុំអត់ដែលមានឈ្មោះ វ៉ាន់ សឿន ទេ នៅកន្លែងនោះអត់មានទេ។

[១៤:៣៥:០៨]

**ស៖** គឺប៉ុន្តែខ្ញុំនិយាយហ្នឹង គឺនិយាយសំដៅទៅដល់អ្នកយាមទាំងអស់ គឺ <សូត្រ> សាំង, ស៊ីម, ឌុចតូច និង វ៉ាន់ សឿន។ ពួកគាត់ទាំងអស់នុ៎ង គឺនៅក្នុងក្រុមអ្នកយាមតែមួយក្រុមទេ នៅក្រាំងតាចាន់នោះ។ <>

**ឆ៖** បាទ គាត់ ចម្លើយគឺគាត់ គឺខ្ញុំមិនឯកភាពជាមួយ។ គាត់ជាអ្នកដែរដល់ គាត់ជាអ្នកចាប់អ្នកចង អ្នកបញ្ជូននៅលើ ខុសត្រូវនៅលើគាត់ និងបទបញ្ជា ប្រធានបញ្ជាគាត់មក គាត់ធ្វើបានទាំងអស់។ គាត់នៅក្នុងហ្នឹងទាំងអស់ អត់មាននៅក្រៅ អត់មានទេបាទ។ ហើយវ៉ាន់ -- បាទ វ៉ាន់ សឿន មួយ ខ្ញុំអត់បានស្គាល់ទេ មិនដឹងគាត់មួយណា វ៉ាន់ សឿន ទេខ្ញុំអត់ដែលមានឈ្មោះ វ៉ាន់ សឿន ផងក្នុងហ្នឹង។

**ស៖** <ក្នុងគោលបំណងបញ្ជាក់ឲ្យច្បាស់> វ៉ាន់ សឿន នេះ ហៅ ស៊ាន់ ។ គាត់ជានីរសារនៅក្រាំងតាចាន់។ លោកច្បាស់ទេឥឡូវ នៅពេលដែលខ្ញុំប្រាប់គាត់ថា ប្រាប់លោកថា វ៉ាន់ សឿន ហ្នឹងហៅ ស៊ាន់ ។ លោកស្គាល់ទេ?

[១៤:៣៦:៣៣]

**ឆ៖** បាទ ស៊ាន់ ស្គាល់។ បើថា វ៉ាន់ សឿន អត់ដែលមានឈ្មោះផង អត់ដែលឮសួរឈ្មោះស្គាល់តែ ស៊ាន់ ទេ។

**ស៖** លោកអាចជម្រាបបានទេ ក្នុងចំណោមបុគ្គលិកក្រាំងតាចាន់ តើមានអ្នកណាខ្លះជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** បាទ១ បានខ្ញុំដឹង តែ តាចេង ហើយ បងមឿន ហើយតែប៉ុណ្ណឹងបាទ។ នៅខាងលើៗ សុទ្ធតែមេគេធំៗ ហ្នឹង ឌុចៗ – ឌុចធំ ហ្នឹងគេអនុប្រធានហើយ។ ប៉ុន្តែបើនិយាយពីបក្ខជន ដឹងតែ តាចេង

ហើយ បងមឿន តែពីរនាក់ហ្នឹងទេ បាទ ហើយ សៀង បីនាក់។

**ស៖** ចុះ តាអាន់, តាពេញ គាត់ជាបក្ខជនទេ?

**ឆ៖** អាហ្នឹង តាអាន់ ប្រធាន។ តាពេញ គាត់អនុប្រធាន -- អ៎! តាពេញ សមាជិក, អនុប្រធាន ឌុច ធំ បាទ។

**ស៖** បើតាមការសង្កេតរបស់លោកនោះ តើអ្នកយាមដូចជា ស្វុត្រ សាំង, ស៊ាន់, ឌុចតូច, ស៊ីម , ទូច, អ៊្លក តើអ្នកទាំងអស់ហ្នឹង ត្រូវតែគោរពតាមបញ្ជានិងការបង្គាប់របស់ តាអាន់ ឬក៏ថ្នាក់ដឹកនាំគុក ណាមួយផ្សេងទៀត? តើមានអ៊ីចឹងទេ?

[១៤:៣៨:៣០]

**ឆ៖** បាទ បើតាមខ្ញុំមើលទៅ វាជួនកាល គាត់បញ្ជាចេញពី តាឆេន មក។ អត់ពីតាឆេនមក តាអាន់។ អត់ពីតាអាន់ តាពេញអ៊ីចឹងទៅ បាទបន្តៗគ្នារហូត។ គាត់ស្ដាប់មេទាំងពីរ ទាំងបីហ្នឹង គាត់ស្ដាប់គ្នាគាត់ទាំងអស់ បាទ។

**ស៖** វ៉ាន់ សឿន បានបញ្ជាក់អំពីការស្ដាប់បង្គាប់នេះ គឺនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ គឺឯកសារប្រតិចារឹកលេខ E1/270.1 នៅម៉ោង១៥:១៣នាទី ដល់ម៉ោង១៥:១៥នាទី គាត់ថា៖ "ក្នុងនាមជាៗថ្នាក់ក្រោម <>យើងត្រូវតែគោរពតាមបញ្ជារបស់ថ្នាក់លើ។ ប្រសិនបើយើងមិនស្ដាប់បញ្ជាទេ គេនឹងចាប់យើងដាក់គុក"។ សូមបញ្ចប់ការដកស្រង់។ ចុះលោកខ្លួនឯងផ្ទាល់នោះ លោកមានបានពិនិត្យមើ<ល>ឃើញទេថា នៅពេលដែលអ្នកយាមណាម្នាក់ដែលមិនគោរពបញ្ជារបស់ តាអាន់ ឬ តាពេញ ឬ តាចេង នោះ តើមានអ៊ីចឹងទេ?

**ឆ៖** បាទ អត់ដែលឃើញផងកន្លែងហ្នឹង ដែលឃើញតែគាត់គោរពនឹងការងាររបស់គាត់នៅកន្លែងហ្នឹង បទបញ្ជាគាត់។ អ្វីៗមួយ គាត់មិនដែលឲ្យអ្នកទោសបានឃើញគ្រប់កន្លែងទាំងអស់ទេ បាទ។

[១៤:៤០:១៣]

**ស៖** ខ្ញុំចង់សួរលោកថាតើលោកមានបានសង្កេតឃើញអំពីតួនាទីរបស់អ្នកយាម ដូចជា ស្វុត្រ សាំង, ឌុចតូច, ស៊ីម និង សឿន ឬក៏ស៊ាន់ ដែលជានីរសារ។ តើបើតាមបញ្ជារបស់ តាអាន់ នោះ ឬក៏មេគុកនោះ គឺថាត្រូវពួកគាត់ហ្នឹង ត្រូវនាំអ្នកទោសថ្មីដែលមកដល់គុកហ្នឹង គឺថានាំពីរបងខាងក្រៅនាំចូលទៅរហូតដល់អគារឃុំឃាំងទេ?

**ឆ៖** បាទ ដែលឃើញតើ! គាត់នាំទទួលពីឈ្លបយកមកដល់របងក្រៅ គាត់យកមកដាក់គុក។

កាលហ្នឹងគាត់នាំពីខាងរបងខាងក្រៅយកមកដាក់គុកខាងក្នុងបាទ ឈ្លបនាំមកពីខាងក្រៅមកដល់នឹងរបងក្រៅហ្នឹងឯងឈ្លប។

**ស៖** តើលោកឃើញអ្នកយាមទាំងអស់នេះយាមអ្នកទោសដែលធ្វើការនៅពេលថ្ងៃទេ?

**ឆ៖** បាទឃើញ អាហ្នឹងគាត់លែងខ្ញុំចេញធ្វើការ គាត់ចេញមកយាមខ្ញុំពីរៗនាក់អ៊ីចឹងទៅ គឺថាលែងពួកអ្នកទោសប្រមាណប្រាំមួយនាក់អ៊ីចឹង ត្រូវកាលណាដកស្ទូងអ៊ីចឹង គាត់មកចាំ មកយាមនៅលើភ្លឺហ្នឹងពីរនាក់អ៊ីចឹង ឬបីនាក់អ៊ីចឹងទៅបាទ។ គាត់អ្នកយាមតើ។

**ស៖** តើអ្នកយាមដូចជា សាំង, ស៊ុម, ឌុចតូច, ឬសឿន ឬក៏ ស៊ាន់ ធ្លាប់យាមអ្នកទោសទេ ឬក៏មានតែលោកទេដែលយាមអ្នកទោសនោះ?

**ឆ៖** បាទ គាត់ ពួកគាត់ហ្នឹងគ្រាន់តែដូរវេនគ្នាយាម ពួកគាត់ហ្នឹង។

**ស៖** តើអ្នកយាមទាំងអស់ហ្នឹងធ្លាប់នាំអ្នកទោស<>ពីកន្លែងឃុំខ្លួនទៅកន្លែងសួរចម្លើយដើម្បីយកទៅសួរចម្លើយទេ លោកធ្លាប់ឃើញទេ?

[១៤:៤២:៥៤]

**ឆ៖** បាទ ឃើញ។ គាត់ដូរវេនគ្នា ថ្ងៃណា ស្អែកឡើងត្រូវវេន -- ឧទាហរណ៍ថាត្រូវវេននរណាត្រូវវេន ស៊ុម ឬឌុចតូច អ្នកនាំខ្លួនទៅកន្លែងសួរចម្លើយ។ អាហ្នឹងហៅកងទ័ព អ្នកហៅនាំខ្លួនទៅសួរចម្លើយ មេធំៗគេនៅចាំកន្លែងគេ ហើយពីរនាក់អ្នកនាំទៅសួរចម្លើយបាទ។

**ស៖** នៅពេលទៅដល់កន្លែងសួរចម្លើយ តើពួកអ្នកយាមទាំងអស់ហ្នឹង<>ចេញពីហ្នឹងទៅធ្វើការផ្សេង ឬក៏អ្នកយាមហ្នឹងនៅកន្លែងហ្នឹង នៅឈរមើលគេសួរចម្លើយអ្នកទោស?

**ឆ៖** បាទ បានខ្ញុំទៅនៅជិតហ្នឹង ខ្ញុំបោសសំរាមនៅជិតហ្នឹង គាត់នៅៗអង្គុយកៅអី នៅអង្គុយខាងក្រៅ ប៉ុន្តែអត់មានកៅអីទេ មានតែឈើដុំកាត់ជាកង់ៗ គ្រាន់តែទ្រាប់អង្គុយនៅហ្នឹង គ្រាន់តែចាំព្រោះគាត់អ្នកអង្គុយចាំអ្នកទោសហ្នឹង ព្រោះគាត់កាន់កាំភ្លើងគ្រប់ដៃ។ ពីរនាក់ហ្នឹង កាំភ្លើងពីរដើមដែរ។ ហើយតាចេង ហើយនិង តាអាន់ ហើយតាពេញ គាត់នៅអង្គុយសួរចម្លើយ ហើយដល់ពេលធ្វើទារុណ-កម្ម កងទ័ពហ្នឹងអ្នកធ្វើទារុណកម្មបាទ យកអាច្នោងឫស្សី ច្នោងប្រវែងៗដល់វៃសួរចម្លើយ ហើយកងទ័ពអ្នកយកកៅស៊ូ កន្សែងកៅស៊ូហៅក្រណាត់ភ្លៀង យកមកចងមុខ ហើយដាក់ដៃទៅក្រោយ ហើយវៃសួរចម្លើយបាទ។

[១៤:៤៤:៣៤]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** នៅពេលដែលលោកនិយាយថា "កងទ័ព" លោកសំដៅទៅដល់អ្នកយាមទាំងអស់ហ្នឹង មែនទេ ដូចជា ឌុចតូច, ស៊ឹម, សាំ<ង>, និង ស៊ាន់ នោះ លោកសំដៅទៅដល់ពួកគាត់ហ្នឹងទេ នៅពេលដែលលោកនិយាយថាកងទ័ពនោះ?

**ឆ៖** បាទ កងទ័ពពួកគាត់ហ្នឹង មានពីណាទៀត មានតែគាត់ហ្នឹងអ្នកនៅកន្លែងហ្នឹង តែក្រុមគ្នាគាត់ហ្នឹង មានអ្នកដទៃឯណាទៅជំនួសអត់ទេ តែពួកគាត់ហ្នឹងតើអ្នកនៅកន្លែងហ្នឹង។ បើនិយាយឲ្យខ្លីមក និយាយឲ្យឆាប់ចប់គឺអ្នកនៅគុកក្រាំងតាចាន់ គឺអ្នកឃាតករ អ្នកដៃដល់ទាំងអស់ អត់មានអ្នកណាមួយនៅក្រៅ អត់មានបាទ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់ដើមបណ្ដឹងរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៥ នាទី ដល់ម៉ោង ១៥:០៥ នាទី)*

[១៥:០៥:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សូមអញ្ជើញលោកស្រីមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកប្រធាន។ យើង<សម្គាល់ឃើញថា យើងដូចជាដើរ>យឺតបន្តិចហើយ ខ្ញុំសូមជម្រាបជូនតុលាការថាគាត់ លោក សយ សែន គាត់ត្រូវទៅត្រឡប់ទៅផ្ទះគាត់វិញនៅថ្ងៃនេះជាចាំ

បាច់។ អ៊ីចឹងខ្ញុំសូមសួរថាតើត្រូវពន្យារពេលធ្វើយ៉ាងម៉េចឲ្យបញ្ចប់សវនាការលើសួរចម្លើយគាត់នៅថ្ងៃនេះ ធ្វើយ៉ាងណាឲ្យល្ងាចនេះហ្នឹងគាត់អាចត្រឡប់ទៅលំនៅដ្ឋានគាត់វិញបានលោកប្រធាន។ សូមជួយពិចារណាត្រង់ចំណុចនេះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញកាត់បន្ថយពេលវេលាទៅ ពីសហព្រះរាជអាជ្ញាមុនទៅ។

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលៈ**

**ស៖** ឥឡូវខ្ញុំនឹងសូមសួរឲ្យបានខ្លីៗឆាប់ចប់។ លោក សយ សែន តើអ្នកយាមនោះ មានតួនាទីដូចជា <ស្ងួត្រ សាំង,> ឌុចតូច <និងអ្នកផ្សេងទៀត មានភារកិច្ច>នាំអ្នកទោសយកទៅសម្លាប់នោះ? <>

**លោក សយ សែន៖**

**ឆ៖** បាទ គាត់ហ្នឹងហើយជាអ្នកនាំអ្នកទោសចេញពីក្នុងគុកយកទៅសម្លាប់បាទ។

**ស៖** តើអ្នកយាម ឬក្រុមអ្នកយាមហ្នឹងជាកូនចៅហ្នឹង<>មានតួនាទីក្នុងការសម្លាប់អ្នកទោសនៅមន្ទីរក្រាំងតាចាន់ ទោះជា<>កុមារក្ដី មនុស្សចាស់ក្ដី ស្ត្រីក្ដី បុរសក្ដីបាទ?

**ឆ៖** បាទ ទូទៅ វាកងទ័ពហ្នឹងជាអ្នកដែលដល់បាទ។

**ស៖** បើសិនជាយោធាជាអ្នកធ្វើការងារទាំងអស់ហ្នឹង តើអ្នកយាម ហើយនិងយោធាដែលជាកូនចៅ<នៅក្រាំងតាចាន់>នោះ គឺទទួលបន្ទុក<>កិច្ចការអាក្រក់ទាំងអស់នៅមន្ទីរក្រាំងតាចាន់ហ្នឹង។ ឧទាហរណ៍ ដូចជាវាយដំអ្នកទោសនៅពេលសួរចម្លើយ ឬក៏យកពួកគេទៅសម្លាប់ជាដើមនេះ។ អ៊ីចឹងឬក៏យ៉ាងណា?

**ឆ៖** បាទ ដូចគ្នា។

[១៥:០៨:៥៤]

**ស៖** បាទ ឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីអ្វីដែល ស្ងួត្រ សាំង បាននិយាយកាលពីម្សិលមិញនៅក្នុងសវនាការម្សិលមិញហ្នឹងនៅក្នុងម៉ោង ១៤:១៨នាទី គាត់និយាយថា៖ “ទាក់ទងនឹងការសម្លាប់កុមារ នៅមន្ទីរក្រាំងតាចាន់ ខ្ញុំសូមបញ្ជាក់ដូចតទៅនេះ នៅក្នុងមន្ទីរក្រាំងតាចាន់មិនមានដើមត្នោតនោះទេ គឺមិនមានដើមត្នោតមួយដើមសោះ។ មិនមានដើមត្នោតទេ<>ប៉ុន្តែឆ្ងាយពីបរិវេណហ្នឹងមានដើមត្នោតគេធ្វើទឹកត្នោតនៅខាងត្បូង និងខាងជើងនៃមន្ទីរក្រាំងតាចាន់នោះ”។<បញ្ចប់ការដកស្រង់។>

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស្ងួត្រ សាំង ហ្នឹង<ទំនង>គាត់មិនបានឆ្លើយច្បាស់ទេថាលោកជាអ្នកទទួលបន្ទុកក្នុងការប្រមូលទឹកត្នោតនោះ ដើម្បីយកមកធ្វើទឹកត្នោតជូរនោះទេ។ ក៏ប៉ុន្តែឈ្មោះ ស៊ាន់ នោះជា<នីរសារ ហើយជា>បងប្អូនជីដូនមួយរបស់គាត់នោះ ឆ្លើយថាគឺលោកហ្នឹងហើយជាអ្នកដែលយកទឹកត្នោតហ្នឹង។ តើលោកជាអ្នកទៅយកទឹកត្នោត ឡើងត្នោតនោះ តើលោកមានធ្លាប់ឃើញដើមត្នោតនៅក្នុងបរិវេណក្រាំងតាចាន់ទេនៅជិតអគារអីជាដើមហ្នឹង? ហើយបើសិនជាមានមែន តើមាននៅកន្លែងណាដែរ?

[១៥:១០:២៥]

**ឆ៖** បាទ មាន។ ពីមុនក្នុងគុកក្រាំងតាចាន់ អាកន្លែងសម្លាប់ពីខាងត្បូងគុកហ្នឹង គឺអត់មានដើមត្នោតទេ ប៉ុន្តែដល់អាហ្នឹងពេញទៅយកមកសម្លាប់នៅភូមិខាងលិចក្នុងគុកដូចគ្នា ប៉ុន្តែពីខាងលិចមាត់ត្រពាំង។ ខ្ញុំធ្វើត្នោតនៅខាងលិចមាត់ត្រពាំង។ ហើយគេយកទៅសម្លាប់នៅគល់ត្នោតហ្នឹង គល់ត្នោតខ្ញុំធ្វើហ្នឹង។ ខ្ញុំនៅពីលើចុងត្នោត គាត់នៅពីក្រោមសម្លាប់ក្មេង។ បាទ មានពិតប្រាកដ ដើមត្នោតរស់នៅសព្វថ្ងៃគេកាប់អស់ពីរដើមនៅតែមួយដើមទេ នៅមួយដើមជាសាក្សីសព្វថ្ងៃហ្នឹងបាទ។

**ស៖** តើមានដើមត្នោតនៅក្រៅរបងទី១ដែរឬទេ?

**ឆ៖** បាទ មានៗច្រើនណាស់។ ដើមត្នោតមិនអាចរាប់អស់ទេ មានច្រើននៅខាងរបងទី១ខាងក្រៅខាងលិចមាត់ត្រពាំង ដើមត្នោតឲ្យខ្ញុំធ្វើត្នោតទឹកត្នោតជូរឲ្យប្រធានហ្នឹង ហើយនិងពួកគាត់ហ្នឹង គឺដើមត្នោតខ្ញុំធ្វើហ្នឹង ជាង១០ដើមនៅម៉ុំហ្នឹង បាទ។

**ស៖** តើបុគ្គលិកនៅក្រាំងតាចាន់ទាំងអស់នោះ រួមទាំងអ្នកយាមផងដែរនោះ សុទ្ធតែដឹងថាការងារមួយដែល តាអាន់ ដាក់ឲ្យលោកធ្វើនោះ គឺត្រូវឡើងត្នោតដើម្បីយកទឹកត្នោតមកធ្វើទឹកត្នោតជូរ។ តើគេដឹងទាំងអស់គ្នាទេនៅក្នុងមន្ទីរក្រាំងតាចាន់ហ្នឹង?

**ឆ៖** បាទ ដឹងទាំងអស់។ ពួកគាត់ដឹងខ្ញុំទាំងអស់។

**ស៖** លោកបាននិយាយជាច្រើនអំពីការសម្លាប់កុមារីទាំងពីរនាក់នោះនៅពេលដែលលោកឡើងត្នោត ហើយលោកបានសង្កេតឃើញសកម្មភាពគេសម្លាប់ក្មេងស្រីទាំងពីរនាក់នោះ។ ឥឡូវនេះ ខ្ញុំសូមបង្ហាញរូបថតពីរ<សន្លឹក> ហើយនិងផែនទី ឬក៏ប្លង់មួយជូនលោកមើល។

**លោក វ៉ាំងសង់ វ៉ាយជ៍ ដេស្សាងឈលះ**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបញ្ចាំងរូបថត គឺឯកសារ D125/220.30 ហើយនិង .31 ហើយនិងប្លង់មួយទៀតដែលមានលេខ D125/220.35។ លោកប្រធាន ខ្ញុំសូមប្រគល់ឯកសារនេះ ជូនទៅ

សាក្សី ហើយសូមបញ្ជាក់ផងដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១៥:១៣:៣៣]

**សួរដោយលោក វ៉ាងសង់ វ៉ាយដ៍ ដេស្មាឯល៖**

**ស៖** បើតាមចំណងជើងរូបថតទាំងអស់នេះ<>លោកជាអ្នកបង្ហាញទៅ<>អ្នកស៊ើបអង្កេតដើមត្នោតដែល<នៅសល់ ជាកន្លែងដែលលោកឃើញ>គេសម្លាប់កុមារីទាំងពីរនាក់ហ្នឹង។ កន្លែងដើមត្នោតដូចរូបថតដែលលោកឃើញនេះ ហើយនិងអ្នកយាមដែលគាត់បានសម្លាប់កុមារីទាំងពីរនាក់នោះនៅចំពោះមុខលោក។ <តើត្រឹមត្រូវទេ?> អ៊ីចឹងខ្ញុំសួរលោកថា តើកន្លែងហ្នឹងហើយដែលថាកន្លែងដែលក្មេងស្រីទាំងពីរនាក់ត្រូវបានគេសម្លាប់ ហើយក៏វាជាដើមត្នោតដែលលោកបានឡើង ឬក៏ជាដើមត្នោតដែលពីចុងត្នោតនោះ លោកបានសង្កេតឃើញសកម្មភាពសម្លាប់ហ្នឹងបាទ?

**ឆ៖** បាទ ដើមត្នោតហ្នឹងហើយ ដើមត្នោតជំរំបីដើម កន្លែងខ្ញុំចង្អុលហ្នឹង ដើមត្នោតហ្នឹង។

**ស៖** បាទ នៅលើប្លង់ D125/220.35 ខ្ញុំគិតថាលោកពិបាកអាន ប៉ុន្តែ<ខ្ញុំបាន*ហាយឡាយ*ប្លង់ពីរ>កន្លែងដែលគេថតរូបថតហ្នឹងឯង។ ហើយយើងឃើញថា នៅក្នុងប្លង់នេះ -- គឺនៅកន្លែងដែលគេសម្លាប់កុមារី<ពីរនាក់>ហ្នឹង ស្ថិតនៅក្រៅរបងទី១ ហើយនិងនៅចន្លោះរបងទី១ និងរបងទី២ ហើយស្ថិតនៅផ្នែកខាងលិចនៃមន្ទីរសន្តិសុខហ្នឹង ប្រហែលជា១០០ម៉ែត្រពី <បើយោងតាមទំហំផែនទីនេះ> -- ទៅ -- ប្រហែលជា១០០ម៉ែត្រពីរបងទី១។ អ៊ីចឹងខ្ញុំសួរលោកថា តើកន្លែងហ្នឹងហើយអីដែលលោកបង្ហាញទៅអ្នកស៊ើបអង្កេតហ្នឹង ត្រឹមត្រូវដែរឬទេ? <តើ>លោក<ចាំបានទេ>?

[១៥:១៥:៣៦]

**ប្រធានអង្គជំនុំ៖**

កុំអាលឆ្លើយដើមបណ្តឹងរដ្ឋប្បវេណី។ សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅលើសំណួរនេះ<។ យើងសូម>ឱ្យព្រះរាជអាជ្ញាអង្គុយ<មួយកន្លែងសិន> ហើយសួរខ្លួនឯង<សាកមើល៍។> គាត់កំពុងតែនាំមុខដើមបណ្តឹងរដ្ឋប្បវេណី<ឱ្យឆ្លើយនឹងសំណួរដែលគាត់ចង់បានចម្លើយហើយ។ នេះមិនមែនជាការតាំងសំណួរត្រឹមត្រូវទេ។> ដំបូងគាត់

បង្ហាញដើមឈើ អាចដើមឈើស្អីក៏បានដែរ បន្ទាប់មកទៀតគាត់ប្រាប់អំពីទិសដៅ ឬក៏គោលដៅនៅក្នុងផែនទី ហើយក៏សង្ឃឹមថាដើមបណ្ដឹងរដ្ឋប្បវេណីអាចនិយាយតាមគាត់។ តើវា<ជាការតាំងសំណួរយ៉ាងណាទៅ>?

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន ខ្ញុំត្រូវឆ្លើយតប។ បាទ ជាដំបូងគឺថាជារូបថតដែលដើមបណ្ដឹងរដ្ឋប្បវេណីបង្ហាញ <និងបញ្ជាក់>កន្លែងនេះទៅ<កាន់ភាគី ជាកន្លែងដែលគេយកកុមារីទាំងពីរនាក់នោះទៅសម្លាប់មែន> ហើយប្លង់ៗទាំងអស់ហ្នឹងបានធ្វើឡើងទៅមូលដ្ឋានលើរូបថត ហ្សេ.ប៉េ.អេស អ៊ីចឹងគឺប្លង់មួយដែលមានសត្យានុម័ត។ អ៊ីចឹងបង្ហាញប្លង់ហ្នឹង ដែលគាត់ខ្លួនឯង ដើមបណ្ដឹងរដ្ឋប្បវេណីខ្លួនឯងបានបង្ហាញទៅចៅក្រមស៊ើបអង្កេត <ដែលលោកដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញបរិវេណក្រាំងតាចាន់>។ <ដូច្នេះខ្ញុំមិនបាននាំមុខដើមបណ្ដឹងរដ្ឋប្បវេណីអីនោះទេ។> អ៊ីចឹងខ្ញុំមិនយល់<សោះ>ដែ<ល>ថា ហេតុអ្វីបានជា<លោកមេធាវីមក>ជំទាស់ ពីព្រោះនេះជាអ្វីដែលលោកដើមបណ្ដឹងរដ្ឋប្បវេណីខ្លួនឯងហ្នឹងហើយដែលគាត់បានចង្អុលបង្ហាញទៅអ្នកស៊ើបអង្កេតបាទ។

[១៥:១៧:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា គឺលោក វ៉ិចទ័រ កូប៉េ ដោយសារសំណួរនេះ គឺជាសំណួរសមស្របដែលផ្អែកលើមូលដ្ឋាននៃកំណត់ហេតុនិងឯកសារដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតជាមូលដ្ឋាន។

សាក្សីឆ្លើយតបនឹងសំណួរដែលសួរឡើងដោយសហព្រះរាជអាជ្ញារងអន្តរជាតិអម្បាញ់មិញនេះ!

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

**ស៖** បាទ ឥឡូវខ្ញុំសូមចោទសំណួរហ្នឹងឡើងវិញម្ដងទៀត។ លោកដើមបណ្ដឹងរដ្ឋប្បវេណីនៅកន្លែងដែលលោកបង្ហាញថា ក្មេងស្រីទាំងពីរនាក់ហ្នឹងត្រូវបានសម្លាប់ គឺថានៅខាងលិចនៃរង្វង់ទី១ ប្រហែលជា១០០ម៉ែត្រពីរបងទី១ គឺថារបងក្នុងបរិវេណក្នុងហ្នឹង។ នៅលើអេក្រង់នេះ យើងមើលទៅមិនឃើញមានលេខ២៩ និង៣០ ដែលជាលេខចង្អុលបង្ហាញកន្លែងដែលគេបានថតរូបថតនេះទេ?

**លោក សយ សែន៖**

**ឆ៖** បាទ នៅក្រៅរបងទី១ ប៉ុន្តែក្នុងរបងទី២ ពីខាងក្រៅបាទ។ នៅខាងលិចហ្នឹង មិនដល់១០០

ម៉ែត្រទេ បាទ រយៈដីប្រហែលជា ថាវ៉ៃឲ្យឆ្ងាយចុះ វា៦០, ៥០ម៉ែត្រជាងពីរបងទី១ ពីក្នុងទៅបាទ។

[១៥:១៩:១០]

**ស៖** បាទ ខ្ញុំមិនមានសំណួរច្រើនទៀតទេ លោកដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវខ្ញុំ សូមត្រឡប់មកនិយាយអំពីចំនួនរណ្តៅ ហើយនិងចំនួនសាកសពនៅមន្ទីរក្រាំងតាចាន់។ លោកបានលើកឡើងថា កាលនៅសវនាការថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥ នេះលោកបាននិយាយនៅក្នុងឯកសារ E1/251.1 នៅម៉ោង១៥:១៦នាទី លោកនិយាយថា៖ "កាលពីឆ្នាំ១៩៧៧ នៅពេលដែលមានការសម្លាប់ទ្រង់ទ្រាយធំ គឺថា មាន<>កន្លែងកប់មនុស្ស<ច្រើនកន្លែង> នៅក្នុងបរិវេណទី១ រង្វង់ទី១។ អ៊ីចឹងត្រូវទៅឲ្យឆ្ងាយ គឺចេញផុតពីរបងទី២ ដើម្បីកប់សាកសពបាននោះ"។ សូមបញ្ចប់ការដកស្រង់។ យើងបានឮខាងមេធាវីការពារក្តីបានចោទប្រកាន់ថា ឌុច និយាយ -- ឌុចតូចនោះថា ប្រហែលជាមានជាង១០.០០០នាក់ ដែលបានកប់នៅក្នុងបរិវេណមន្ទីរក្រាំងតាចាន់ហ្នឹង <ហើយសពខ្លះទៀតកប់នៅក្នុងរណ្តៅក្រៅបរិវេណ>។ អ៊ីចឹងលោកអាចបញ្ជាក់បានដែរឬទេ តើចំនួនសាកសពដែលគេបោះ -- ដែលគេកប់នៅមន្ទីរក្រាំងតាចាន់ហ្នឹង នៅពេលដែលច្រើនហួសហេតុពេកទៅ គេយកទៅកប់នៅក្នុង -- នៅក្រៅរបងជុំទី១ ហ្នឹង លោកអាចបញ្ជាក់បានទេថាពិតជាអ៊ីចឹងមែន ឬក៏យ៉ាងណា?

**ឆ៖** បាទ វា បើតាមខ្ញុំមើល ដែលស្ថានទិដ្ឋភាពនៅកន្លែងនោះ គឺមិនអាច១០.០០០ទេ។ ខ្ទង់ប្រហែលជា១០.០០០ជាង សព្វថ្ងៃនេះអដ្ឋិធាតុគាស់រករណ្តៅ រកមាស រកប្រាក់សម័យ៧៩ ហ្នឹង ឡើងព្រះគេសកន្លែងក្រាំងតាចាន់ហ្នឹងវា១០.០០០នាក់ជាងទៅហើយ ចុះទម្រាំនៅភូមិខាងក្រៅ កន្លែងកប់ខាងក្រៅនេះ វាពេញភូមិទាំងអស់ អាខាងក្រៅនេះ។ អារបងទី១ខាងក្រៅ អារបង ផុតរបងទី២នេះ គឺភូមិខាងលិចនេះណែនពេញទាំងអស់ មិនទាន់គាស់ទេ។ សព្វថ្ងៃនៅសពនៅកន្លែងហ្នឹងទាំងអស់ អត់ទាន់គាស់ទេភូមិហ្នឹង។

[១៥:២១:២៨]

**ស៖** តើលោកអាចនិយាយប្រាប់ ជូនតុលាការបានដែរឬទេថា លោកខ្លួនឯងផ្ទាល់ហ្នឹង លោកក៏ត្រូវបានជីករណ្តៅនៅខាងក្រៅរបងទី១ដែរ ដើម្បីកប់សាកសពនោះ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំបានជីក វាឲ្យទៅជីក ខ្ញុំពីរនាក់តាចិន ហើយនិង អាខា មួយទៀត។ បីនាក់ជីករណ្តៅនៅខាងក្រៅអាកន្លែងជិតវ៉ៃក្មេងនេះ។ ខាងត្បូងវ៉ៃក្មេងហ្នឹងរណ្តៅមិនអាចចាំបាន ប្រហែលជាស្មានប្រហែលជាអាចជាប្អូនដប់ម្ភៃរណ្តៅប៉ុណ្ណឹងទេ។ ប៉ុន្តែមួយរណ្តៅវាមាន៣០ មាន២០ មាន១០ ខាង

ត្បូងហ្នឹងបាទ។ មិនអាចចាំបានវាយូរឆ្នាំភ្លេចខ្លះហើយ យូរពេក។

**ស៖** <> ប្រធានបទចុងក្រោយ នៅក្នុងរបាយការណ៍កំណត់ទីតាំងក្រាំងតាចាន់ហ្នឹង គឺឯកសារ D125/220 ជារបាយការណ៍ដែលសហថៅក្រុមស៊ើបអង្កេតបាន<ព្រាង> ដែលឈរលើមូលដ្ឋាននៃចម្លើយរបស់លោក នៅពេលដែលលោកបានជូនពួកគាត់ទៅកន្លែងនោះ។ នៅក្នុងរបាយការណ៍នោះមានសរសេរ ដូចតទៅនេះ "គឺថារណ្ដៅមានជម្រៅពី១ម៉ែត្រ ទៅ១ម៉ែត្រកន្លះតែប៉ុណ្ណោះ គឺថារាក់ពេកទៅពីរបីថ្ងៃក្រោយមកនោះផ្ទុះប្រេះ ហើយដោយសារសាកសពហើម ហើយក្លិនអាក្រក់។ នៅពេលដែលក្លិននោះ<ស្អុយ>ខ្លាំងពេក<> តាអាន់ ហ្នឹងគាត់<ប្រាប់>ឲ្យ សយ សែន <ទៅ>កប់សាកសពហ្នឹងឡើងវិញ ហើយនិងជីករណ្ដៅថ្មី<>នៅកន្លែងផ្សេង។ តើលោកបានប្រាប់ទៅ<>អ្នកស៊ើបអង្កេតថា ពីរបីថ្ងៃក្រោយមកដោយសារសាកសពហ្នឹងហើមខ្លាំងពេកទៅប្រេះផ្ទុះ លោកបានប្រាប់ទៅអ្នកស៊ើបអង្កេតអ៊ីចឹងមែនទេ?

[១៥:២៣:៤០]

**ឆ៖** បាទ បានប្រាប់មែន។ បើប្រធានមន្ទីរហ្នឹង តាអាន់ ហ្នឹងគាត់ កាលណាប្រេះផ្ទុះពេលវាប្រេះដីធុំក្លិន ថាធុំក្លិនខ្លាំងចូលទៅកន្លែងគុកហ្នឹងខ្លាំង គាត់ដើរជិតខ្ញុំហ្នឹង គាត់ធ្វើច្រមុះ "អ្ហឺស១! អាសែនអ្លែងទៅត្បូង! គ្រាន់តែប៉ុណ្ណឹង ខ្ញុំក៏ដឹងថាល្បិចគាត់ ម៉ូគាត់ដឹងតែឲ្យខ្ញុំយកចបទៅលុបអាដីធុំក្លិនមិនឲ្យប៉ះពាល់អ្នកដែលជាប់គុកនៅក្នុងគុកបាទ មិនឲ្យក្លិនមកកន្លែងគុក។

**ស៖** ផ្ទុយទៅវិញ នៅពេលដែលសាកសពទាំងអស់នោះ ស្អុយរលួយអស់ទៅនៅសល់តែឆ្អឹងនោះ តើឃើញមានថាដីស្រុតចុះទៅទេ នៅតាមរណ្ដៅទាំងអស់នោះ ពីពេលដែលហើមខ្លាំងនោះ ប្រេះផ្ទុះដល់តែពេលស្អុយរលួយអស់ទៅ តើផ្ទុះ ឬក៏រណ្ដៅសាកសពទាំងអស់នោះស្រុតទៅក្រោមទេ?

**ឆ៖** បាទ អាហ្នឹង--

**ប្រធានអង្គជំនុំ៖**

ឈប់១ ស្នូត្រ សាំង សូមលោកឆ្លើយឲ្យបានយឺត១បន្តិច ព្រោះអ្នកបកប្រែ បកប្រែភាសាដែលលោកឆ្លើយ ចម្លើយដែលលោកឆ្លើយហ្នឹងមិនទាន់ទេ។ សូមលោកបន្ថយល្បឿន បានន័យថា លោកនិយាយឲ្យបានយឺតជាងហ្នឹង។

[១៥:២៥:០៨]

**លោក សយ សែន៖**

**ឆ៖** បាទ កាលណាស្អុយៗរលួយអ៊ីចឹងទៅ វាផតទៅក្រោមអស់អ៊ីចឹង។ ថ្ងៃក្រោយ គាត់វ៉ៃប្អូនប្រាំនាក់ គាត់វ៉ៃដាក់ថែមពីលើហ្នឹង។ វ៉ៃថែមពីលើហើយ គាត់ប្រើខ្ញុំឱ្យទៅលុបខ្មោចហ្នឹង បាទ។

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

**ស៖** អ៊ីចឹង បើខ្ញុំមិនច្រឡំទេ គឺថារណ្ដៅទាំងអស់នោះ គេប្រើច្រើនដង នៅពេលដែលសាកសពនៅម្ដុំនោះស្អុយរលួយអស់ទៅនុំង វាសល់កន្លែងដើម្បី<គេ>យកសាកសព<ថ្មី>ទៅដាក់នៅរណ្ដៅចាស់ហ្នឹងថែមទៀត ហើយ<បន្ទាប់មក លោកត្រូវ>កប់រណ្ដៅហ្នឹងថែមទៀតទៅ។ តើខ្ញុំនិយាយដូច្នេះត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ពិតប្រាកដហើយ បាទ។

**ស៖** លោកនិយាយអំពីតួនាទីរបស់<សឿន ឬ>ស៊ាន់ ដែលជានីរសារ<នៅ>មន្ទីរក្រាំងតាចាន់។ គាត់រូបគាត់ផ្ទាល់ ពេលដែលគាត់មកផ្ដល់សក្ខីកម្មទីនេះ គាត់បាននិយាយថា គាត់មិនមែនជាអ្នកយកសារពីមន្ទីរស្រុកមកមន្ទីរក្រាំងតាចាន់ទេ ក៏ប៉ុន្តែគាត់យក<តែ>លិខិតពីមន្ទីរក្រាំងតាចាន់ ទៅមន្ទីរស្រុកតែប៉ុណ្ណោះ។ ហើយគាត់បាននិយាយថា មាននីរសារស្រុកមួយដែលឈ្មោះ ហ៊ុល ដែលទទួលបន្ទុកក្នុងការរត់សំបុត្រមកឱ្យ តាអាន់ នៅមន្ទីរសន្តិសុខក្រាំងតាចាន់។ តើឈ្មោះ ហ៊ុល នេះដែលជានីរសារស្រុកនោះ លោកស្គាល់ឈ្មោះគាត់ទេ ស្គាល់គាត់ទេ?

[១៥:២៧:០៨]

**ឆ៖** បាទស្គាល់ ប៉ុន្តែមិនដឹងគាត់ជានីរសារ-មិននីរសារ អត់ស្គាល់ទេ ដឹងតែស្គាល់ ហ៊ុល ស្គាល់។

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ លោកប្រធាន។ ខ្ញុំសង្ឃឹមថា គាត់អាចត្រឡប់ទៅផ្ទះគាត់វិញបាននៅល្ងាចនេះ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដី។

ជាដំបូងនេះ ក្រុមមេធាវីការពារក្ដីលោក នួន ជា។ សូមអញ្ជើញ!

[១៥:២៧:៤៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដើម្បីជាការរៀបចំ ដូច្នេះខ្ញុំចង់ដឹងថាតើមេធាវីការពារក្ដីត្រូវការពេលប្រហែលប៉ុន្មានដែរ នៅ

រសៀលនេះ? ព្រោះ<យើងទើបតែឮថា>ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតែត្រឡប់ទៅវិញនៅល្ងាចនេះ។ ដូច្នេះហើយ យើងត្រូវការពេលវេលា ដើម្បីធ្វើការរៀបចំ<ការធ្វើដំណើររបស់គាត់>។

**លោក វ៉ិចទ័រ កូប៉េ៖**

និយាយតាមត្រង់ទៅ ខ្ញុំគិតថាយើងអាចបញ្ចប់នៅមុនម៉ោងបួន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំនឹងសួរបន្តពីអ្វីដែលព្រះរាជអាជ្ញាបានសួរ ទាក់ទងទៅនឹងការស្ទុយរលួយ<>សាកសព។ ខ្ញុំទើបតែឮលោកបាននិយាយថា មាន<សាកសព>ចំនួនប្រហែលជា ១០.០០០<នាក់>ត្រូវបានគេសម្លាប់<នៅកន្លែងនោះ>។ ហើយលោកក៏បាននិយាយ<ដែរ>ថា គឺលោកធ្លាប់ទៅកន្លែង<នោះ លើសពីរដង ហើយ>ឥឡូវនេះជាកន្លែងរំឭកការចងចាំ<>ក្រាំងតាចាន់។ នៅពេលដែលត្រឡប់ទៅវិញនោះ លោកឃើញចេតិយ ហើយលោកឃើញកន្លែងតម្កល់អដ្ឋិធាតុស្តូប។ តើលោកដឹងថា តើមានលលាដ៍ក្បាលប្រហែលជាប៉ុន្មានដែរ នៅក្រាំងតាចាន់ នៅកន្លែងរំឭកៗវិញ្ញាណក្ខន្ធនោះ?

**លោក សយ សែន៖**

**ឆ៖** បាទអាហ្នឹងខ្ញុំអត់បានរាប់មើលទេ ទាល់គណៈកម្មការគាត់នៅកន្លែងហ្នឹង ហើយនិងមានយុវសន្តិភាពគាត់អ្នកនៅកន្លែងហ្នឹង បាទ។

**ស៖** តើលោកដឹងទេថា<>ចំនួនមនុស្សប្រហែលជា១០.០០០នាក់<ដែលលោកទើបបានផ្ដល់អម្បាញ់មិញ>ធៀបជាមួយនឹងលលាដ៍ក្បាលដែលលោកឃើញនេះ តើវាមានចំនួនប្រហាក់ប្រហែលគ្នា ឬមួយយក៏ខាងខុសគ្នា?

[១៥:៣០:០៣]

**ឆ៖** បាទ បើតាមមើលតាៗ និងគណៈកម្មការហើយនិងយុវសន្តិភាព កាលហ្នឹងគាត់ចាប់ផ្ដើមរាប់ ដឹងពីឆ្នាំណាមក មានបញ្ជីនៅហ្នឹងដែរ ប៉ុន្តែខ្ញុំអត់បានចងចាំពីបញ្ហាហ្នឹង ប៉ុនថាខ្ទង់មួយម៉ឺនជាងបាទ ប៉ុន្តែមួយម៉ឺនជាង ក៏ខ្ញុំមិនសូវនេះប៉ុន្មានដែរវា ដូចមនុស្សវាច្រើនណាស់។ ឥឡូវ វានៅអាភូមិខាងលិចអត់ទាន់មានគាស់មួយផង នៅវណ្ដៅនៅពេញហ្នឹងទាំងអស់ អត់គាស់ផង។

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណី ជាបន្តទៅទៀតនេះ ខ្ញុំមានសំណួរពីរបី ដើម្បីសួរលោក។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ហើយសំណួរនេះពាក់ព័ន្ធទៅនឹងអ្វីដែលកើតឡើងក្រោយពេលលោកផ្ដល់សក្ខីកម្មនៅ<មុខអង្គជំនុំជម្រះ>គឺនៅថ្ងៃ០៦ ខែកុម្ភៈ ឆ្នាំ២០១៥នេះ។ <លោកប្រធាន> ខ្ញុំយោងទៅលើឯកសារ <D219/203> ខ្ញុំគិតថាប្រហែលជាឥឡូវនេះគេដូរទៅជាលេខ E ហើយមើល់ទៅ <តែខ្ញុំមិនឃើញមាននៅក្នុងឯកសាររបស់ខ្ញុំទេ>គឺមានលេខ01072285។ ដែលក្នុងនេះគឺមានរបាយការណ៍<ជជែកដេញដោលគ្នា> ហើយខ្ញុំគិតថាប្រហែលជាលោកយល់ថាខ្ញុំ<កំពុង>យោងទៅលើឯកសារណាមួយ<ហើយ>។ លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកចាំទេថានៅថ្ងៃ នៅក្រោយថ្ងៃ០៦ ខែកុម្ភៈ គឺ<បន្ទាប់ពីថ្ងៃដែលលោកបានផ្ដល់សក្ខីកម្មរួចមក តើ>មានអ្នកស៊ើបអង្កេតរបស់អង្គជំនុំជម្រះទៅជួបលោក<ដែរទេ>?

**ផ៖** បាទ អត់ទេ។

**ស៖** ក្រោយពេលដែលលោកបញ្ចប់សក្ខីកម្មរបស់លោក អ៊ីចឹងលោកមិនបានជួបជជែកជាមួយអ្នកស៊ើបអង្កេតបរទេសដែលមានអ្នកបកប្រែខ្មែរអមជាមួយទេ <>អ៊ីចឹងមែនទេ?

**ផ៖** បាទ ខ្ញុំស្ដាប់អត់បានទេ សូមមានប្រសាសន៍ម្ដងទៀតមក។

**ស៖** នៅពេលដែលលោកបញ្ចប់សក្ខីកម្មកន្លងមកនោះ ខ្ញុំគិតថា -- ខ្ញុំជឿជាក់ថាលោកបានជួបជជែកជាមួយអ្នកស៊ើបអង្កេត<អន្តរជាតិប្រហែល១០នាទី> សួរលោកអំពីបញ្ហាមួយចំនួន ខ្ញុំគិតថានៅក្រៅសាលសវនាការនេះ។ តើ<អ៊ីចឹងមែន>ទេ?

**ផ៖** បាទមាន គាត់ទៅជួបខ្ញុំដើម្បីទំនាក់ទំនងជាមួយខ្ញុំ ការភ័យខ្លាចនឹងឡើងមកសវនាការ។ កុំឲ្យភ័យ កុំឲ្យខ្លាច តាំងចិត្តឲ្យក្លាហាន ឲ្យស្មារតីឲ្យរឹងប៉ឹង កុំឲ្យភ័យឲ្យខ្លាចបាទ។ ប៉ុន្តែខ្ញុំនៅតែខ្លាច នៅតែញ័រ នៅតែខ្លាចបាទ។

[១៥:៣៣:៣៦]

**ស៖** តើលោកចាំទេថាគាត់សួរលោកអំពី សួរសំណួរលោកអំពី វ៉ាត់ ហើយនិងម្ដាយរបស់គាត់ គឺ យាយញ៉ែ។ តើគេមានសួរលោកអំពីបញ្ហានេះទេ?

**ផ៖** បាទ អត់ទេបាទ។

**ស៖** តើគេមានសួរលោកអំពីអ្វីដែលកើតឡើងចំពោះ វ៉ាត់ នៅក្រាំងតាចាន់។ តើលោកចាំថាលោកធ្លាប់ប្រាប់អ្នកស៊ើបអង្កេតហ្នឹងអំពីបញ្ហានេះទេ?

**ផ៖** បាទ ដែល ប្រាប់។

**ស៖** តើលោកចាំទេថាលោកប្រាប់គាត់ថាយ៉ាងម៉េច<ខ្លះ>?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ឆ៖** បាទ ប្រាប់ថា ឌុច គាត់ចេះតែរឡេះរឡោះគាត់ដៃជើង ដៃអីលូកលើ លូកក្រោមជាមួយ អ៊ីរ៉ាត់ តែប៉ុណ្ណឹងបាទ។

**ស៖** តើលោកប្រាប់គាត់តែប៉ុណ្ណឹងទេ ប្រាប់ថា ឌុច <ប្រព្រឹត្ត>តែប៉ុណ្ណឹងទេ<ចំពោះ>រ៉ាត់ អ៊ីចឹងមែនទេ?

[១៥:៣៥:០៦]

**ឆ៖** បាទ។

**ស៖** ដូច្នេះដើម្បីច្បាស់ គឺថាខ្ញុំអាចសួរសំណួរហ្នឹងជាសាធារណៈ។ អ៊ីចឹងមានន័យថា ឌុច មិនដែលរំលោភ រ៉ាត់ ទេ <នេះតាមចម្លើយរបស់លោក>។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អត់ទេ ដើរតែឡេះឡោះដែល លូកលើលូកក្រោមបាទ។

**ស៖** តើលោកមានបាននិយាយជាមួយអ្នកស៊ើបអង្កេតហ្នឹងអំពីនារីម្នាក់ រុន ដែរឬទេ?

**ឆ៖** បាទ អ៊ីរុន ក៏អត់ដែលបាននិយាយជាមួយគ្នាប៉ុន្មានទេ អ៊ីរុន គាត់ -- ដល់រឿងថាគាត់រត់ចេញពីឆ្នាំ៧៩ វៀតណាមបុកមកហ្នឹង គាត់រត់ទៅឡើងព្រៃជាមួយ តាអាន់ ទៅ ខ្ញុំនៅឯកន្លែងគុកនោះ។ នៅគុកជាមួយតាចិន តាអីនៅទាំងអស់គ្នា នៅមូលគ្នានេះ។ គាត់រត់ទៅព្រៃបានជួប អ៊ីរុន ថ្ងៃក្រោយនេះ អ៊ីរុន គាត់ថា តាអាន់ យកគាត់ ណែនាំយកគាត់ដើម្បីឲ្យរស់រានមានជីវិតជាមួយគាត់ កុំប្រាប់គាត់ថាគាត់ជាប្រធានគុក។

**ស៖** តើលោកមានប្រាប់បញ្ហាហ្នឹងទៅអ្នកស៊ើបអង្កេតដែលថា <រុន> ហ្នឹង គាត់មាន<> ស្នេហាជាមួយ តាអាន់ នៅក្រាំងតាចាន់ដែរឬទេ?

**ឆ៖** បាទ ដែរ។

[១៥:៣៦:៥១]

**ស៖** តើលោកមានបានប្រាប់អ្នកស៊ើបអង្កេតអំពីអាសយដ្ឋានបច្ចុប្បន្នរបស់គាត់ដែរឬទេ? ឬក៏ប្រាប់ថា រុន នៅរស់រានមានជីវិតដែរឬទេ?

**ឆ៖** បាទ នៅសព្វថ្ងៃគាត់នៅស្រុកដងទង់ ខេត្តកំពត។

**ស៖** តើលោកដឹងដែរឬទេថា រុន គឺជាមិត្តភក្តិរបស់អ្នកទោសស្ត្រីម្នាក់ដែលធ្លាប់ជាពេទ្យដែរឬទេ គឺនារីម្នាក់ឈ្មោះ ហាន នោះ។ តើជាមិត្តភក្តិដែរឬទេ?

**ឆ៖** បាទ មិត្តភក្តិគាត់ពីរនាក់ អ៊ីហាន នៅខាងជើងអង្គរកា ស្រែខ្វារ។

**សៈ** អ៊ីចឹង រុន ហើយនិង ហាន ជាមិត្តភក្តិគ្នា ឬក៏ថាជាអ្នកជាប់គុកនារីដូចគ្នា។ ហើយឥឡូវពួកគេនៅរស់រានមានជីវិត អ៊ីចឹងមែនទេ?

**ឆៈ** បាទ នៅទាំងពីរ។ អ៊ីហាន ក៏នៅ អ៊ីរុន ក៏នៅ។

**សៈ** តើលោកអាចផ្តល់អាសយដ្ឋាន ឬក៏អាចប្រាប់អាសយដ្ឋានបច្ចុប្បន្នរបស់ ហាន ប្រាប់មកយើងបានដែរឬទេ?

**ប្រធានអង្គជំនុំៈ**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

បើកក្បាលមីក្រូហ្វូនផង!

**លោកស្រី ម៉ុច សុវណ្ណារីៈ**

សូមជម្រាបលោកប្រធាន នាងខ្ញុំសូមជំទាស់នូវសំណួរដែលមេធាវីការពារក្តីលោក នួន ជា បានសួរ ពីព្រោះសំណួរនេះគឺមិនទាន់ទងជាមួយនឹងសំណុំរឿងដែលយើងកំពុងតែធ្វើសវនាការនៅពេលនេះទេ ហើយវាជាព័ត៌មានដែល -- ហ្នឹងហើយ វាមិនពាក់ព័ន្ធជាមួយនឹងសំណុំរឿងនៅពេលនេះទេ។

[១៥:៣៩:២៣]

**លោក វ៊ិចទ័រ កូប៉េៈ**

នេះគឺជាការជំទាស់ថ្មីដែលខ្ញុំមិនដែលឮទេលោកប្រធាន។ ខ្ញុំគិតថាវាមានភាពពាក់ព័ន្ធខ្លាំង ព្រោះថានារីទាំងពីររូបហ្នឹងគឺត្រូវបាន<ជាប់>ឃុំនៅក្រាំងតាចាន់<។ ខ្ញុំគិតថា ឈ្មោះអ្នកទាំងពីរនេះ ក៏អាចមាននៅក្នុង>ឯកសារពីក្រាំងតាចាន់<ដែរ>។ ហើយការស្វែងរកនារីទាំងពីរ ហើយនិងឲ្យអញ្ជើញគាត់មកផ្តល់សក្ខីកម្ម គឺជួយដល់ការស្វែងរកការពិត។ ដូច្នេះហើយទើបខ្ញុំសួរសំណួរអំពីអាសយដ្ឋានរបស់នារី ហាន និង រុន ហើយខ្ញុំគិតថាវាពាក់ព័ន្ធយ៉ាងខ្លាំង។

**ប្រធានអង្គជំនុំៈ**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់នេះ។ ហើយអង្គជំនុំជម្រះក៏ត្រូវការស្តាប់ព័ត៌មានពាក់ព័ន្ធជាមួយនឹងបុគ្គលពីររូបហ្នឹងដែរ។ ហើយប្រសិនបើមានលទ្ធភាពអាចនឹងស្វែងរកបាននោះ វាជាការល្អប្រសើរសម្រាប់បញ្ជាក់ស្វែងរកការពិតក្នុងរឿងនេះ។

សាក្សីស្តាប់ ផ្តល់ចម្លើយតបទៅនឹងសំណួររបស់មេធាវីការពារក្តី!

ប្រតិចារិកដែលត្រូវបានកែតម្រូវៈ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**លោក សយ សែន៖**

**ឆ៖** បាទ ស្គាល់។ ខ្ញុំបង្ហាញអាសយដ្ឋានគាត់បាន។ អ៊ីហាន នៅភូមិពោធិ៍ដុះ ឃុំមឿងចារ ស្រុក--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំចង់ឲ្យលោកសរសេរ <អាសយ>ដ្ឋាននៅលើក្រដាសវិញ ប្រសិនបើលោកស្គាល់អាសយដ្ឋានរបស់ ពួកគាត់ទាំងពីរនេះ។ ហើយសូមឲ្យអ្នកណាម្នាក់ជួយប្រគល់ក្រដាសមួយសន្លឹកជូនដល់គាត់ដើម្បីឲ្យគាត់អាចសរសេរអាសយដ្ឋាននៅលើក្រដាសនោះវិញ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

លោកស្រីចៅក្រម ខ្ញុំគិតថាកាលពីសវនាការថ្ងៃទី០៤ ដល់ ទី០៦ ខែកុម្ភៈ ដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹងបាននិយាយថា គាត់មិនចេះអានទេ។ អ៊ីចឹងខ្ញុំគ្រាន់តែជាការរំឭកទេលោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការជួយសរសេរគាត់ទៅ ឲ្យគាត់ប្រាប់ទៅលោកទៅ ហើយលោកសរសេរ។

[១៥:៤៤:២០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកដើមបណ្ដឹងរដ្ឋប្បវេណី តើលោកអាចប្រាប់ឈ្មោះពេញរបស់បុគ្គលនេះបានទេ ពីព្រោះមើលទៅឈ្មោះឃើញតែមួយកំណាត់ទេ មិនដឹងថាជាឈ្មោះនាមត្រកូល ឬក៏នាមខ្លួនទេ។ ដូច្នេះ តើលោកអាចដឹងឈ្មោះពេញរបស់បុគ្គលហ្នឹងដែរឬទេ? ជួយប្រាប់ទៅគាត់ផង។

*(មន្ត្រីតុលាការកត់ត្រាព័ត៌មានបន្ថែមពីដើមបណ្ដឹងរដ្ឋប្បវេណី)*

**ប្រធានអង្គជំនុំ៖**

ហើយអ៊ីចឹងឈ្មោះដាក់ "អ៊ី"ៗ ខាងដើមមិនមែនត្រកូលគាត់ទេអី? ហៅឈ្មោះ អ៊ី ចៃ មីង ហ្នឹងទេអី?

**លោក សយ សែន៖**

បាទ លោកប្រធាន។ ហ្នឹងខ្ញុំកាលហ្នឹងគាត់ហៅគាត់ថា អ៊ីរុន ហើយអ៊ីហាន។ ហៅតែពីរនាក់អ៊ីចឹង។ ប៉ុន្តែសម័យបច្ចុប្បន្ន ខ្ញុំទៅដល់ផ្ទះគាត់ហើយ បើគាត់ -- បើមានពេលឱកាសទំនេរចាំទាក់ទងមក ខ្ញុំៗជូនគាត់ទៅដល់មួយភ្លែត បាទ។

**ប្រធានអង្គជំនុំ៖**

ហើយលោកប្រាប់តែស្រុកអ៊ីចឹង លោកស្គាល់ឃុំទេ ឬក៏ភូមិដែលគាត់នៅទេ? ឈ្មោះ រុន ណ៎ះ?

**លោក សយ សែន៖**

បាទ ស្គាល់លោកប្រធានបាទ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការ ឲ្យគាត់សរសេរឈ្មោះ រុន និងឃុំ និងភូមិ -- នេះៗសរសេរនេះថែម។ សរសេរនៅក្រដាសស្អាត សរសេរមក ដើម្បី--

*(មន្ត្រីតុលាការកត់ត្រាព័ត៌មានបន្ថែមពីដើមបណ្តឹងរដ្ឋប្បវេណី)*

[១៥:៤៦:២៩]

**ប្រធានអង្គជំនុំ៖**

សរសេរឈ្មោះតែម្តងទៅកុំបាច់ដាក់អ៊ីហ្នឹង – "អ៊ី"មិនមែនត្រកូលទេ។ ណោះ! ដាក់ឈ្មោះអ៊ីចឹងទៅ ដាក់ភេទស្រីទៅ!

**លោក ឌេល លីសាក់៖**

ក្នុងពេលដែលដើមបណ្តឹងរដ្ឋប្បវេណីកំពុងតែផ្តល់ព័ត៌មាននេះ ដើម្បីជាកំណត់ត្រា ខ្ញុំគិតថាប្រហែល<ឯកសារនេះអាច>ជួយ<បានខ្លះ។ អ្នកដែលគាត់ចង់និយាយនោះ> មានឈ្មោះ <ពេញក្នុង>ឯកសារ D157.7, ខ្មែរមានលេខ 00270804, អង់គ្លេសមានលេខ 00866433 ដល់ 34, បារាំងមានលេខ 00872808 ដល់ 09។ ហើយនៅក្នុងឯកសារនេះ គឺមានទាំងឈ្មោះពេញ ក៏ដូចជាឈ្មោះហៅក្រៅរបស់បុគ្គលទាំងអស់នេះ។ ដូច្នេះ គឺថាយើងអាចពិនិត្យទៅលើឈ្មោះពេញនៅក្នុងឯកសារទាំងអស់នេះបាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសហព្រះរាជអាជ្ញារងអន្តរជាតិ។ សូមអញ្ជើញលោក រ៉ុចទ័រ កូប៉េ!

[១៥:៤៨:៣៨]

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** លោកដើមបណ្ដឹងរដ្ឋប្បវេណីខ្ញុំមានសំណួរទាក់ទងនឹងនារីម្នាក់ទៀត គឺអ្នកទោសនារីម្នាក់។ តើលោកស្គាល់នារីម្នាក់ឈ្មោះ សិទ្ធ យ៉ែម ដែរឬទេ?

**លោក សយ សែន៖**

**ឆ៖** បាទ ដូចអត់ដែលឮឈ្មោះ។

**ស៖** អត់បញ្ហាទេ ប៉ុន្តែឥឡូវនេះ ខ្ញុំនិយាយអំពីនារីបីនាក់ទៀតគឺ វ៉ាត់, រុន ហើយនិង ហាន។ តើលោកចាំទេថានារីទាំងបីនាក់នេះ អាចឃើញសកម្មភាពដូចនឹងលោកបានឃើញ។ មានន័យថានារីទាំងបីនាក់ហ្នឹង គាត់អាចឃើញសកម្មភាពរបស់អ្នកយាមដូចដែលលោកបានឃើញ។ តើវាអ៊ីចឹងមែនទេ?

[១៥:៤៩:៥០]

**ឆ៖** បាទ ស្គាល់ បីនាក់ហ្នឹងស្គាល់ទាំងបី។

**ស៖** យើងដឹងអំពីចំណុចទាំងអស់នេះហើយ ប៉ុន្តែខ្ញុំចង់សួរថាតើលោកអាចប្រាប់បានទេថានារីទាំងបីនាក់ហ្នឹង <កាលជំនាន់ហ្នឹង> នារីទាំងបីនាក់ហ្នឹង <ពួកគេ>អាចឃើញនូវហេតុការណ៍ដូចគ្នានឹងលោកបានឃើញ <គឺ>ហេតុការណ៍ដែលអ្នកយាមហ្នឹងគេបានប្រព្រឹត្ត <តាមអ្វី>ដូចដែលលោកបានរៀបរាប់អ៊ីចឹង។ តើគាត់អាចមើលឃើញអ៊ីចឹងមែនទេ?

**ឆ៖** បាទ អាហ្នឹងខ្ញុំអត់ប៉ានថាដែរ ចំពោះរូបគាត់បាទ។

**ស៖** ខ្ញុំនឹងបន្តទៅមុខទៀត។ នៅពេលមុននេះបន្តិចលោកបានរៀបរាប់ថាតួនាទីរបស់អ្នកយាម អ្នកយាមមានតួនាទីមួយ គឺតួនាទីចាប់អ្នកទោស<>។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន គឺតែកងទ័ពមានសិទ្ធិនៅកន្លែងនោះ គឺកាប់សម្លាប់ ចាប់ ជូនអីលើកងទ័ពទាំងអស់បាទ។

**ស៖** អ៊ីចឹងលោកចង់ផ្ដល់សក្ខីកម្មថា ពួកអ្នកយាមហ្នឹង មិនមែនត្រឹមតែយាមនៅក្រាំងតាចាន់ទេ ប៉ុន្តែពួកអ្នកយាមហ្នឹងអាចទៅចាប់អ្នកភូមិយកមកក្រាំងតាចាន់ហ្នឹងទៀត។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំដឹងគាត់ទៅយកឃុំឆ្ងាយៗ ដូចជាឃុំស្រែរនោង លាយបូរ។ ហ្នឹងឃើញគាត់ទៅ

យកពីស្រែរនោងញ៉ែកញាប់ជាងគេ។ សួរអ្នកទោសថា នៅស្រែរនោងបាទ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ លោកដើមបណ្ដឹងរដ្ឋប្បវេណី នៅមុននេះបន្តិចគឺលោកបាននិយាយថា ហេតុផលដែលលោកមកផ្ដល់សក្ខីកម្ម គឺលោកចង់ស្វែងរកការពិត ហើយ<តាមពិតទៅ> លោក<តាងនាមឲ្យ> -- <ខ្ញុំសូមដកស្រង់ "តាងនាម>ឲ្យអ្នកដែលបានស្លាប់បាត់បង់ជីវិតទៅ"។ ដូច្នេះ <>តាម<បេសកម្មនេះ>អ្វីដែលលោកបានរៀបរាប់ហ្នឹង តើវាជាការត្រឹមត្រូវដែរឬទេដែលថា ពេលខ្លះលោក<>មិន<បាន>និយាយការពិតប្រាប់អង្គជំនុំជម្រះនោះទេ?

**ឆ៖** ខ្ញុំស្ដាប់អត់សូវបាទ សូមគាត់មានប្រសាសន៍ម្ដងទៀតបាទ។

**ស៖** <នៅរសៀលនេះ> មុននេះបន្តិចលោកនិយាយថា លោកមានបេសកម្មមួយដើម្បីស្វែងរកការពិត ហើយលោកធ្វើឡើងក្នុងនាមអ្នកដែលបានស្លាប់បាត់បង់ជីវិតទៅ។ ដូច្នេះអ្វីដែលខ្ញុំចង់សួរលោកថា នៅពេលដែលលោកនិយាយថាលោកធ្វើដើម្បីអ្នកដែលបានស្លាប់បាត់បង់ជីវិតទៅ តើវាអាចដែរឬទេថា ពេលខ្លះលោកមិនបាននិយាយការពិត ឬក៏លោកនិយាយកុហកអំពីអ្វីដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រាប់អង្គជំនុំជម្រះដែរឬទេ?

[១៥:៥៣:២៤]

**ឆ៖** បាទ រឿងជាពិតប្រាកដ ទោះបីខ្ញុំកុហកមិនដឹងកុហកមានការអី ឬក៏មានន័យអី។ រឿងនេះខ្ញុំអត់មានកាឡៃ ហើយក៏អត់មានកុហកភូតភរនៅតុលាការដែរ។ វាអត់មានផលប្រយោជន៍ទៅលើរូបខ្ញុំប៉ុន្មាន គឺអត់មានទេ មានតែ ដើម្បីខ្ញុំឡើងមកនេះ ដើម្បីផលប្រយោជន៍ដែលអ្នករងគ្រោះ អតីតទូទាំងប្រទេសដែលស្លាប់ដោយជំនាន់ ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដោយក្រោមការដឹកនាំ ដែលមិនដែលស្គាល់នោះតែប៉ុណ្ណឹងទេបាទ។

**ស៖** អ៊ីចឹងខ្ញុំចង់សួរបន្តិចទៀត។ ពេលរសៀលហ្នឹងខ្ញុំបានសួរ ស្សូត្រ សាំង <ថាតើ>គាត់និយាយ<>តែការពិត និងមិននិយាយកុហកអ្វីទាំងអស់។ តើលោកនិយាយដូចគ្នាអ៊ីចឹងមែនទេ និយាយតែការពិត ហើយមិនមាននិយាយការកុហកអ្វីទាំងអស់ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រង់ណាដែលខ្ញុំឃើញ ខ្ញុំថាពិត។ ត្រង់ណាដែលខ្ញុំមិនឃើញ ខ្ញុំអត់និយាយ។ ត្រង់ណាដែលឃើញ អាហ្នឹងខ្ញុំនិយាយថាខ្ញុំឃើញ។ ដូចពីប៉ុន្មានថ្ងៃមុនៗនេះ ខ្ញុំបានស្ដាប់អាស៊ីសេរីផ្សាយពីបញ្ហា តាឆេន នៅអន្លង់វែងគាត់មកសក្ខីកម្ម។ គាត់និយាយថា "កុំឲ្យតុលាការជឿនឹង សយ សែន ពេកនៅក្មេងណាស់ វានិយាយមិនដឹងអីទេ"។ កុំថា ខ្ញុំមិនដឹង ខ្ញុំដឹងទាំងអស់ កន្លែងណាក៏ខ្ញុំដឹងដែរ ឲ្យតែនៅ

ក្នុងគុកក្រាំងតាចាន់បាទ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

*(សម្រាករយៈពេលខ្លី)*

[១៥:៥៥:៤២]

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធាន ខ្ញុំ<រង់>ចាំឲ្យលោកប្រធានអនុញ្ញាតឲ្យខ្ញុំនិយាយ។ <ខ្ញុំទទួលបន្ទុកធ្ងន់ ជាអ្នកសួរចុងក្រោយគេទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។> ឥឡូវខ្ញុំឃើញថាពេលវេលាបានទៅមុខហើយ អ៊ីចឹងខ្ញុំព្យាយាមសួរខ្លីៗឲ្យបានលឿន។ ខ្ញុំត្រូវការមន្ត្រីតុលាការដើម្បីប្រគល់ឯកសារនេះ ទៅគឺថាឯកសារ E319.1.24 ហើយសូមអាន<ខ្សឹបៗ>ឲ្យគាត់ ព្រោះគាត់អត់ចេះអានអក្សរ ត្រូវអានទៅចម្លើយ១០៧ និង ១០៨ <ឲ្យត្រូវនឹងចម្លើយដែលខ្ញុំបាន*ហាយឡាយ* ពណ៌លឿង ក្នុងសំណៅជាភាសាខ្មែរ ក្រោយពីបាន>អានជូនគាត់ ហើយបន្ទាប់មក ខ្ញុំចោទសំណួរគាត់ សំណួរបន្ត។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការជួយការងារនេះបន្តិចទៅ!

សូមអញ្ជើញសហមេធាវី -- សហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៥:៥៦:៤៧]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំដូចមិនយល់ ថាត្រូវៗ និយាយខ្សឹបដាក់ត្រចៀកអ្វីដែលសរសេរ។ អ៊ីចឹងគាត់អានជាភាសាបារាំងទៅ គេបកប្រែជាភាសាខ្មែរមកភ្លាមៗហើយ។

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំសូមអរគុណលោកសហព្រះរាជអាជ្ញាដែលផ្ដល់មធ្យោបាយនេះ ប្រាប់មធ្យោបាយនេះដល់ខ្ញុំ។ <ខ្ញុំចង់ធ្វើរបៀបនេះ ដោយសារតែ> អ្នកណាក៏គេដឹងដែរ<>ថានៅ<ក្នុង>តុលាការយើងនេះ យើង<បានអនុវត្តយូរមកហើយគឺយើង>មិនផ្ដល់អត្តសញ្ញាណ<>អ្នក<ដែលជា>ជនរងគ្រោះនៃការរំលោភបំពាន<>ផ្លូវភេទ<នោះទេ>។ <វាជារឿងសាមញ្ញប៉ុណ្ណោះ។> អ៊ីចឹងហើយ បានខ្ញុំប្រុងប្រយ័ត្នមិនចង់នែ៎ មិនចង់អានឈ្មោះរបស់គេនៅក្នុងសវនាការជាសាធារណៈនេះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖** អ៊ីចឹងៗសូមអានសំណួរទាំងពីរនេះទៅលោក សយ សែន គឺ១០៧, ១០៨។ បន្ទាប់មកទៀត ខ្ញុំចោទសំណួរបន្ត ដើម្បី -- អ៊ីចឹងសូមឲ្យលោកកុំនិយាយឈ្មោះដែលនៅក្នុងប៉ុន្មានឃ្លាហ្នឹង ចេញឲ្យសាធារណជនដឹង។

*(មន្ត្រីតុលាការកត់ត្រាព័ត៌មានបន្ថែមពីដើមបណ្តឹងរដ្ឋប្បវេណី)*

[១៥:៥៨:៥៩]

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

លោកមន្ត្រីតុលាការ អានសំណួរ-ចម្លើយពីរហ្នឹងទៅឲ្យគាត់ហើយឬនៅ? ខ្ញុំអាចចោទសំណួរបានទេ?

**ស៖** លោក សយ សែន សំណួររបស់ខ្ញុំដូចតទៅនេះ៖ តើលោកចាំថា បានឆ្លើយថាអ្នកទោស <ស្រី>ម្នាក់ត្រូវបានគេចាប់រំលោភនៅមន្ទីរក្រាំងតាចាន់ ហើយដែលបានផ្តល់ឈ្មោះ អ្នកៗដែលគេចាប់រំលោភនេះផងដែរទៅសហចៅក្រមស៊ើបអង្កេត ដែលថា -- ហើយលោកក៏បានប្រាប់ផងដែរថា ម្តាយរបស់ស្ត្រីដែលគេរំលោភហ្នឹងបានរៀបរាប់រឿងហ្នឹងប្រាប់លោក។ អ៊ីចឹង ខ្ញុំសួរលោកថា លោកនៅចាំថាខ្លួនឯងបាននិយាយយ៉ាងដូច្នេះទៅសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**លោក សយ សែន៖**

**ឆ៖** បាទ នៅចាំ ប៉ុន្តែគាត់មិនបានរំលោភទេ គាត់បានត្រឹមមកលូកលើលូកក្រោមបាទ។ ជាមួយស្ត្រីដែលពីរនាក់យកទៅសម្លាប់ហ្នឹង ហ្នឹងបានគាត់រំលោភហើយ បានគាត់សម្លាប់។ យកគ្រាប់ក្បាលម៉ាជិនហើយ បានគាត់ឲ្យខ្ញុំទៅលុបខ្មោចហ្នឹងកាលហ្នឹង អាហ្នឹងបានខ្ញុំនៅចាំ បាទ។

*(សម្រាករយៈពេលខ្លី)*

[១៦:០០:២១]

**ស៖** លោក សយ សែន ហេតុអីក៏លោកបាននិយាយថាស្ត្រីហ្នឹងត្រូវបានរំលោភ។ ផ្ទុយទៅវិញនៅក្នុងសវនាការនេះ <និងសវនាការចុងក្រោយ> លោកនិយាយ<>ថា<ពួក>គាត់មិនត្រូវបានគេរំលោភទេ<?> អ៊ីចឹង ខ្ញុំសួរលោកថា ហេតុអីក៏អង្គាល់លោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេតនោះ លោកឆ្លើយថាគាត់ហ្នឹងត្រូវបានគេចាប់រំលោភ បើសិនហ្នឹងរឿងហ្នឹងមិនពិតផងនោះ?

**ឆ៖** បាទ គាត់ច្រឡំៗទេបាទ ច្រឡំនារីវាមានពីរនាក់។ អ៊ីវ៉ាត់ហ្នឹង គាត់ចាប់រឡេះរឡោះផ្សេង

សម្លាប់នោះ អាហ្នឹងអ្នករំលោភហើយបានសម្លាប់ក្រោយ។ គាត់ច្រឡំកន្លែងហ្នឹងទេ។

**ស៖** <ក្នុងសក្ខីកម្មរបស់លោក ខ្ញុំ>សូមកុំឱ្យឆ្លើយឈ្មោះ<។ ខ្ញុំសួរម្តងទៀត> ហេតុអ្វីក៏លោកបានឆ្លើយទៅសហចៅក្រមស៊ើបអង្កេតថាស្ត្រីនោះត្រូវបានចាប់រំលោភ បើវាមិនមែនជាការពិតផងនោះ ម៉េចក៏លោកប្រាប់ថាគាត់ហ្នឹងត្រូវបានគេចាប់រំលោភ?

**ប្រធានអង្គជំនុំ៖**

សូមសាក្សី -- ដើមបណ្តឹងរដ្ឋប្បវេណី កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[១៦:០១:៤៥]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ឥឡូវៗនេះ យើង -- សហមេធាវីការពារក្តី យើងមិនចង់រំខានគាត់ទេ ក៏ប៉ុន្តែគួរតែ ដើម្បីឱ្យ<ច្បាស់>នោះ សយ សែន គាត់មិនបានឆ្លើយយ៉ាងអ៊ីចឹងទេនៅកាលនៅថ្ងៃទី០៥ <ខែ>កុម្ភៈនោះ គាត់មិនបាននិយាយអ៊ីចឹងទេ។ គាត់អត់បាននិយាយពីការរំលោភហ្នឹងមែន គឺថាមានព្រឹត្តិការណ៍ពីរខុសគ្នា<កើតឡើង។> យើងបាននិយាយអំពីចំណុចនេះច្រើន<ហើយ> ធ្វើយ៉ាងម៉េចបែងចែក វែកញែកចំណុចហ្នឹង រឿងពីរហ្នឹងឱ្យដាច់ពីគ្នាបាទ។ <ខ្ញុំនឹងព្យាយាមនិយាយឱ្យបានយឺតបន្តិច លោកស្រីចៅក្រម ហ្វេនស៍។> ចំពោះបុគ្គលដែលគាត់បានលើកឡើងនេះ អ្វីដែលគាត់បានឃើញនោះគឺថាគេគ្រាន់តែលួកលាន់គាត់ទេ មិនបានមានការរុកកួនផ្លូវភេទអីនោះទេ<។ ចុងក្រោយ> កាលលោក កូប៉េ ចោទសំណួរទៅគាត់នោះ ពេលដែលគាត់សួរទៅដើមបណ្តឹងរដ្ឋប្បវេណីនេះថា -- សាក្សីនេះថាតើៗគាត់បានធ្លាប់បានមើលឃើញគេចាប់រំលោភបុគ្គលហ្នឹងទេ? គាត់<បាន>ឆ្លើយ<ច្បាស់>នៅម៉ោង០៩:៣៥នាទី ច្បាស់ហើយថា "អត់ទេ"។ អ៊ីចឹងត្រង់ចំណុចនេះនោះ យើងកាលនោះបញ្ហានេះ យើងពិភាក្សាគ្នាច្បាស់លាស់ហើយ។ សយ សែន បានសម្តែងមតិយ៉ាងច្បាស់លាស់កាលនៅថ្ងៃ<សវនាការ ថ្ងៃ>ទី០៥ ទី០៦ ទី០៧ ខែកុម្ភៈ <សក្ខីកម្មរបស់គាត់ច្បាស់ណាស់ហើយ។> ហើយគាត់ថាមិនបានឃើញបុគ្គល<ទាំង>នេះត្រូវបានគេចាប់រំលោភទេ។ គាត់ថា បុគ្គលរូបហ្នឹងគ្រាន់តែត្រូវបានទទួលការប្រទូស្តផ្លូវភេទតែប៉ុណ្ណឹង។ អ៊ីចឹង <ខ្ញុំចង់ឱ្យច្បាស់សម្រាប់ប្រតិចារឹក។> សូមឱ្យអង្គជំនុំជម្រះមេត្តាជ្រាបបាទ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំយល់ពីការបំភ្លឺរបស់សហវិតារបស់ខ្ញុំហើយ ក៏ប៉ុន្តែសំណួររបស់ខ្ញុំនេះវាពាក់ព័ន្ធខ្លាំងណាស់ ព្រោះថាខ្ញុំមិនមែនចង់ដឹង ឬមិនចង់ត្រឡប់មកនិយាយពីអង្គហេតុដែលថា សយ សែន ហ្នឹង រឿងដែល សយ សែន ហ្នឹងគាត់បានប្រាប់ថាគាត់មិនមែនជាសាក្សី គាត់មិនបានឃើញនោះទេ ក៏ប៉ុន្តែក៏ខ្ញុំសួរចង់ដឹងថាហេតុអ្វីបានគាត់ឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេត<អំពីរឿងរ៉ាវទាំងហ្នឹង> -- ដែលគាត់មិនដឹងផងនោះ-- <ដែលអ្វីដែលគាត់ដឹងមិនមែនជាការពិត>។ អ៊ីចឹង <ខ្ញុំគ្រាន់តែចង់សួរថា ហេតុអីបានជាគាត់ឆ្លើយប្រាប់អ្នកស៊ើបអង្កេត ក្នុងខណៈដែលរឿងនេះមិនមែនជាការពិត? សំណួររបស់ខ្ញុំគឺថា ហេតុអី? ខ្ញុំមិនបានចង់ឲ្យគាត់ឆ្លើយលម្អិតអីទេ ពីព្រឹត្តិការណ៍ដែលគាត់មិនបានឃើញ។> ខ្ញុំគ្រាន់តែចង់សួរគាត់ថា តើហេតុអីបានគាត់និយាយខុសពីការពិតនៅចំពោះមុខចៅក្រមស៊ើបអង្កេត តែប៉ុណ្ណឹងទេ អ្វីដែលខ្ញុំចង់ដឹងនោះ។

[១៦:០៤:៣៥]

**ប្រធានអង្គជំនុំ៖**

អំមិញសាក្សីដូចឆ្លើយច្បាស់លាស់ហើយជាភាសាខ្មែរ គាត់ថាមានការភ័ន្តច្រឡំ។ ដូច្នេះសំណួរនេះសំណួរច្រំដែល សាក្សីមិនបាច់ឆ្លើយទេ គាត់ឆ្លើយរួចហើយ ថាមកពីការមានការភ័ន្តច្រឡំ បើចង់សួរហ្នឹង ចង់សួរថាតើច្រឡំហ្នឹង ភ័ន្តច្រឡំមកពីអ្នកណា? មកពីអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតហ្នឹងស្តាប់ច្រឡំ ហើយសរសេរច្រឡំ ឬក៏គាត់ឆ្លើយច្រឡំ កាលពីពេលធ្វើកំណត់ហេតុនុ៎ង! បើសំណួរដដែល មិនបាច់ឆ្លើយតបទេ ដើមបណ្តឹងរដ្ឋប្បវេណី ព្រោះលោកបានឆ្លើយរួចហើយថាលោកថាមានភ័ន្តច្រឡំ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក សយ សែន លោកបានឆ្លើយថាមានការភ័ន្តច្រឡំនៅត្រង់ចំណុចនេះ ក៏ប៉ុន្តែនៅក្នុងចម្លើយលេខ១០៧ របស់លោកនេះ លោកនិយាយថា<>ម្តាយរបស់បុគ្គលរូបនេះបានរៀបរាប់រឿងការរំលោភនេះប្រាប់លោក<។ ដើម្បីជាប្រយោជន៍សម្រាប់ភាគី និងអង្គជំនុំជម្រះទាំងមូលផង> ខ្ញុំសូមឲ្យគេយោងទៅរកឯកសារ E3/5844 ដែលជាការស្តាប់ចម្លើយរបស់ម្តាយរបស់ជនរងគ្រោះម្នាក់ហ្នឹង។ ERN ភាសាខ្មែរគឺ 01056209, ជាភាសាបារាំងគឺ 01056617, ជាភាសាអង់គ្លេសគឺ 01056615។ នេះគឺជាប្រតិចារឹកដោយផ្នែក<> អំពីនៃខ្សែអាត់គេស្តាប់បុគ្គលរូបនោះ។ សំណួរខ្ញុំមានដូចតទៅនេះ៖ លោក សយ សែន លោកនិយាយថា ម្តាយរបស់ស្ត្រីនុ៎ងបាននិយាយអំពីការប្រទូស ឬក៏ការរំលោភដែល

គាត់ជាជនរងគ្រោះទទួលរង។ អ៊ីចឹងបើម្ដាយគាត់ហ្នឹង ម្ដាយស្ត្រីរូបហ្នឹងត្រូវបានស្លាប់សហថៅក្រុមស៊ើបអង្កេតហ្នឹង គាត់បាននិយាយប្រាប់ថៅក្រុមស៊ើបអង្កេតហើយថាកូនគាត់នោះមិនត្រូវបានរំលោភបំពានអ្វីនោះទេនៅមន្ទីរក្រាំងតាចាន់នោះ។ អ៊ីចឹងតើលោកឆ្លើយតបយ៉ាងម៉េចដែរ ហើយសួរលោកថាតើលោកអាចបញ្ជាក់បានដែរឬទេថាតើម្ដាយគាត់ហ្នឹង ម្ដាយស្ត្រីរូបហ្នឹងបាននិយាយថាកូនគាត់ហ្នឹង គឺថាត្រូវបានទទួលការប្រទូស្តផ្លូវភេទដែរឬទេ?

[១៦:០៧:២៧]

**លោក សយ សែន៖**

**ឆ៖** បាទ អត់ទេ។ ក្រែងថា គាត់បានតែលូកលើលូកក្រោមតែប៉ុណ្ណឹងទេ គាត់និយាយ។ ម្ដាយគាត់ប្រាប់ខ្ញុំ។

**ស៖** ដូច្នេះលោករក្សាចម្លើយថាម្ដាយរបស់ស្ត្រីរូបនោះបាន -- គាត់ហ្នឹងហើយជាអ្នកមកប្រាប់លោកថាគេហ្នឹង<>លូកលាន់កូនគាត់ហ្នឹង។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** ហើយទាក់ទងទៅនឹងការស្លាប់ ដែលគេចេះតែនាំគ្នានិយាយថាគាត់ស្លាប់ហ្នឹង អាហ្នឹងគ្រាន់តែនិយាយស្មានៗទេ ឬក៏យ៉ាងណា? ច្រឡំ?

**ឆ៖** បាទ សូមមានប្រសាសន៍ម្ដង រឿងស្លាប់ៗអ្នកណា? ស្លាប់អត់បានកន្លែងហ្នឹង។

**ស៖** ក្នុងផ្នែកដែលនៅក្នុងចម្លើយលោកនេះ លោកនិយាយអំពីការថាបុគ្គលរូបហ្នឹងស្លាប់ហើយ។ អ៊ីចឹងខ្ញុំគ្រាន់តែសួរថា នេះជាការភ័ន្តច្រឡំ<ដែលលោកប្រាប់ទៅ>អ្នកស៊ើបអង្កេតទេឬក៏យ៉ាងណាដែល -- លោកច្រឡំថាគាត់ស្លាប់ឬយ៉ាងម៉េច នៅពេលដែលលោកឆ្លើយទៅអ្នកស៊ើបអង្កេត?

**ឆ៖** បាទ ខ្ញុំបានដឹងថាស្ត្រីពីរនាក់យកមកពីស្រែរនោង ហ្នឹងគាត់រំលោភហើយ គាត់សម្លាប់ហើយគាត់យកគ្រាប់ក្បាលម៉ាជិនញុកកេរ្តិ៍ខ្មាស់ ហ្នឹងគាត់ឲ្យខ្ញុំទៅលុបខ្មោចហ្នឹង។ ហ្នឹងគាត់បានប្រាប់ខ្ញុំថា "អញធ្វើរួចហើយ អ្ហែងលុប អ្ហែងទៅឃើញអត់?" គាត់សួរសម្ពុតខ្ញុំអ៊ីចឹង "ខ្ញុំថាខ្ញុំបានឃើញបង"។ តែប៉ុណ្ណឹង។

[១៦:០៨:៤២]

**ស៖** តើអ្នកណាអ្នកប្រាប់រឿងនេះដល់លោក?

**ឆ៖** បាទ អាចបញ្ចេញឈ្មោះគេបានដែរអត់?

**ស៖** បើសិនជាមានអ្នកណារៀបរាប់រឿងហ្នឹងប្រាប់លោកនោះ <មិនមែនជាឈ្មោះរបស់ជនរងគ្រោះ ហើយជាអ្នកផ្ដល់រឿងរ៉ាវទាំងនោះមកលោក> លោកអាចទៅនិយាយប្រាប់ឈ្មោះបាន។

**ឆ៖** បាទ ប្រាប់បាន។ បងឌុច គាត់ប្រាប់ខ្ញុំអ៊ីចឹង។

**ស៖** អ៊ីចឹង ខ្ញុំត្រូវយល់ថា លោកមិនបានឃើញទេ មិនមែនជាសាក្សីទេ ប៉ុន្តែមានអ្នកផ្សេងអ្នកប្រាប់នៅពេលដែលលោកនិយាយថា ឌុច ហ្នឹង ចង់សំដៅទៅលើ ឌុចតូច ឬឌុចធំ?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី កុំអាល់ទាន់ឆ្លើយតប។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ឥឡូវខ្ញុំមានអារម្មណ៍ថា យើងច្របូកច្របល់អស់ហើយលោកប្រធាន។ យើងនិយាយអំពីការរំលោភ ឬការលួចលាន់ស្ត្រីម្នាក់ ឥឡូវនេះដើមបណ្ដឹងរដ្ឋប្បវេណីគាត់បានពន្យល់អំពីការស្លាប់របស់នារី<>ពីរនាក់<>មកពីកងចល័ត ហើយត្រូវបានរំលោភ ហើយក្រោយមកមានញាត់គ្រាប់កាំភ្លើងចូលប្រដាប់ភេទ ហើយគាត់ថា ឌុច ជាអ្នកប្រាប់គាត់។ អ៊ីចឹង ឥឡូវ ត្រូវបែងចែកព្រឹត្តិការណ៍ពីរនេះឲ្យដាច់ពីគ្នា បើមិនអ៊ីចឹងទេវាកាន់តែស្មុគស្មាញទៅៗ ពិបាកតាមណាស់ លោកប្រធាន។

**កញ្ញា អង់តា ហ្គីសសេ៖**

សំណួរ--

**ប្រធានអង្គជំនុំ៖**

កុំអាល់សិន!

[១៦:១២:២០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកស្រីមានសំណួរប៉ុន្មានទៀត ដែលត្រូវសួរ?

**កញ្ញា អង់តា ហ្គីសសេ៖**

បើសិនជាខ្ញុំអាចបំភ្លឺបាន ត្រង់ចំណុចនេះខ្ញុំមាន ត្រូវការពេល<៥នាទីសម្រាប់បញ្ចប់បញ្ហានេះ និង៣នាទីទៀតសម្រាប់សួរសំណួរផ្សេងទៀត។>បើនិយាយសរុបទាំងអស់ទៅប្រហែលជា៨នាទី<។> លោកប្រធាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:១៥:០៦]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវហ្នឹងដោយមានបញ្ហាច្របូកច្របល់មិនច្បាស់លាស់ ហើយសំណួរហ្នឹងក៏ជាការលំបាក សូម្បីតែយើជាប្រធានអង្គជំនុំជម្រះក៏ស្ដាប់នូវសំណួរដែលសួររបៀបនេះមិនបានដែរ មិនពេញលេញដែរ ។ ដើម្បីឲ្យប្រាកដប្រជា ទី១ សូមឲ្យលោកស្រីមេធាវីតាំងសំណួរណាដែលជាសំណួរអាចសួរសាធារ-ណៈបានចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះមុន។

ហើយចំណែកឯអស់ហើយ លោកស្រីប្រាប់ថាអស់ហើយ លោកស្រីចង់តាំងសំណួរពាក់ព័ន្ធជាមួយនឹង ពាក់ព័ន្ធនឹងរំលោភផ្លូវភេទនៅក្រាំងតាចាន់ លោកស្រីប្រាប់យើង ដើម្បីយើងសម្រេចថាធ្វើជាអសាធារណៈដើម្បីឲ្យលោកស្រីសួរនាំឲ្យបានច្បាស់លាស់ ដើម្បីយើងក្ដាប់បញ្ហានេះឲ្យបាន។ ជាប្រយោជន៍ដើម្បីស្វែងរកការពិតក្នុងរឿងនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំយល់លោកប្រធាន។ ខ្ញុំស្ដាប់បង្គាប់ ក៏ប៉ុន្ដែមើលទៅសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ហាមឃាត់មិនឲ្យប្រាប់ឈ្មោះជនរងគ្រោះដែលទទួលបំពានការរំលោភផ្លូវភេទ <ប៉ុន្ដែ យើងអាចលើកអង្គ-ហេតុនៅវគ្គសាធារណៈបាន>។ អ៊ីចឹង ខ្ញុំព្យាយាមធ្វើយ៉ាងណាមិនឲ្យនិយាយឈ្មោះជនរងគ្រោះដោយសារអ៊ីចឹងហើយបានខ្ញុំមិនហ៊ាននិយាយឈ្មោះ លោកប្រធាន ព្រោះថាមានសម្រេចពីអង្គជំនុំជម្រះហើយៗ។

[១៦:១៦:៤២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<>យើងចង់<ឲ្យ>លោកស្រី<មេធាវី>បន្តជាមួយសំណួរ<បន្ថែមដែលមិនពាក់ព័ន្ធនឹង> ផ្នែករំលោភ ឬក៏បៀតបៀនផ្លូវភេទ<។ លោកស្រីបានសួរសំណួរទាំងនេះនៅក្នុងសវនាការ>ជាអសាធារណៈ <អ៊ីចឹង យើងនឹងបិទធ្វើជាវគ្គអសាធារណៈវិញ ដែលអនុញ្ញាតឲ្យភាគីជជែកបញ្ហា>ឈ្មោះដោយសេរី ដើម្បីបញ្ជាក់លម្អិតទៅលើអ្វីដែលលោកស្រីចង់បញ្ជាក់បំភ្លឺទាក់ទងទៅនឹងការបៀតបៀនផ្លូវភេទនោះ។

ដូច្នេះ ឥឡូវហ្នឹងគឺថាលោកស្រីអាចសួរអ្វីដែលមិនពាក់ព័ន្ធទៅនឹងរឿងផ្លូវភេទ បន្ទាប់មកទៀត

គឺយើងនឹងចូលទៅវគ្គអសាធារណៈដែលលោកស្រីអាចសួរឈ្មោះ<ជនរងគ្រោះ> ហើយយើងអាចជជែកគ្នាបាន<ប្រសើរជាងហ្នឹង>។ តើខ្ញុំបញ្ជាក់អ៊ីចឹងច្បាស់ទេលោកស្រី?

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំយល់ច្បាស់ហើយ ខ្ញុំៗគ្រាន់តែថាចង់ មិនចង់ធ្វើជាសម្ងាត់ទេ ព្រោះថាខាតពេលវេលាតែប៉ុណ្ណឹងទេ។ ឥឡូវ ខ្ញុំធ្វើតាម។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក សយ សែន នៅក្នុងសវនាការនេះលោកបានឆ្លើយថា លោក -- នៅសវនាការថ្ងៃទី០៤ ខែកុម្ភៈ ហ្នឹង គឺឯកសារ E1/256.1 ប្រហែលជាក្រោយម៉ោង១៥:៤៥:១៥ វិនាទីបន្តិច។ សំណួរសួរថា នៅ -- លោកឆ្លើយៗថា៖ “នៅពេលដែល<យើង>នាំពួកគេទៅធ្វើស្រែ កាលហ្នឹងមានអ្នកទោសប្រាំពីរនាក់។ គឺដោយសារមានច្រើនពេកអ៊ីចឹង គឺគេឲ្យខ្ញុំនៅចាំយាមពួកគេ ហើយឲ្យប្រយ័ត្នប្រយែង បើប្រសិនជាមានអ្នកទោសរត់នោះ ខ្ញុំប្រហែលជាត្រូវបានគេសម្លាប់ហើយ។ បាទ អ៊ីចឹងហើយខ្ញុំធ្វើការងារទាំងអស់នេះ <ការដ្ឋាន>ការងារ”។ “ថ្ងៃនេះ សូត្រ សាំង <ជាអ្នកយាមម្នាក់ដែរ>បាននិយាយថា មុខការរបស់គាត់នោះមានមួយដែរ គឺថាការយាមអ្នកទោសដែរ គឺនៅពេលដែលគាត់ធ្វើការនៅបរិវេណខាងក្រៅនៃមន្ទីរក្រាំងតាចាន់”។<> សំណួរទី១របស់ខ្ញុំគឺ ចង់ដឹងថាតើអ្នកណាផ្តល់តួនាទីយាមអ្នកទោសនេះទៅលោក? ហើយលោកយល់ស្របដែរឬទេក្នុងការឆ្លើយៗថា -- ក្នុងការយល់ឃើញថា ការងារនេះ គឺវាស្មើនឹងការងារអ្នកយាមទៅហើយ ការងារដែលលោកធ្វើនេះ?

[១៦:១៩:២២]

**លោក សយ សែន៖**

**ឆ៖** បាទ ខ្ញុំជាអ្នកទោសៗ ខ្ញុំនៅជាប់យូរជាងគេ គាត់ៗក៏ថា៖ “អ្អែងនេះ អ្នកអាយាមគុក បើអ៊ីចឹងគ្នាអ្អែង ប្រាំមួយ ប្រាំពីរនាក់ហ្នឹង អ្អែងមើល ប្រយ័ត្នអាណារត់ទៅណា អញមានការទៅនោះបន្តិច អ្អែងមើល!”។ ប៉ុន្តែមើលៗរយៈកាលទៅប្រហែលមួយភ្លែតប្រហែល១០-២០នាទីទេ។ ប៉ុណ្ណឹងទេបាទ។

**ស៖** តើលោកធ្វើយ៉ាងម៉េចដែរ ដើម្បីធ្វើកុំឲ្យអ្នកទោសហ្នឹងរត់?

**ឆ៖** បាទ មានអ្នកណារត់បើសុទ្ធតែស្រីៗ។ កូនចៅយាយញ៉ូ ហើយ អ៊ីហ៊ុន អ៊ីហាន ខ្ញុំ តាចិនតែប៉ុណ្ណឹង មានអ្នកណារត់ មានសុទ្ធតែអ្នកចាស់ៗនៅហ្នឹងទាំងអស់។

**ស៖** នៅពេលយាមនោះ លោកអត់មានអាវុធទេឬ?

**ផ៖** បាទ អ្នកទោសណាគេឲ្យកាន់អាវុធ អត់មានទេ។

**ស៖** តើអ្នកទោសផ្សេងទៀតនោះ មានដឹងថាលោកមានតួនាទីក្នុងការឃាមពួកគេដែរឬទេ?

**ផ៖** បាទ អត់ទេ។

**ស៖** ដូច្នេះ ពួកគេនោះ គិតថាលោកហ្នឹងក៏មានឋានៈជាអ្នកទោសដូចតែពួកគេដែរទេ។ អ៊ីចឹង មែនទេ?

**ផ៖** បាទដូចតែគ្នា អ្នកទោសដូចតែគ្នា។

[១៦:២១:៣៦]

**ស៖** អម្បាញ់មិញនេះ នៅពេលលោកឆ្លើយតបទៅនឹងមេធាវីរបស់លោកហ្នឹង លោកបានឆ្លើយថាលោកមិនមានការស្អប់ខ្ពើម ឬក៏ខឹងសម្បាអីទៅ -- ចំពោះអ្នកឃាមនៅមន្ទីរក្រាំងតាចាន់ទេ។ ដោយលោកមកផ្តល់មូលហេតុថា លោកនឹងមកផ្តល់សក្ខីកម្មនេះដោយគ្មានការស្អប់ខ្ពើមអីនោះទេ <មិន បាន> គុំកួនអីទេ។ ហើយក៏សូមអានដកស្រង់ សម្រង់មួយដែលលោកផ្តល់សក្ខីកម្មទៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ E3/4846, ERN ជាភាសាបារាំងគឺ 00943276, ERN ជាភាសាអង់គ្លេសគឺ 00527786, ERN ជាភាសាខ្មែរគឺ 00527748។ នៅពេលដែលលោកឆ្លើយទៅនឹងសំណួរមួយដែលគេសួរថាឲ្យនិយាយពីអង្គហេតុនោះ លោកឆ្លើយថា៖ “បើគិតទៅពីពេលសម័យ៣ឆ្នាំនេះ ពេលឮឈ្មោះបុគ្គលទាំងអស់នេះ គឺខឹងសម្បាណាស់ព្រោះថាខ្ញុំនៅចាំច្បាស់ណាស់។ ខ្ញុំចង់តែយកពូថៅទៅកាប់ពួកទាំងអស់ហ្នឹងទេ”។ សូមបញ្ចប់ការដកស្រង់។ លោកយល់ស្របនឹងខ្ញុំដែរឬទេក្នុងការនិយាយថា នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជាសួរនោះ សម្ភាសលោកនោះ លោកមានទស្សនៈខុសពីឥឡូវនេះវិញ នៅឆ្លើយមុខតុលាការនេះលោកមានទស្សនៈផ្សេង នៅមុខមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សេង?

**ប្រធានអង្គជំនុំ៖**

ដើមបណ្តឹងរដ្ឋប្បវេណីកុំអាល់ទាន់ឆ្លើយតប!

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៦:២៣:៤៦]

**លោក វាំងសង់ វ៉ាយដ៍ ដេស្តាឯល៖**

ខ្ញុំមិនជំទាស់ទេ គឺថាសូមឲ្យសាធារណជនដឹង។ ខ្ញុំគ្រាន់តែចង់ប<ញ្ជា>ក់ ពញ្ញាក់ស្មារតីថាកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង ចុះនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៤។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំចោទសំណួរឡើងវិញម្តងទៀត។ តើអង្គាល់អ្វីដែលលោកនិយាយទៅប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយនិងអ្វីលោកនិយាយប្រាប់មកតុលាការនេះ ខុសគ្នា។ លោកយល់ស្របនឹងខ្ញុំដែរឬទេ?

**លោក សយ សែន៖**

**ឆ៖** បាទ យល់ស្រប។ ព្រោះថា យល់ស្របពីសម័យមុនគឺអត់មានច្បាប់និងតឹងរ៉ឹង គឺការកំហឹងរបស់មនុស្សតែងនឹងមាន ហើយមកសម័យឥឡូវមានច្បាប់និងតឹងរ៉ឹងមែនទែន តាមច្បាប់ក្រឹត្យក្រមនៅតុលាការបាទ។

**កញ្ញា អង់តា ហ្គីសសេ៖**

ឥឡូវនេះ ខ្ញុំសូមចូលនិយាយអំពីការបំភ្លឺទៅលើការរំលោភផ្លូវភេទ។ តើខ្ញុំ បើសិនជាអាចចោទសំណួរដោយមិនបាច់<ចូលវគ្គ>អាសាធារណៈអីទេ លោកប្រធាន ឬក៏យ៉ាងម៉េច? លោកប្រធាន ចង់ចូលសវនាការអសាធារណៈ ឬសាធារណៈ? ខ្ញុំព្យាយាមមិននិយាយពីឈ្មោះរបស់បុគ្គលនុ៎ងទេ លោកប្រធាន។ <ប៉ុន្តែ តាមតែអង្គជំនុំជម្រះសម្រេចចុះ!>

**ប្រធានអង្គជំនុំ៖**

បាទ បើព្យាយាមនិយាយមិនចំឈ្មោះបុគ្គលជាការល្អ ប៉ុន្តែសុំឱ្យតាំងសំណួរឱ្យបានស្រួលស្តាប់ ទំនងអ្នកស្តាប់នុ៎ង ក៏អាចស្តាប់សំណួរយល់ ហើយនិងអាចឆ្លើយតបបាន ពីព្រោះសំណួរកន្លងមក ពិតជាពិបាកស្តាប់។ ជាភាសាខ្មែរគឺពិតជាពិបាកស្តាប់ណាស់។ ញែកវាមិនដាច់រវាងបញ្ហាករណីទាំងពីរហ្នឹង វាអត់ដាច់ពីរគ្នាទេ។ អញ្ជើញ!

[១៦:២៥:៥៨]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំថាជាភាសាបារាំងនោះ ដូចជាមិនសូវជាស្មុគស្មាញដល់<ម៉្ចឹ>ងទេ។ ឥឡូវ ខ្ញុំព្យាយាមធ្វើយ៉ាងម៉េចឱ្យសាមញ្ញស្រួលយល់។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោក សយ សែន លោកបាននិយាយអំពីមនុស្សបីនាក់។ ម្នាក់ប្រហែលជាទទួលការរុកកួនផ្លូវភេទ ហើយពីរនាក់ទៀតទទួលការរំលោភបំពាន ហើយដោយមានការញាត់គ្រាប់កាំភ្លើង

<អឹម>៧៩ ចូលប្រដាប់ភេទផង។ តើលោកបែងចែកទេរវាងមនុស្សដែលថា គេគ្រាន់តែលូកលាន់គាត់ទេ ហើយនិងនារីពីរនាក់ទៀត តែប្រហែលជាទំនងជាត្រូវបានគេរំលោភដោយមានញាត់គ្រាប់សេវេន-ធីណៃចូលប្រដាក់ផ្លូវភេទផង។ លោកបែងចែកឲ្យដាច់បានទេ ពីរករណីខុសគ្នានេះ?

**លោក សយ សែន៖**

**ឆ៖** បាទ បែងចែកដាច់បាន។ ខ្ញុំដឹងតែពីរនាក់ដែលរំលោភ ហើយញាត់គ្រាប់ក្បាលម៉ាជិនហ្នឹង ដឹងគាត់ប្រាប់ខ្ញុំផ្ទាល់តែម្តង។ ហើយគាត់ឲ្យខ្ញុំទៅលុបខ្មោចហ្នឹង។ ហើយម្នាក់នោះ គឺបានត្រឹមតែលូកលើលូកក្រោម ឯកសារព័ត៌មានហ្នឹង ខ្ញុំបានរាយការណ៍ប្រាប់ជាបីប្អូនដងទៅហើយ។ បាទ នៅដដែលៗ នៅតែដដែលហ្នឹង បាទ។

[១៦:២៧:១៩]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមចោទសំណួរទៅលើស្ត្រីពីរនាក់ហ្នឹង ដែលត្រូវបានគេចាប់រំលោភ ហើយដែលមានញាត់គ្រាប់កាំភ្លើងចូលប្រដាក់ភេទ។ លោកយល់ខ្ញុំច្បាស់ហើយណ៎ះ?

**ឆ៖** បាទ។

**ស៖** លោកចង់បន្ថែមអ្វីទៀត ឬក៏យ៉ាងម៉េ? ឥឡូវនេះលោកយល់ច្បាស់ហើយណ៎ះ! ខ្ញុំនិយាយប្រាប់លោកមុនថា ខ្ញុំនឹងចោទសំណួរដែលទាក់ទងទៅអ្នកស្ត្រីពីរនាក់ដែលត្រូវបានគេរំលោភហើយ មានញាត់គ្រាប់កាំភ្លើង គ្រាប់សេវេនធីណៃចូលទេ។ យើងបន្តពិភាក្សាតែចំណុចនេះទេ។

**ឆ៖** បាទ ខ្ញុំបានប្រាប់ពីរបីដងហើយតើ ចំណុចពីរនាក់ហ្នឹង ប្រាប់តាំងពីខ្ញុំឡើងមកសក្ខីកម្មលើកទី១មករហូត។ បាទបានប្រាប់ពីរដង បីដងហើយហ្នឹង។

**ប្រធានអង្គជំនុំ៖**

ចាំៗស្តាប់សំណួរសិនណ៎ះ! ចាំស្តាប់សំណួរហើយឆ្លើយតប ឆ្លើយខ្លីៗបានហើយ។ ឆ្លើយឲ្យចំនឹងសំណួរចាំបាច់ដែលត្រូវឆ្លើយតបនឹងសំណួរបានហើយ។ ចាំស្តាប់សំណួរសិនណ៎ះ!

[១៦:២៨:៤២]

**សួរដោយកញ្ញា អង់តា ហ្គិសសេ៖**

**ស៖** ខ្ញុំមិនសុំឲ្យ<លោក>និយាយអំពីអង្គហេតុនោះទេ។ ខ្ញុំសុំឲ្យលោកបញ្ជាក់ប្រាប់<នៅមុខ>តុលាការវិញ។ <ជាបឋម តើលោកបានឃើញការ>រំលោភផ្លូវភេទ<នេះទេ>?

**លោក សយ សែន៖**

**ឆះ** ហ្នឹងក៏ខ្ញុំបានជម្រាបពីមុនមកដែរ ថាគាត់រំលោភហើយ គាត់សម្លាប់គេហើយ គេប្រើខ្ញុំឲ្យទៅលុបខ្មោចហ្នឹង បាទខ្ញុំបានប្រាប់ហើយតើ។

**សះ** អម្បាញ់មិញ នៅពេលដែលយើងនិយាយអំពីអង្គហេតុនេះ ខ្ញុំបានឮថា ឌុច បានរៀបរាប់រឿងរ៉ាវនេះប្រាប់លោក ហើយលោកមិនបានឃើញសកម្មភាពរំលោភនេះទេ។ តើលោកអាចបញ្ជាក់ទៅតុលាការបានដែរឬទេ ថាតើលោកបានមានវត្តមាននៅពេលដែលគេរំលោភហ្នឹងផ្ទាល់ដែរឬទេ? ឃើញនឹងភ្នែកដែរឬទេ?

[១៦:២៩:៥០]

**ឆះ** បាទ អត់ឃើញទេ ប៉ុន្តែគាត់ប្រាប់ខ្ញុំ។ ឌុច ហ្នឹងគាត់អ្នកប្រាប់ខ្ញុំផ្ទាល់ហ្នង។ គាត់ថា "អញធ្វើហើយ សម្លាប់ហើយ អ្នែងទៅលុបតាម -- អ្នែងទៅមើលៗ អ្នែងឃើញៗយ៉ាងម៉េចខ្លះ? អ្នែងទៅដល់ អ្នែងឃើញអីខ្លះក្នុងហ្នឹង?" ថា "ខ្ញុំឃើញបង"។ ឃើញគាត់ឲ្យសួរចំណុចថា ចង់សួរខ្ញុំសួរថា "ឃើញគេគ្រាប់ក្បាលម៉ាជិននេះញុកកេរ្តិ៍ខ្មាស" តែប៉ុណ្ណឹងទេបាទ។

**សះ** បើដូច្នេះ តើលោកអាចបញ្ជាក់បានដែរឬទេថាៗ តាឌុចតូច ហ្នឹងហើយដែលបានរៀបរាប់ពីរឿងរំលោភហ្នឹងដែលគាត់បានប្រព្រឹត្ត ហើយគាត់ហ្នឹងហើយដែលបានសួរលោកថាមើលឃើញគ្រាប់<អឹម>សេវេនធីណែហ្នឹងទេ។ អ៊ីចឹង ឌុចតូច ហ្នឹងហើយ ឬក៏យ៉ាងម៉េចដែលប្រាប់លោក?

**ឆះ** បាទ ឌុចតូចហ្នឹង។

**សះ** <តើ>នៅថ្ងៃកើតហេតុហ្នឹង<ជាថ្ងៃដដែលជាមួយគ្នានឹងថ្ងៃ>ដែលគាត់រៀបរាប់អំពីការរំលោភហ្នឹង ជូនលោកស្តាប់?

**ឆះ** បាទ នៅថ្ងៃកើតហេតុមួយភ្លែតហ្នឹងបាទ។

**សះ** សវនាការថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ លោកបានឆ្លើយថា ឌុចតូច នេះហើយនិង ស្វូត្រ សាំង បានរំលោភ ហើយអ្នកណាដែលប្រាប់លោកថា ស្វូត្រ សាំង ចូលរួមក្នុងការរំលោភនេះដែរ?

**ឆះ** ឌុច គាត់អ្នកប្រាប់។

**កញ្ញា អង់តា ហ្គីសសេះ**

លោកប្រធានខ្ញុំអស់សំណួរហើយ។ ខ្ញុំសូមធ្វើសំណើមួយដោយសារអង្គហេតុដែលចោទប្រកាន់នេះធ្ងន់ធ្ងរ ហើយដោយមានសាក្សី<ពីរនាក់>ផ្សេងទៀតដែលមាននៅទីនេះ។ អ៊ីចឹងគួរតែធ្វើយ៉ាងណាឲ្យមានការប្រឈមមុខគ្នាលោកប្រធាន តទល់នឹងគ្នាជាមួយនឹងសាក្សីបន្តបន្ទាប់ទៀត <ដើម្បីស្វែងរក

ការពិត> ព្រោះយើងមានសាក្សីច្រើន។

**ប្រធានអង្គជំនុំ៖**

ភាគីដទៃទៀតមានបញ្ហាអីលើសំណើសុំនេះទេ?

[១៦:៣២:៤៥]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន សំណើនេះមិនច្បាស់ទេ ហើយពេលវេលាកាន់តែវាយឺតហើយ ខ្ញុំគិតថាមេធាវីការពារក្តីគួរតែដាក់សំណើជាលាយលក្ខណ៍អក្សរ<។ លោកស្រីមេធាវីបានលើកឡើងអំពីសាក្សីពីរនាក់ទៀត តែឥឡូវ យើងមានដើមបណ្តឹងរដ្ឋប្បវេណីតែម្នាក់ប៉ុណ្ណោះនៅទីនេះ។> យើងមានសាក្សីជាច្រើន <មែន បើ>យើងនិយាយពី<>ឌុច, សាំង, ស៊ីន <នោះ។ និយាយឲ្យចំទៅ ខ្ញុំមិនយល់អំពីសំណើនេះសោះ។ ខ្ញុំគិតថា យើងមិនចាំបាច់មាន>ការពិភាក្សាគ្នាយូរត្រង់ចំណុចនេះ<ទេ>។ ខ្ញុំគិតថា មេធាវីការពារក្តីគួរតែដាក់សំណើជាលាយលក្ខណ៍អក្សរមក។

[១៦:៣៣:១០]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំអាចធ្វើសំណើជាលាយលក្ខណ៍អក្សរបាន។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

អរគុណលោកប្រធាន។ ហើយយើងក៏ត្រូវការពេលវេលាផងដែរ ដើម្បីឆ្លើយតបទៅនឹងសំណើនេះ បើសិនជាធ្វើជាលាយលក្ខណ៍អក្សរហ្នឹងជាការងាយស្រួលចំពោះយើងផងដែរ។ យើងបាន<ស្តាប់ច្រើនហើយ> សូត្រ សាំង ហើយ សយ សែន នេះ គឺថាមាននូវចម្លើយខុសគ្នា។ ខ្ញុំមិនយល់ថាតើការឲ្យគាត់តទល់គ្នានោះបានផលប្រយោជន៍អីប៉ុន្មានទេ ហើយសំណើនេះក៏វាវាងយឺតដែរ ថាមានសវនាការយូរមកហើយ ស៊ើបអង្កេតយូរណាស់មកហើយ អ៊ីចឹងចំណាយ -- ដីកាដំណោះស្រាយមានតាំងពីយូរមកហើយ។ អ៊ីចឹងមេធាវីការពារក្តីគួរតែធ្វើសំណើពីមុនមក ថាតាំងពីដំណាក់កាលស៊ើបអង្កេតតែម្តង។ អ៊ីចឹងចំពោះយើងៗយល់ឃើញថាវាយឺតហួសពេលទៅហើយៗ <មិនមាន>ប្រយោជន៍<អី>ក្នុងការរកឃើញការពិតនេះទេ<> បើសិនជាព្រមទទួលសំណើហ្នឹង<>អាចឃើញថាគាត់មានចម្លើយខុសគ្នា ហើយធ្វើឲ្យតុលាការខាតពេលវេលា។ អ៊ីចឹងបើសិនជាយើង បើសិនជា<មេធាវីការពារក្តី>ធ្វើសំណើជាលាយលក្ខណ៍អក្សរ យើងនឹងឆ្លើយតបទៅដែរ ថាយើងសូមជំទាស់ជាមុនឲ្យហើយទៅ ព្រោះថានេះ

ជំទាស់តាមលក្ខណៈគោលការណ៍។

[១៦:៣៤:៤៦]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឆ្លើយតបដោយសង្ខេបលោកប្រធាន។ ខ្ញុំគិតថា វាជាការល្អដែលយើងគួរតែមានការសរសេរជាលាយលក្ខណ៍អក្សរទៅលើបញ្ហានេះ<។ អ្វីដែលខ្ញុំកត់សម្គាល់ឃើញនោះ> មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី<មិនមែនជាភាគីតែមួយគត់ ដែលត្រូវលើក>ពិភាក្សាអំពីបញ្ហានេះ<ទេ។ ខ្ញុំគិតថា>មានមេធាវីពីររូប<ទៀត>តំណាងឲ្យពួកដើមបណ្ដឹងរដ្ឋប្បវេណីទាំងពីរនាក់នេះទៀត។ <នេះមុខតែមាន> ទំនាស់ផលប្រយោជន៍<ហើយ> ព្រោះថាឥឡូវនេះយើងមានមេធាវីតែមួយទេដែលបង្ហាញពីជំហរ។ ដូច្នេះ យើងចង់ឲ្យមានមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីដែលបង្ហាញពីជំហរទាំងពីររូបតែម្ដង។ ខ្ញុំគិតថាវាមានទំនាស់ផលប្រយោជន៍សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី។ ដូច្នេះ វាមិនអាចឲ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីតែមួយរូប<លើកបញ្ហានេះមកនិយាយនោះ>ទេ។ ប៉ុន្តែទោះបីយ៉ាងក៏ដោយ ខ្ញុំគិតថា ឥឡូវវាហួសម៉ោងទៅហើយ ដូច្នេះយើងមិនគួរមានការប្រឈម<គ្នានៅពេលនេះ>ទេ យើងគួរតែធ្វើកិច្ចដំណើរការនីតិវិធីតាមលាយលក្ខណ៍អក្សរទៅវិញចុះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះអង្គជំនុំជម្រះសម្រេចឲ្យម្ចាស់សំណើ ដាក់សំណើរបស់ខ្លួនជាលាយលក្ខណ៍អក្សរមកអង្គជំនុំជម្រះ។

បាទ ជាបន្តទៅទៀត លោក សយ សែន ក្នុងនាមលោកជាដើមបណ្ដឹងរដ្ឋប្បវេណី លោកអាចថ្លែងរៀបរាប់ជូនដល់អង្គជំនុំជម្រះស្ដាប់អំពីរឿងហេតុ ទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទពីររូប នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ដល់លោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលនាំឲ្យលោកសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប្ដឹងទាមទារសំណងជំងឺចិត្តនិងជាសមូហភាពពីជនជាប់ចោទ និងអំពីស្ថានភាពព្យសនកម្មដែលមានចំពោះលោកជាអាទិ៍ ខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត និងជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ ជាព្យសនកម្មផ្ទាល់ខ្លួន និងកើតមានពិតប្រាកដរហូតមកដល់បច្ចុប្បន្ននេះ។ ប្រសិនបើមានលោក លោកមានបំណងធ្វើដូច្នេះ។ សូមអញ្ជើញ!

[១៦:៣៧:០២]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក សយ សែន៖**

បាទ ខ្ញុំអរគុណលោកប្រធានបានឡើងមកសវនាការនៅសាលាក្ដីខ្មែរក្រហម ដើម្បីជំនួសមុខឲ្យអ្នកដែលរងគ្រោះទាំងអស់ទូទាំងប្រទេស គ្រប់កន្លែង មិនថានៅក្រាំងតាចាន់មួយទេ បានបំភ្លឺ និងគ្មាននៅអ្នកដែលបានចែកឋាន និងស្លាប់ទៅពីជំនាន់នោះ។ ទោះបីរូបខ្ញុំឡើងមកតុលាការនេះ ក៏គ្មាននឹងផលប្រយោជន៍បុគ្គលខ្ញុំផ្ទាល់ក៏អត់មានទេ មានដើម្បីក្មេងស្រុករក្រោយ អ្នកនិងអ្នកស្លាប់ទៅចែកឋានទៅបានៗស្លាប់កើតជាតិក្រោយៗកុំឲ្យប៉ះពាល់ ប៉ះសង្គមដែលមិនដែលឃើញ អត់ដែលឃើញ។ បានថានិយាយមិនចង់ឃើញ ខ្ញុំនិយាយអត់ចង់ចេញទេបាទ។ អាហ្នឹងចប់មួយ។

ខ្ញុំសូមសួរសំណួរនូវលោកតុលាការថា រឿងអី បានកើតសង្គមដែលម្ហូបអាហារស្បៀងមានគ្រប់មុខបែបយ៉ាងដែលបង្អត់បាយប្រជាជនដែលទូទាំងប្រទេស ហើយមកស្លាប់ចោល។ ចង់សួរសំណួរគាត់ចោទទៅលើគាត់វិញ តែប៉ុណ្ណឹង ឲ្យគាត់ឆ្លើយចំពោះខ្ញុំ បានតែមួយម៉ាត់ពីរម៉ាត់ ក៏ខ្ញុំអត់ចិត្តដែរ។

សូមអស់យោបល់តែប៉ុណ្ណឹងចុះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោក សយ សែន។ អង្គជំនុំជម្រះជម្រាបលោក សយ សែន ថា នៅក្នុងសវនាការកាលពីថ្ងៃ០៨ ខែមករា ឆ្នាំ១០១៥ បន្ទាប់ពីអង្គជំនុំជម្រះបានស្ដាប់ជនជាប់ចោទទាំងពីរនាក់ ឆ្លើយបញ្ជាក់អំពីការដែលពួកគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។ អង្គជំនុំជម្រះបានកត់សម្គាល់ថា ជនជាប់ចោទទាំងពីរនាក់នៅតែរក្សាជំហររបស់ខ្លួនបន្តអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបដដែល លើកលែងតែ និងរហូតដល់ពេលណាដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានព័ត៌មានជាក់ច្បាស់ពីជនជាប់ចោទ ឬពីសហ មេធាវីការពារក្ដីរបស់ជនជាប់ចោទ។ នៅក្នុងសវនាការនោះ អង្គជំនុំជម្រះបានកំណត់ឲ្យជនជាប់ចោទ និង/ឬ មេធាវីការពារក្ដីជនជាប់ចោទត្រូវមានការទទួលខុសត្រូវក្នុងការជូនដំណឹងដល់អង្គជំនុំជម្រះឲ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព ប្រសិនបើជនជាប់ចោទសម្រេចលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយយល់ព្រមឆ្លើយតបទៅនឹងសំណួរនៅដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីសវនាការដែល សួរដោយអង្គជំនុំជម្រះ ឬភាគីពាក់ព័ន្ធ។ រហូតមកដល់ពេលនេះ អង្គជំនុំជម្រះនៅមិនទាន់បានទទួលដំណឹងអំពីការផ្លាស់ប្ដូរជំហររបស់ជនជាប់ចោទទាំងពីរនាក់ ពីការសម្រេចលះបង់សិទ្ធិក្នុងការនៅស្ងៀម មិនឆ្លើយតប មកជាការយល់ព្រមឆ្លើយតបនឹងសំណួរនៅឡើយទេ។

[១៦:៣៩:៤៨]

ដូច្នេះអង្គជំនុំជម្រះមិនអាចបង្គាប់បញ្ជាឲ្យគាត់ឆ្លើយតបជាមួយនឹងសំណួររបស់លោកបានទេ ពីព្រោះស្ថិតនៅក្នុងលក្ខខណ្ឌដែលគាត់រក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតប។

សវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី២៦ ខែមីនា ឆ្នាំ ២០១៥ ចាប់ផ្តើមធ្វើពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម 2-TCCP-880 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។ ហើយអង្គជំនុំជម្រះសូមអរគុណលោក សយ សែន ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងឋានៈដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមកន្លះថ្ងៃមកនេះ ហើយសក្ខីកម្មរបស់លោកអាចនឹងរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ ការផ្តល់សក្ខីកម្មរបស់លោកបានដល់ទីបញ្ចប់ហើយ វត្តមានរបស់លោកមាននៅអ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់ទីលំនៅ ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកធ្វើដំណើរត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

ហើយបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលគាំពារសក្សី និងអ្នកជំនាញ ក្នុងការជូនលោក សយ សែន វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការវិញនៅនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:៤១ នាទី)*